

## ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ជនរួចពីរងគ្រោះដោយការជួញដូរផ្លូវភេទ៖ បទពិសោធន៍ និងការបង្ហាញពីការសងគុណឪពុកម្ដាយ និងក្ដីកង្វល់ផ្នែកហិរញ្ញវត្ថុ

# របាយការណ៍សម្រាប់ការអនុវត្តន៍

## គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង

ជាគម្រោងស្រាវជ្រាវរបស់អង្គការសម្ព័ន្ធចាប់ដៃអំពីសមាហរណកម្ម ដែលសិក្សាទៅលើវដ្ដជីវិតរបស់អ្នក ដែលត្រូវបានគេកេងប្រវ័ញ្ច និងជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា


អ្នកនិពន្ធ : ជូលៀ ស្មីត-ប្រេក

សហការីនិពន្ធ : លឹម វណ្ណធារី និង ញ៉ាញ់ ចន្ថា



ឆ្នាំ ២០១៥

សម្ព័ន្ធចាប់ដៃ
CHAB DAI COALITION

equitas.
LOVE146.ORG
end child sex slavery & exploitation
TENTH CHURCH
imago dei fund
EARTH HEIR

# សេចក្តីថ្លែងអំណរគុណ

ដើម្បីឲ្យការស្រាវជ្រាវនេះមានដំណើរការ យើងបានសហការដៃគូជាមួយមនុស្សមួយចំនួន និងបណ្តាអង្គការជាច្រើន ហើយបានទទួលនូវការឧបត្ថម្ភគាំទ្រយ៉ាងមុតមាំពីម្ចាស់ជំនួយរបស់គម្រោង។ ជាបឋម យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកស្រី ស៊ីវន ម៉ាយ ដែលអ្នកប្រឹក្សាផ្នែកស្រាវជ្រាវរបស់គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង សម្រាប់ទស្សនៈវិស័យ ទិសដៅ និងការត្រួតពិនិត្យគម្រោងចាប់តាំងពីពេលកំពុងចាប់ផ្តើមគម្រោងរហូតមកដល់សព្វថ្ងៃនេះ។ អរគុណផងដែរ ចំពោះក្រុមអ្នកស្រាវជ្រាវរបស់គម្រោងមេអំបៅគឺ លោក ស្រៀង-ផល្លី កញ្ញា ប៊ុន-ដារីន និងកញ្ញា កឿក-ផលឡែន សម្រាប់ការខិតខំប្រឹងប្រែង ដោយមិនគិតពីការនឿយហត់ ក្នុងការប្រមូលទិន្នន័យ រួចចំលងទិន្ន័យជាសំឡេងឱ្យទៅជាអត្ថបទភាសាខ្មែរ និងបកប្រែឱ្យទៅជាភាសាអង់គ្លេស។ យើងក៏សូមអរគុណចំពោះលោកស្រី ស៊ីវន-ម៉ាយ លោក គ្លេន-ម៉ាយ លោកស្រី ហេឡេន-ស្វ៊ន លោក ថដ-ម៉ូរីសុន និងលោក ឆាលី-ស្មីតប្រេក ចំពោះការផ្តល់ជាមតិយោបល់ទៅលើសេចក្តីព្រាងនៃបាយការណ៍សិក្សានេះ។

យើងសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់អ៊ីឃ្វីតាស់ (Equitas) ដែលជាម្ចាស់ជំនួយដើមដំបូងបំផុតរបស់គម្រោងចំពោះការជឿជាក់ និងការបន្តផ្តល់ជំនួយដល់គម្រោងនេះតាំងពីឆ្នាំកន្លងៗមក។ យើងក៏សូមអរគុណដល់ម្ចាស់ជំនួយដទៃទៀតដូចជា Tenth Church, Imago Dei, Love 146, Earth Heir និងបណ្តាម្ចាស់ជំនួយផ្សេងៗទៀតសម្រាប់ការឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្ត។

យើងសូមអរគុណចំពោះអង្គការដៃគូរបស់គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង។ យើងពិតជាកោតសរសើរនូវរាល់ការខ្នះខ្នែងជួយសម្របសម្រួល និងការផ្តល់ព័ត៌មានទាក់ទងនឹងអតិថិជននៅក្នុងគម្រោង។ យើងក៏សូមអរគុណ ចំពោះការចូលរួមផ្តល់ជាមតិវាយតម្លៃលើលទ្ធផលនៃការសិក្សា និងអនុសាសន៍នានានៅក្នុងរបាយការណ៍សិក្សារបស់យើង។ ជាពិសេស យើងក៏សូមអរគុណចំពោះអង្គការមួយចំនួនដូចជា អង្គការ Agape International Mission, អង្គការ American Rehabilitation Ministries នៅបាត់ដំបង និងសៀមរាប, អង្គការ Bloom Asia, អង្គការ Cambodian Hope Organization, អង្គការ Citipointe, អង្គការកូនស្រី, អង្គការសង្គ្រោះជោគវាសនា, អង្គការហាការ, អង្គការថៃទាំសុខភាពកុមារ, អង្គការបេសកម្មយុត្តិធម៌អន្តរជាតិ, អង្គការ Pleroma Home for Girls, អង្គការសួននៃក្តីសង្ឃឹមកម្ពុជា, អង្គការរតនៈអន្តរជាតិ, អង្គការ Hope for Justice, អង្គការ World Hope, និងអង្គការទស្សនៈពិភពលោកកម្ពុជា។

យើងក៏សូមថ្លែងអំណរអរគុណចំពោះអ្នកដែលបានចូលរួមចំណែកក្នុងគម្រោងដូចខាងក្រោម៖

លោកស្រី ហេឡេន ស្វ៊ន ជាស្ថាបនិក និងជានាយិកាអន្តរជាតិនៃអង្គការសម្ព័ន្ធចាប់ដៃ សម្រាប់ទស្សនៈវិស័យការណែនាំ និងទឹកចិត្តដ៏មុតមាំចំពោះការស្រាវជ្រាវនេះ។

លោក រស់ យ៉េង ប្រធានប្រចាំប្រទេសអង្គការសម្ព័ន្ធចាប់ដៃ ចំពោះការគាំទ្រ និងលើកទឹកចិត្ត។

កញ្ញា អោង មួយឡែន ប្រធានផ្នែកហិរញ្ញវត្ថុអង្គការសម្ព័ន្ធចាប់ដៃ ចំពោះការខិតខំប្រឹងប្រែងមិនគិតពីការនឿយហត់ក្នុងការរៀបចំខ្ទង់ចំណាយ និងការទំនាក់ទំនងជាមួយម្ចាស់ជំនួយសម្រាប់គម្រោងស្រាវជ្រាវនេះ។

រូបថតទំព័រមុខដោយៈ កញ្ញា លឹម វណ្ណធារី
រចនាទំព័រមុខដោយៈ លោក ស្រៀង ផល្លី

ដើម្បីស្វែងរកេរបាយការណ៍សិក្សាទាំងមូល និងឯកសារយោងស្តីពី *"ការធ្វើសមាហរណសេដ្ឋកិច្ចរបស់ជនរួចពីរងគ្រោះដោយការជួញដូរផ្លូវភេទៈ បទពិសោធន៍ និងការបង្ហាញពីការសងគុណឪពុកម្តាយ និងក្តីកង្វល់ផ្នែកហិរញ្ញវត្ថុ"* សូមមើលនៅក្នុងៈ

Smith-Brake, Julia. Lim, Vanntheary. Nhanh, Channtha. (2015), 'Economic Reintegration of Survivors of Sex Trafficking: Experiences and Expressions of Filial Piety and Financial Anxiety'.
The Butterfly Longitudinal Research Project: A Chab Dai study on (Re-) integration: Researching the lifecycle of sexual exploitation & trafficking in Cambodia (Phnom Penh: Chab Dai).

www.chabdai.org.
and/or
freedomcollaborative.org

# មាតិកា


១ .សេចក្តីផ្តើម ........ 1
២. កម្មវត្ថុនៃការសិក្សា ........ 1
៣. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ 2
៣.១ ទំហំ និងវិធីសាស្ត្រនៃការសិក្សាប៉ាន់ប្រមាណតាមប្រធានបទរួម ........ 3
*៣.១.១ ការសិក្សាប៉ាន់ប្រមាណ* ........ 3
*៣.១.២ ការពិភាក្សាក្រុមគោលដៅ (FGD)* ........ 3
*៣.១.៣ ការសម្ភាសន៍ និងទិន្នន័យសង្ខេបជាសាច់រឿង* ........ 4
៤. លទ្ធផលនៃការសិក្សា និងការពិភាក្សា ........ 5
៤.១ ការកំណត់និយមន័យ ........ 5
*៤.១.១ ការធ្វើសមាហរណកម្មសេដ្ឋកិច្ច* ........ 5
*៤.១.២ ការបតស្នងសងគុណឪពុកម្តាយ* ........ 6
*៤.១.៣ ក្តីបារម្ភផ្នែកហិរញ្ញវត្ថុ* ........ 6
៤.២ ការបំពេញកាតព្វកិច្ចគ្រួសារ គឺជាការបង្ហាញការសងគុណ ........ 7
*៤.២.១ ក្តីបារម្ភ និងទំនួលខុសត្រូវ* ........ 7
*៤.២.២ កិត្តិយស និងការសងគុណ* ........ 10
*៤.២.៣ ទំនាក់ទំនងអវិជ្ជមាន* ........ 12
*៤.២.៤ បន្ទុកចំពោះការបំពេញកាតព្វកិច្ចគ្រួសារ* ........ 14
៤.៣ ការទទួលរងនូវការឈឺចាប់ពីក្តីបារម្ភផ្នែកហិរញ្ញវត្ថុរបស់ជនរួចពីរងគ្រោះ ........ 16
*៤.៣.១ បញ្ហាថវិកា និងសុខភាពផ្លូវចិត្ត* ........ 18
*៤.៣.២ ការរំពឹងទុកមិនច្បាស់លាស់ និងក្តីបារម្ភសម្រាប់ថ្ងៃអនាគត* ........ 20
៤.៤ ភាពមិនមានលំនឹងផ្នែកហិរញ្ញវត្ថុរបស់ជនរួចពីរងគ្រោះ និងបំណុល ........ 21
*៤.៤.១ អស្ថេរភាពហិរញ្ញវត្ថុក្នុងពេលបច្ចុប្បន្ន និងពេលអនាគត* ........ 21
*៤.៤.៣ វដ្តនៃបំណុល* ........ 25
៤.៥ ជនរួចពីរងគ្រោះភាគច្រើនមិនបានត្រៀមខ្លួនសម្រាប់ការងារ ........ 27
*៤.៥.១ ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ទីផ្សារការងារ* ........ 29
*៤.៥.២ អាជីវកម្មសង្គមនៃកម្មវិធីមណ្ឌលថែទាំ* ........ 30
៥.១ សេចក្តីសន្និដ្ឋាន និងដែនកំណត់ ........ 30
៥.២ អនុសាសន៍ ........ 32
*៥.២.១ ភាពសំខាន់នៃគ្រួសារ* ........ 32

*៥.២.២ គំរូនៃសមត្ថភាពផ្នែកហិរញ្ញវត្ថុក្នុងចំណោមជនរួចពីវេងគ្រោះ*...........................................33
*៥.២.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវនៅពេលអនាគត*................................................36
៦. គន្លូនិទ្ទេស.............................................................................................................38

# បញ្ជីតារាង

តារាង 1៖ ការផ្ញើលុយទៅឪពុកម្ដាយ/គ្រួសារ (ចំនួន=៧៧នាក់) 7
តារាង 2៖ អារម្មណ៍អំពីទំនួលខុសត្រូវចំពោះគ្រួសារ (ចំនួន=៧៧នាក់) 7
តារាង 3៖ ក្ដីបារម្ភអំពីជីវភាពគ្រួសារ 8
តារាង 4៖ ប្រយោគទាក់ទងនឹងក្ដីបារម្ភ និងទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ដល់ឪពុកម្ដាយ និងក្រុមគ្រួសារ 8
តារាង 5៖ ប្រយោគទាក់ទងនឹងការផ្ដោកផែនការអនាគត 9
តារាង 6៖ ប្រយោគទាក់ទងនឹងបំណងចិត្តសម្រាប់ថ្ងៃអនាគត 10
តារាង 7៖ ការបង្ហាញអំពីការសងគុណរបស់ជនរួចពីរងគ្រោះ 11
តារាង 8៖ ការទុកចិត្តលើឪពុកម្ដាយ (ចំនួន=៧៧នាក់) 12
តារាង 9៖ ប្រយោគទាក់ទងនឹងការផ្គត់ផ្គង់ដល់ឪពុកម្ដាយ ទោះបីជាមានទំនាក់ទំនងល្អជាមួយពួកគេ 13
តារាង 10៖ សូចនាករអំពីភាពបរាជ័យក្នុងគ្រួសារ (ចំនួន=៧៧នាក់) 14
តារាង 11៖ ប្រយោគទាក់ទងនឹងបន្ទុកនៃការសងគុណ 15
តារាង 12៖ ទស្សនៈយល់ឃើញអំពីកាតព្វកិច្ច 15
តារាង 13៖ ចម្លើយ "ខ្ញុំរកលុយបានគ្រប់គ្រាន់ ដោយធ្វើការនៅក្នុងការងារតែមួយ" (ចំនួន=៤៤នាក់) 17
តារាង 14៖ ការបង្ហាញ និងបទពិសោធន៍អំពីក្ដីបារម្ភផ្នែកហិរញ្ញវត្ថុ (ចំនួន=៧៧នាក់) 17
តារាង 15៖ ការជះឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានដោយសារទំនួលខុសត្រូវសងគុណឪពុកម្ដាយ 19
តារាង 16៖ ប្រាក់ខែប្រចាំខែជាមធ្យម 22
តារាង 17៖ អារម្មណ៍ផ្ទាល់ខ្លួនអំពីបំណុលគ្រួសារ 23
តារាង 18៖ ទំនួលខុសត្រូវ និងអ្នកទទួលខុសត្រូវនៅក្នុងបំណុលគ្រួសារ 24
តារាង 19៖ ក្ដីបារម្ភទាក់ទងនឹងបំណុល (ចំនួន=៧៧នាក់) 24
តារាង 20៖ បទពិសោធន៍នៃបំណុល (ចំនួន=៧៧នាក់) 25
តារាង 21៖ ប្រភេទនៃការងារ ដែលមានអត្រានៃការលាឈប់ខ្ពស់ (ចំនួន=១១នាក់) 28
តារាង 22៖ ហេតុផលក្នុងការចាកចេញពីការងារ( ចំនួន=៣៤នាក់) 28
តារាង 23៖ ការបង្ហាញពីការពេញចិត្ត ឬមិនពេញចិត្តចំពោះការងារជាមួយកម្មវិធីជំនួយ 30
តារាង 24៖ ការបង្ហាញពីការសងគុណ និងក្ដីបារម្ភផ្នែកហិរញ្ញវត្ថុរបស់ជនរួចពីរងគ្រោះ 31
តារាង 25៖ គំរូសមត្ថភាពហិរញ្ញវត្ថុសម្រាប់ជនរួចពីរងគ្រោះ 36

## ១ .សេចក្តីផ្តើម

ឯកសារនេះ គឺជារបាយការណ៍សិក្សាស្រាវជ្រាវសង្ខេបមួយដកស្រង់ពីរបាយការណ៍សិក្សាប្រធានបទរួម ដែលស្តីអំពី "ការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ជនរួចពីរងគ្រោះដោយការជួញដូរផ្លូវភេទ៖ បទពិសោធន៍ និងការបង្ហាញពីការសងគុណឪពុកម្តាយ និងក្តីកង្វល់ផ្នែកហិរញ្ញវត្ថុ"។ ឯកសារនេះ មានគោលបំណងផ្តល់នូវសេចក្តីសង្ខេបពីលទ្ធផលនៃការសិក្សាពិស្តារចេញពីការសិក្សាប៉ាន់ប្រមាណលើប្រធានបទរួម។ ហើយឯកសារនេះក៏មានរួមបញ្ចូលនូវអនុសាសន៍សិក្សាមួយចំនួនទាក់ទងនឹងការធ្វើសមាហរណកម្មសេដ្ឋកិច្ចសម្រាប់បណ្តាអង្គការ ដែលធ្វើការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងសកលលោកផងដែរ។

## ២. កម្មវត្ថុនៃការសិក្សា

គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង (Butterfly longitudinal Research Project) គឺជាគម្រោងសិក្សាស្រាវជ្រាវមួយដែលធ្វើការតាមដានជាបន្តបន្ទាប់ក្នុងរយៈពេលដប់ឆ្នាំ ទៅលើការធ្វើសមាហរណកម្មរបស់ជនរួចពីរងគ្រោះដោយការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះបានចាប់ផ្តើមនៅក្នុងឆ្នាំ ២០១០ ហើយឥឡូវនេះ បានបញ្ចប់រយៈពេលនៃឆ្នាំទីប្រាំមួយរបស់ខ្លួនហើយ។ គោលបំណងដ៏សំខាន់របស់គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង (BLR) គឺដើម្បីស្តាប់ពី "សំឡេង" ផ្ទាល់របស់ជនរួចពីរងគ្រោះ ហើយតាមរយៈការស្តាប់នេះ យើងទទួលបាននូវការយល់ដឹងពីទស្សនៈ និងបទពិសោធន៍របស់ពួកគេ ពេលដែលពួកគេបានសមាហរណកម្មចូលក្នុងសហគមន៍វិញ។

តាមរយៈការផ្សព្វផ្សាយនូវ "សំឡេង" របស់ពួកគេ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវទាំងនៅក្នុងស្រុក ក្នុងតំបន់ និងក្នុងសកលលោក អង្គការសម្ព័ន្ធចាប់ដៃជឿជាក់ថា កម្មវិធី និងគោលនយោបាយសមាហរណកម្ម នឹងទទួលបានព័ត៌មាន និងមានភាពរីវឌ្ឍន៍ទៅមុខ ដើម្បីធ្វើឲ្យជីវិតរបស់ជនរួចពីរងគ្រោះដោយការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទមានភាពល្អប្រសើរឡើង។ គោលបំណងនៃរបាយការណ៍សិក្សានេះ គឺដើម្បីលាតត្រដាងពីប្រធានបទដ៏សំខាន់បំផុតទាក់ទងនឹងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ និងការសងគុណឪពុកម្តាយក្នុងចំណោមជនរួចពីរងគ្រោះដោយការជួញដូរផ្លូវភេទ ក្រោយពេលពួកគេត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍វិញ (ឧទា. សហគមន៍កំណើតរបស់ពួកគេ ឬសហគមន៍ថ្មី ដែលជាសហគមន៍រស់នៅក្រៅពីកម្មវិធីជំនួយមណ្ឌលស្នាក់នៅ)។ ប្រធានបទរួមនោះត្រូវបានបែងចែងជាពីរផ្នែកសំខាន់ៗដើម្បីធ្វើការប្រៀបធៀបគ្នា៖ "មុនពេល" និង "ក្រោយពេល" ការធ្វើសមាហរណកម្ម ។ នៅក្នុងករណីមួយចំនួន ដែលជនរួចពីរងគ្រោះមិនមានព័ត៌មាននិយាយពីស្ថានភាព "មុនពេល" ការធ្វើសមាហរណកម្មឡើយ ដោយសារតែពួកគេបានធ្វើសមាហរណកម្មដោយផ្ទាល់ ឬភ្លាមៗ ក្រោយពេលពួកគេចេញពីស្ថានភាពកេងប្រវ័ញ្ច។

ដោយសារតែប្រធានបទទាំងនេះ មិនបានគេយកមកធ្វើការស្វែងយល់ឲ្យបានទូលំទូលាយនៅក្នុងការសិក្សាមុនៗទេ ដូច្នេះហើយគោលបំណងនៃឯកសារនេះ គឺសិក្សាផ្តោតទៅលើការស្វែងយល់ និងការវិភាគលើប្រធានបទតាមបែបគុណភាព និងបែបទូលំទូលាយ។ លើសពីនេះទៅទៀត ប្រធានបទត្រូវបានសាកសួរក្នុងលក្ខណៈនិយាយរៀបរាប់សាច់រឿងឡើងវិញ និងការសម្ភាសន៍បែបទម្រង់សំណួរបើក ហើយមានករណីតិចតួច ជនរួចពីរងគ្រោះត្រូវបានសាកសួរដោយចំៗ ដោយផ្ទាល់ ឬដោយសំណួរបិទ (បាទ/ចាស ឬទេ) ទាក់ទងនឹងប្រធានបទទាំងនេះ។ ផ្ទុយទៅវិញ ប្រធានបទទាំងនេះ បានលេចឡើង

តាមរយៈការសន្ទនាដែលជនរួចពីរងគ្រោះបាននិយាយដោយខ្លួនឯងស្ដីពីប្រធានបទទាំងនេះ និងតាមយៈការបង្ហាញពីក្ដីបារម្ភ ក្ដីភ័យខ្លាច និងភាពពិតជាក់ស្ដែង ដែលជាផ្នែកមួយនៃបទសម្ភាសន៍ដែលមានទម្រង់សំណួបើកជាក់លាក់ (semi-structured interviews) ហើយមិនមែនជាចម្លើយឆ្លើយតបនៅក្នុងកម្រងបញ្ជីសំណួរស្រាវជ្រាវឡើយ។ ដោយសារតែហេតុផលទាំងនេះ ការចាត់ថ្នាក់កំណត់លេខកូដទិន្នន័យ បានធ្វើការកត់ត្រាចម្លើយលើរយៈពេលនៃការសិក្សាទាំងមូលដោយផ្ដោតសំខាន់ទៅលើដំណើរការនៃការធ្វើសមាហរណកម្ម ជាជាងទៅលើស្ថានភាពមួយឆ្នាំៗ។

សូមកត់សំគាល់ថា ចំនួនដែលបានលើកឡើងនៅក្នុងផ្នែក "លទ្ធផលនៃការសិក្សា" ភាគច្រើន គឺជាចំនួនដែលបានរាប់នៅពេលណាដែលជនរួចពីរងគ្រោះបាននិយាយបង្ហាញពីប្រធានបទដោយផ្ទាល់ ឬក៏ជាផ្នែកមួយដែលមានបង្ហាញនៅក្នុងការធ្វើបទសម្ភាសន៍ទូទៅ និងមាននៅក្នុងបញ្ជីសំណួរ។ ឧទាហរណ៍ ជនរួចពីរងគ្រោះ អាចត្រូវបានសួរដោយផ្ទាល់ ថាតើពួកគេមានជំពាក់បំណុលគេដែរ ឬទេក្នុងពេលបច្ចុប្បន្ន ប៉ុន្តែវាមានការសន្ទនាទូលំទូលាយជាងនេះទៅទៀតស្ដីពីអារម្មណ៍ដែលពួកគេមានចំពោះបញ្ហាបំណុល និងការសងបំណុល ដែលជារឿយៗវាមានលក្ខណៈជាការសន្ទនាមិនផ្លូវការ និងមិនផ្អែកតាមបញ្ជីសំណួរនោះឡើយ។ ផ្ទុយទៅវិញ បើទោះបីជាជនរួចពីរងគ្រោះមិនបានបង្ហាញពីចំណុចជាក់លាក់ណាមួយនៃប្រធានបទទាំងនេះក៏ដោយ នោះវាក៏មិនមែនមានន័យថា ពួកគេមិនធ្លាប់ជួបប្រទះនូវបទពិសោធន៍ទាំងនេះទេ។

## ៣. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង (BLR) បានប្រើវិធីសាស្ត្រចម្រុះកាលពីប្រាំឆ្នាំមុន (សូមមើល Miles & Miles ២០១០; Miles & Miles 2011; Miles et al., 2012; Miles et al., 2013, Miles et al. 2014)។ ក្រុមអ្នកស្រាវជ្រាវបានប្រើឧបករណ៍ស្រាវជ្រាវ (បញ្ជីសំណួរ) ដែលមានសួរទាំងសំណួរបិទ និងសំណួរបើក។ ក្រុមអ្នកស្រាវជ្រាវនេះក៏បានប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យបែបគុណវិស័យមួយចំនួនផ្សេងៗទៀតដូចជា ការពិភាក្សាក្រុមគោលដៅ (FGD) ការសម្ភាសន៍បែបស៊ីជម្រៅ ការសម្ភាសន៍ក្រៅផ្លូវការ ការលេងល្បែងកម្សាន្ត គូសគំនូរ និងការសង្កេតទៅលើអ្នកចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវជាដើម។ ក្រៅពីនោះ ដើម្បីឲ្យនៅតែអាចបន្តការប្រមូលព័ត៌មានពីអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវដែលធ្វើចំណាកស្រុក (ឧទា. ចំណាកស្រុកទៅប្រទេសថៃ) ឬប្ដូរទីលំនៅទៅកាន់តំបន់ដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជា ក្រុមអ្នកស្រាវជ្រាវក៏បានធ្វើការសម្ភាសន៍តាមទូរសព្ទជាមួយពួកគេដែរ។ ការប្រើប្រាស់វិធីសាស្ត្រចម្រុះបែបនេះ បានធ្វើឲ្យក្រុមការងារគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង (BLR) ទទួលបាននូវព័ត៌មានដ៏ទូលំទូលាយស្ដីអំពីដំណើរជីវិតរបស់អ្នកចូលរួមនៅក្នុងការសិក្សា (ជនរួចពីរងគ្រោះ)។

នៅក្នុងឆ្នាំ ២០១៤ នៅពាក់កណ្ដាលនៃអាយុគម្រោងស្រាវជ្រាវរយៈពេលវែងនេះ ក្រុមអ្នកស្រាវជ្រាវបានធ្វើការវិភាគករណីសិក្សាមូលដ្ឋានគោលមួយ ដោយវិភាគទៅលើជីវិតរបស់អតិថិជនម្នាក់ៗ។ ទិន្នន័យទាំងបែបគុណវិស័យ និងបរិមាណវិស័យដែលប្រមូលបានជាងបួនឆ្នាំកន្លងមកនេះ ត្រូវបានចងក្រង និងសង្ខេបឡើងវិញនូវអ្វីដែលគម្រោងបានដឹង ដើម្បីរក្សាទុកជាឯកសារ ជៀសវាងការបាត់បង់សាច់រឿងរបស់អតិថិជនម្នាក់ៗ។ ការវិភាគករណីសិក្សានេះ បានវិភាគលម្អិតសង្ខេបបែបគុណវិស័យ "ទិន្នន័យសង្ខេបសាច់រឿងពិស្ដារ" របស់អតិថិជននីមួយៗនៅក្នុងគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង (BLR)។ ក្រៅពីទិន្នន័យសង្ខេបសាច់រឿងទាំងនេះ ការសិក្សាប៉ាន់ប្រមាណបែបគុណវិស័យ ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដើម្បីដាក់បញ្ចូលបន្ថែម ទៅក្នុងទិន្នន័យរយៈពេលវែងចំពោះអតិថិជនចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះភាគច្រើន។

## ៣.១ ទំហំ និងវិធីសាស្រ្តនៃការសិក្សាប៉ាន់ប្រមាណតាមប្រធានបទរួម

ការសិក្សាប៉ាន់ប្រមាណតាមប្រធានបទរួមនេះ បានទាញយកទិន្នន័យរបស់អ្នកចូលរួមការសិក្សាចេញពីកម្រងទិន្នន័យធំរបស់ក្រុមអ្នកចូលរួមសិក្សា ដែលគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែងបានប្រមូលទិន្នន័យរួចហើយ។ ការសិក្សាប៉ាន់ប្រមាណនេះ បានសិក្សាផ្តោតទៅលើតែក្រុមអតិថិជនដែលត្រូវបានធ្វើសមាហរណកម្មនៅចុងឆ្នាំ ២០១៤តែប៉ុណ្ណោះ ដែលមានចំនួនសរុប ៧៧នាក់។ ចំពោះទិន្នន័យទាំងអស់ដែលគម្រោងប្រមូលបាន គឺមានតែព័ត៌មាន/ទិន្នន័យនិយាយពីអតិថិជនទាំង៧៧នាក់នេះប៉ុណ្ណោះដែលត្រូវបានដាក់បញ្ចូលទៅក្នុងការវិភាគបែបប្រធានបទរួម។ ក្រុមអតិថិជនអាចត្រូវបានដាក់បញ្ចូលនៅក្នុងការសិក្សាប៉ាន់ប្រមាណនេះបាន លុះត្រាតែពួកគេបានចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវយ៉ាងហោចណាស់៤ជំនួប គិតជារយៈពេលស្មើនឹងពីរឆ្នាំស្ថិតក្នុងការសិក្សា។ អតិថិជនទាំងភេទប្រុស និងភេទស្រី ដែលត្រូវបានដាក់បញ្ចូលនៅក្នុងការសិក្សានេះ គឺជាក្រុមអ្នកធ្លាប់រស់នៅក្នុងកម្មវិធីមណ្ឌល ក្រុមអ្នកធ្លាប់ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងសហគមន៍ និងក្រុមអ្នកបដិសេធមិនទទួលយកជំនួយពីកម្មវិធី ឬអង្គការ។ ទិន្នន័យអំពីអតិថិជនចូលរួមនៅក្នុងការសិក្សាទាំង៧៧នាក់នេះ ត្រូវបានយកមកវិភាគទាំងព័ត៌មានពីមុនពេល និងក្រោយពេលការធ្វើសមាហរណកម្មរបស់ពួកគេ។

ប្រភេទខុសៗគ្នានៃវិធីសាស្រ្តប្រមូលទិន្នន័យនៅក្នុងការសិក្សាប៉ាន់ប្រមាណនេះមានដូចជា៖

១. ការសិក្សាប៉ាន់ប្រមាណ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ ២០១១ និង២០១២
២. ការពិភាក្សាក្រុមគោលដៅ (FGD) ដែលបានធ្វើឡើងនៅក្នុងឆ្នាំ ២០១២ និង២០១៥ និង
៣. ការសម្ភាសន៍បែបស៊ីជម្រៅ ដែលបានវាយជាអត្ថបទ និងទិន្នន័យសាច់រឿងសង្ខេបរបស់អតិថិជនម្នាក់ៗ ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥។

### *៣.១.១ ការសិក្សាប៉ាន់ប្រមាណ*

ការសិក្សាប៉ាន់ប្រមាណបែបបរិមាណវិស័យ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០១១ និង២០១២ ដែលជារយៈពេលដើមដំបូងនៃអាយុកាលរបស់គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង ។ ដោយហេតុនេះ លទ្ធផលនៃការសិក្សាភាគច្រើនពីការសិក្សាប៉ាន់ប្រមាណ គឺបានពីអតិថិជនដែលបានធ្វើសមាហរណកម្ម តាំងពីមុនពេលពួកគេត្រូវបានធ្វើសមាហរណកម្មទៅទៀត។ ខាងក្រោមនេះ គឺជាសំណួរនៃការស្ទង់មតិស្រាវជ្រាវមួយចំនួន ដែលត្រូវបានប្រើនៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ៖

### *៣.១.២ ការពិភាក្សាក្រុមគោលដៅ (FGD)*

បន្ថែមពីលើទិន្នន័យស្ទង់មតិ ការពិភាក្សាក្រុមគោលដៅ ត្រូវបានរៀបចំឡើង។ ការពិភាក្សាក្រុមគោលដៅដំបូង ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០១២ នៅក្នុងមណ្ឌល ហើយស្ថិតក្នុងប្រធានបទស្តីពី "ច្បាប់ស្រី"។ សំណួរមួយដែលបានពិភាក្សានៅក្នុងការពិភាក្សាក្រុមគោលដៅ (FGD) គឺ "តើកុមារក្រោមអាយុ១២ឆ្នាំ និងលើសពីអាយុ១២ឆ្នាំ អាចជួយផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេតាមរបៀបណាខ្លះ?" ការពិភាក្សាក្រុមគោលដៅទីពីរ ត្រូវបានធ្វើឡើងក្នុងកំឡុងពេលនៃការសិក្សាប៉ាន់ប្រមាណលើប្រធានបទ (ចុងឆ្នាំ ២០១៥) ក្នុងគោលបំណងប្រមូលព័ត៌មានឲ្យបានកាន់តែជាក់លាក់ថែមទៀតអំពីការសងគុណឪពុកម្តាយ។ ការពិភាក្សារបស់ក្រុមតូចគោលដៅ (FGD)ទាំងពីរ ដែលបានប្រើនៅក្នុងការសិក្សាប៉ាន់ប្រមាណ

នេះ ត្រូវបានធ្វើឡើងជាមួយក្រុមស្ត្រីដដែលនៅក្នុងអាជីវកម្មសង្គមនៃកម្មវិធីថៃទាំជំនួស ដែលភាគច្រើនជាអ្នកដែលបាន ចំណាយពេលក្រោមបួនខែនៅក្នុងមណ្ឌល មុនពេលត្រូវបានធ្វើសមាហរណកម្ម។

### ៣.១.៣ ការសម្ភាសន៍ និងទិន្នន័យសង្ខេបជាសាច់រឿង

នៅក្នុងការសិក្សាប៉ាន់ប្រមាណតាមប្រធានបទរួមទៅលើជនរួចពីរងគ្រោះទាំង៧៧នាក់នេះ អត្ថបទទាំងអស់ដែលសរសេរ ចេញពីឯកសារនៃបទសម្ភាសន៍ជាសំឡេង និងទិន្នន័យជាសាច់រឿងសង្ខេបទាំងមូលនៃការសម្ភាសន៍ និងការចុះប្រមូល ទិន្នន័យ ឬជំនួបជាមួយពួកគេនៅក្នុងកំឡុងពេលនៃសិក្សានេះ គឺត្រូវបានប្រើប្រាស់ ដើម្បីទាញយកព័ត៌មានភាគច្រើន សម្រាប់ការវិភាគប្រធានបទរួមបែបនេះ។ ទោះបីជាការសិក្សានេះមានដែនកំណត់នៃការសិក្សាដោយមិនរាប់បញ្ចូល អតិថិជនចូលរួមក្នុងការសិក្សា នៅត្រឹមចុងឆ្នាំ ២០១៤ ក៏ដោយ(ឧទា. អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ត្រូវបាន រាប់បញ្ចូល បើពួកគេត្រូវបានធ្វើសមាហរណកម្មនៅចុងឆ្នាំ ២០១៤) តែប្រសិនបើយើងមានទិន្នន័យរួចជាស្រេចស្តីអំពី អតិថិជនទាំងនេះស្តីពីពួកគេនៅក្នុងឆ្នាំ ២០១៥ នោះវាក៏ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងការវិភាគ។ នៅក្នុងចំណោម អតិថិជនចូលរួមការសិក្សាទាំង៧៧នាក់ ដែលបានកំពុងធ្វើសមាហរណកម្ម យើងមានទិន្នន័យសម្រាប់ឆ្នាំ ២០១៥ របស់ អតិថិជនចំនួន ២០នាក់រួចទៅហើយ។

ការវិភាគបួនដំណាក់កាលរបស់លោក អាឡែន ប្រីមែន ឆ្នាំ២០១២ (Alan Bryman, 2012) ត្រូវបានប្រើប្រាស់នៅក្នុង ការកំណត់លេខកូដនៃទិន្នន័យបែបគុណភាព។ វិធីសាស្ត្ររបស់លោក ប្រីមែន រួមមាន ការកំណត់លេខកូដ ឬការកំណត់ សន្ទស្សន៍នៃទិន្នន័យបែបគុណភាពចូលទៅក្នុងប្រភេទ ដែលនឹងតំណាងឲ្យស្ថានភាពដូចគ្នា (Gibbs, 2011)។ វត្ថុបំណង នៃការកំណត់លេខកូដទិន្នន័យនៅតាមផ្នែក មិនមែនដើម្បីរាប់ចំនួនដងនៃលេខកូដដែលមានឡើយ ប៉ុន្តែដើម្បីធ្វើការ បកស្រាយប្រភេទទៅតាមប្រធានបទ ដែលផ្តល់ព័ត៌មានអំពីការវិភាគនៃទិន្នន័យបែបគុណភាព។ ដំណាក់កាលទាំងបួននៃ ការវិភាគបែបគុណភាពរបស់លោក ប្រីមែន គឺ៖

១. អានអត្ថបទទាំងមូល។ កំណត់យកប្រធានបទសំខាន់បំផុត និងព្រឹត្តិការណ៍ខុសពីប្រក្រតី។ បែងចែក ករណីទៅតាមប្រភេទ អាស្រ័យលើសំណួរនៃការស្រាវជ្រាវ។

២. អានអត្ថបទម្តងទៀត គូសចំណាំលើអត្ថបទ សរសេរកំណត់ចំណាំនៅគែម និងបង្កើតស្លាកសញ្ញាសម្រាប់ កូដ ដែលទិន្នន័យនឹងត្រូវកំណត់សន្ទស្សន៍។

៣. កំណត់លេខកូដអត្ថបទ៖ បញ្ចូលជាប្រព័ន្ធលេខកូដនីមួយៗទៅក្នុងស្លាកសញ្ញានៃប្រធានបទ។ លុបបំបាត់ លេខដដែល ហើយគិតអំពីការដាក់លេខកូដជាក្រុម។

៤. ភ្ជាប់ទស្សនៈទ្រឹស្តីទូទៅជាមួយនឹងអត្ថបទ៖ ការកំណត់លេខកូដ គឺគ្រាន់តែជាផ្នែកដំបូងនៃការវិភាគបែប គុណភាពប៉ុណ្ណោះ ដូច្នេះ អ្នកវិភាគត្រូវធ្វើការបកស្រាយលេខកូដនៅពេលក្រោយ ដោយកំណត់ពីភាព ប្រទាក់គ្នារវាងលេខកូដ ហើយភ្ជាប់លេខកូដទៅនឹងសំណួរនៃការស្រាវជ្រាវ និងអត្ថបទដែលមានស្រាប់។

ប្រព័ន្ធនៃការកំណត់លេខកូដនៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ មានបញ្ចូលទាំងការបង្កើតជាផ្នែក ដោយផ្អែកលើប្រធាន បទធំៗ ដែលកើតចេញពីអំណានដំបូងនៃអត្ថបទសម្ភាសន៍។ ចំនួនដ៏ធំនៃផ្នែកកំណត់កូដ ត្រូវបានបង្កើតឡើង ដើម្បី ទទួលបានរូបភាពពេញលេញនៃការបង្ហាញ និងបទពិសោធន៍អំពីការសងគុណឪពុកម្តាយ និងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ។ ប្រធានបទទូទៅ ដែលបានពិភាក្សានៅក្នុងលទ្ធផលទាំងនេះ គឺជាការបង្ហាញចេញ និងបទពិសោធន៍អំពីការសងគុណ

ឪពុកម្តាយ បំណុល ក្តីបារម្ភផ្នែកហិរញ្ញវត្ថុ និងទិដ្ឋភាពខ្លះៗអំពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការងារ។ បន្ទាប់មក ការចាត់ថ្នាក់តាមផ្នែក ត្រូវបានបញ្ចូលព័ត៌មានថែមទៀត តាមរយៈការអានអត្ថបទសម្ភាសន៍បែបស៊ីជម្រៅជាលើកទីពីរ។ ប្រព័ន្ធនៃការកំណត់លេខកូដទិន្នន័យ បន្តតាមជានអាយុ និងភេទរបស់អតិថិជនចូលរួមក្នុងការសិក្សា ប៉ុន្តែដោយសារទំហំសំណាកជាទូទៅ មានទំហំតូចពេក ដូច្នេះ ការប្រៀបធៀបលើលក្ខខណ្ឌទាំងនេះ នៅមានកម្រិតនៅឡើយ។ ការសិក្សាប៉ាន់ប្រមាណនេះ ព្យាយាមស្វែងយល់ពីប្រធានបទសំខាន់ៗបំផុតទាក់ទងនឹងការសងគុណឪពុកម្តាយ និងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ ហើយការសិក្សានេះ មិនមានបំណងចង់ក្លាយជាការវិភាគបែបស្ថិតិនៅគ្រប់ប្រភេទនៃសំណាកឡើយ។

ប្រព័ន្ធកំណត់លេខកូដបែបគុណភាព ត្រូវបានបង្កើតមក ដើម្បីទាញយកពាក្យ គំនិត និងការចាត់ថ្នាក់តាមផ្នែកនៅក្នុងវិសាលភាពនៃការសិក្សាប៉ាន់ប្រមាណ។ លើសពីនេះទៅទៀត ប្រព័ន្ធនៃការកំណត់លេខកូដ បានបែងចែកចម្លើយ និងប្រធានបទចូលទៅក្នុងប្រអប់ចំណុចពីរផ្សេងគ្នា៖ "មុនពេលធ្វើសមាហរណកម្ម" (ខណៈពេលស្ថិតនៅក្នុងកម្មវិធីមណ្ឌលស្នាក់នៅ ឬមណ្ឌលស្នាក់នៅបណ្តោះអាសន្ន) និង "ក្រោយពេលធ្វើសមាហរណកម្ម" (ពេលចាកចេញពីមណ្ឌល ទៅរស់នៅក្នុងសហគមន៍)។ ចម្លើយរបស់អតិថិជន ដែលរស់នៅក្នុងកម្មវិធីមណ្ឌល ត្រូវបានចាត់ថ្នាក់ចូលក្នុងប្រភេទ "មុនពេលធ្វើសមាហរណកម្ម"។ ការធ្វើបែបនេះ ជួយឲ្យមានភាពងាយស្រួលក្នុងការធ្វើការប្រៀបធៀបរវាងប្រធានបទរួម សម្រាប់មុនពេល និងក្រោយពេលធ្វើសមាហរណកម្ម ហើយវាក៏អនុញ្ញាតឲ្យប្រធានបទធំៗលេចចេញមក ក្រោយពេលធ្វើសមាហរណកម្មត្រូវបានចាត់ថ្នាក់ផងដែរ។

ប្រធានបទសំខាន់ៗ រួមមានក្តីបារម្ភផ្នែកហិរញ្ញវត្ថុ ស្នេហា/អស្នេហាសេដ្ឋកិច្ច ការសងគុណឪពុកម្តាយ (រួមទាំងអារម្មណ៍ មានកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ) និងការរៀបចំផែនការសម្រាប់ថ្ងៃអនាគត។ ចំណុចទាំងអស់នេះ រួមបញ្ចូលទាំងការឆ្លើយតប គំនិត ទស្សនៈ និងបទពិសោធន៍របស់អតិថិជន ទាក់ទងនឹង "ក្តីបារម្ភ" (អំពីលុយ អំពីបំណុល អំពីអនាគត អំពីក្រុមគ្រួសារ) ការពេញចិត្តនឹងការងារ កាតព្វកិច្ចគ្រួសារ និងការគ្រប់គ្រងថវិកាជាដើម។

# ៤. លទ្ធផលនៃការសិក្សា និងការពិភាក្សា

## ៤ ១.ការកំណត់និយមន័យ

### *៤.១.១ ការធ្វើសមាហរណកម្មសេដ្ឋកិច្ច*

ការធ្វើសមាហរណកម្មសេដ្ឋកិច្ច គឺមានរួមបញ្ចូលទាំងទិដ្ឋភាពនានាស្តីពីការធ្វើសមាហរណកម្មជនរួចពីរងគ្រោះ ទាក់ទងនឹងសុខុមាលភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយវា គឺជាផ្នែកអាំងតេក្រាលមួយដ៏សំខាន់នៃដំណើរធ្វើសមាហរណកម្មពួកគេ។ វាមិនរួមបញ្ចូលគ្រាន់តែការងារ និងការប្រើប្រាស់ថវិកាតែមួយប៉ុណ្ណោះទេ ប៉ុន្តែវាក៏បញ្ចូលទាំងអាកប្បកិរិយា និងទំនាក់ទំនងរបស់ពួកគេជាមួយនឹងសេដ្ឋកិច្ច និងស្ថានភាពហិរញ្ញវត្ថុ ដោយរាប់បញ្ចូលទាំងជាលក្ខណៈបុគ្គល ក៏ដូចជាកត្តានៅជុំវិញផងដែរ (ឧទា. គ្រួសារ សហគមន៍ សង្គម)។ ឯកសារយោង (ការសិក្សាពីមុនៗ) បានយល់ស្របថា ជាតុដ៏សំខាន់មួយនៃការធ្វើសមាហរណកម្ម គឺជាការពង្រឹងអំណាចខាងផ្នែកសេដ្ឋកិច្ច៖

> ការពង្រឹងអំណាចខាងសេដ្ឋកិច្ច គឺជាប្រធានបទមួយដ៏សំខាន់បំផុត ដែលមាននូវចំណុចមួយចំនួនដូចខាងក្រោម៖ (១) ការកើនឡើងអក្ខរកម្មហិរញ្ញវត្ថុ ឬចំណេះដឹង និងជំនាញក្នុងការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ និងការទទួលបានធនធាន។ (២) ភាពប្រសើរឡើងនៅក្នុងការផ្គត់ផ្គង់ខ្លួនឯងខាងផ្នែកសេដ្ឋកិច្ច ឬជំនឿដែល

បុគ្គលម្នាក់មាននូវធនធាន ជម្រើស និងទំនុកចិត្ត ដើម្បីទទួលបានជោគជ័យ និង (៣) ការវិវឌ្ឍន៍ខ្លួនចំពោះការផ្គត់ផ្គង់ខ្លួនឯងខាងផ្នែកសេដ្ឋកិច្ច ឬឥរិយាបថខាងផ្នែកសេដ្ឋកិច្ច ដែលបង្ហាញពីការចេះផ្គត់ផ្គង់ខាងផ្នែកសេដ្ឋកិច្ច ឬអក្ខរកម្មខាងផ្នែកហិរញ្ញវត្ថុរបស់ពួកគេ ទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន (Postmus, 2012, p.1)។

លោក Surtees (2012) កំណត់អត្ថន័យនៃការពង្រឹងអំណាចខាងសេដ្ឋកិច្ចរបស់ជនរួចពីរងគ្រោះដោយសារការជួញដូរដូចខាងក្រោម៖

នៅក្នុងបរិបទនៃការធ្វើសមាហរណកម្ម ការពង្រឹងអំណាចផ្នែកសេដ្ឋកិច្ច គឺជាការដែលបុគ្គលត្រូវគេជួញដូរ ទទួលបានការបំពាក់បំប៉នជាមួយជំនាញ ធនធាន និងទំនុកចិត្ត ដើម្បីឲ្យពួកគេអាចមានសមត្ថភាពផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសាររបស់ពួកគេខាងផ្នែកសេដ្ឋកិច្ច ហើយនៅក្នុងរយៈពេលវែង ពួកគេអាចចូលរួមចំណែកជួយដល់សុខុមាលភាពសេដ្ឋកិច្ចសហគមន៍របស់ពួកគេផងដែរ (ទំព័រ ១១)។

## *៤.១.២ ការបេតស្នេងសងគុណឪពុកម្តាយ*

ជាសង្ខេប ការសងគុណ គឺជាជំនឿមួយ ដែលកូនត្រូវមានកាតព្វកិច្ចចំពោះឪពុកម្តាយរបស់ខ្លួន។ ការសងគុណ ត្រូវបានបង្ហាញចេញតាមរបៀបខុសៗគ្នាតាមបរិបទសង្គមនីមួយៗ ប៉ុន្តែជំនឿនេះ ត្រូវបានឲ្យតម្លៃយ៉ាងខ្លាំងនៅក្នុងវប្បធម៌អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍។ លោក Lewis (2005) ពន្យល់ថា៖

ការសងគុណ ពាក់ព័ន្ធនឹងទំនាក់ទំនងតាមឋានៈទៅតាមជំនាន់ជាមួយជីដូនជីតា ការគោរពសក្ការៈ ការគោរព ការស្តាប់បង្គាប់ និងការលុតជង្គង់គោរព ស្របតាមអាយុ និងភេទ។ វាបង្គាប់ចេញនូវកាតព្វកិច្ច និងបំណុលដែលមានចំពោះចាស់ទុំរបស់ខ្លួន ហើយវាសង្កត់ន័យយ៉ាងខ្លាំងទៅលើសាច់ញាតិបងប្អូន ដែលរស់នៅក្នុងគ្រួសារធំមានច្រើនជំនាន់រស់នៅក្រោមដំបូលផ្ទះតែមួយ។ ការសងគុណឲ្យតម្លៃលើមនុស្សចាស់ ជាពិសេស បុរស នៅក្នុងឋានៈឯកសិទ្ធិខ្ពស់ជាងសមាជិកគ្រួសារដែលក្មេងជាង។ តាមពិតទៅ ការសងគុណរក្សានូវតំណភ្ជាប់ខាងអារម្មណ៍រវាងការចងចាំនឹងភាពពិតឆ្លងជំនាន់ ជាមាគ៌ាឆ្ពោះទៅរកការបន្តជំនឿនៃវប្បធម៌ និងជំនាន់។ លើសពីនេះទៅទៀត ការសងគុណ ផ្តល់នូវច្បាប់ និងវិន័យ សម្រាប់ការស្តាប់បង្គាប់ ការអប់រំ ការប្រៀនប្រដៅ និងអំណាច (Liem, 1998 & Detzner, 2004, ដូចបានលើកឡើងនៅក្នុង Lewis, 2005, ទំព័រទី៦)។

## *៤.១.៣ ក្តីបារម្ភផ្នែកហិរញ្ញវត្ថុ*

និយមន័យនៃពាក្យ "ក្តីបារម្ភផ្នែកហិរញ្ញវត្ថុ" បានត្រូវបានបង្កើតឡើងជាចម្បងនៅក្នុងការសិក្សាស្រាវជ្រាវអំពីបទពិសោធន៍របស់សិស្សទៅលើប្រាក់កម្ចីសិស្ស និងសម្ពាធខាងផ្នែកហិរញ្ញវត្ថុទាក់ទងនឹងការអប់រំ។ ការស្រាវជ្រាវ ត្រូវបានពិភាក្សាលើសពីនេះនៅក្នុងផ្នែករំលឹកនៃការសិក្សាស្រាវជ្រាវពីមុនៗខាងក្រោម។ នៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ បានកំណត់និយមន័យ "ក្តីបារម្ភផ្នែកហិរញ្ញវត្ថុ" ដែលអាចត្រូវបានពិពណ៌នាថា "ជាអារម្មណ៍ព្រួយ ឬបារម្ភអំពីស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលម្នាក់"។ (Archuleta, Dale & Spann, 2013, p58)។ លើសពីនេះ "ភាពតានតឹងផ្នែកសេដ្ឋកិច្ច គឺជាអារម្មណ៍តានតឹង ដោយសារតែស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្នរបស់ខ្លួន និង/ឬដោយសារតែភាពភ័យខ្លាចអំពីបញ្ហាសេដ្ឋកិច្ច" (Brown University, n.d.)។

## ៤ ២.ការបំពេញកាតព្វកិច្ចគ្រួសារ គឺជាការបង្ហាញការសងគុណ

អ្នកចូលរួមនៅក្នុងការសិក្សាបានបង្ហាញពីប្រធានបទនៃការសងគុណ ហើយបើសួរដោយផ្ទាល់ ពួកគេបាននិយាយថា ភារកិច្ចដែលពួកគេមានចំពោះឪពុកម្តាយរបស់ខ្លួន គឺជាការគោរព ជាជាងការសងបំណុល។ ជារឿយៗ អតិថិជនចូលរួមក្នុងការសិក្សា មានអារម្មណ៍ភ័យព្រួយ ដោយសារតែក្តីបារម្ភ ដែលពួកគេមានអំពីជីវភាពគ្រួសារ និងទំនួលខុសត្រូវដែលពួកគេត្រូវផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួន។

### *៤.២.១ ក្តីបារម្ភ និងទំនួលខុសត្រូវ*

អារម្មណ៍អំពីក្តីបារម្ភ និងទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះឪពុកម្តាយ ឬគ្រួសាររបស់ខ្លួន ជារឿយៗ មានភាពពាក់ព័ន្ធគ្នា។ ចំនួនអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ដែលបានបង្ហាញថាចង់ផ្ញើលុយទៅកាន់ឪពុកម្តាយរបស់ពួកគេ ត្រូវបានបញ្ចូលនូវលទ្ធផលខាងក្រោម ដែលជាសូចនាករ មិនមែនជាការផ្គត់ផ្គង់ហិរញ្ញវត្ថុពិតប្រាកដឡើយ ប៉ុន្តែវាជាការបង្ហាញការសងគុណ នៃអារម្មណ៍ទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះឪពុកម្តាយរបស់ខ្លួន។ ប្រយោគអំពីការផ្ញើលុយទៅកាន់ឪពុកម្តាយរបស់ខ្លួន ជារឿយៗ ត្រូវបានបូកបញ្ចូលជាមួយប្រយោគអំពីទំនួលខុសត្រូវរបស់ខ្លួនដែលត្រូវធ្វើ។ ឧទាហរណ៍ អតិថិជនម្នាក់ដែលបានផ្ញើប្រាក់ខែពាក់កណ្តាលរបស់ខ្លួនទៅឲ្យឪពុកម្តាយរបស់នាងជារៀងរាល់ខែ បានបង្ហាញនៅក្នុងប្រយោគដូចគ្នាថា នាងមានក្តីបារម្ភអំពីគ្រួសាររបស់នាង នាងស្រឡាញ់ឪពុកម្តាយរបស់នាងខ្លាំងណាស់ នាងយល់អំពីតម្រូវការគ្រួសាររបស់នាង ហើយនាងមានអារម្មណ៍ថា នាងមានទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ដល់គ្រួសាររបស់នាង។ អតិថិជនម្នាក់ទៀតដែលមិនអាចផ្ញើលុយទៅកាន់ក្រុមគ្រួសាររបស់នាង (ជីតារបស់នាង គឺជាអាណាព្យាបាលរបស់នាងបន្ទាប់ពីម្តាយរបស់នាងបានស្លាប់ទៅ) ដោយសារតែនាងស្ថិតនៅក្នុងមណ្ឌល ហើយមិនអាចរកលុយបាន បានបង្ហាញពីអារម្មណ៍ពិរុទ្ធភាពយ៉ាងខ្លាំង ដែលខ្លួនមិនអាចផ្ញើលុយបាន។ នាងបាននិយាយថា "ជីតារបស់ខ្ញុំឈឺ ដោយសារតែជំងឺលើសឈាម...ខ្ញុំមិនអាចផ្តោតអារម្មណ៍ ឬគិតអំពីអ្វីបានឡើយ ដោយសារតែខ្ញុំមិនអាចជួយគាត់បាន។"

| បាននិយាយថា ពួកគេផ្ញើលុយទៅឪពុកម្តាយ | បាននិយាយថា ពួកគេប្រាថ្នាចង់ផ្ញើលុយ ប៉ុន្តែ ពួកគេមិនអាចផ្ញើបាន | ចំនួនសរុប | ភាគរយនៃមនុស្សដែលបានធ្វើសមាហរណកម្មសរុប |
|---|---|---|---|
| ៤៧ | ៥ | ៥២ | ៦៧,៥% |

តារាង 1៖ ការផ្ញើលុយទៅឪពុកម្តាយ/គ្រួសារ (ចំនួន=៧៧នាក់)

សំណុំនៃសូចនាករទីពីរ រួមមានការបង្ហាញ ឬប្រយោគនៃអារម្មណ៍ទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះគ្រួសាររបស់ខ្លួន។ អារម្មណ៍ ឬប្រយោគទាំងនេះ ត្រូវបានរាប់បញ្ចូល បើវាមានលក្ខណៈដាច់ឡែក ឬបន្ថែមទៅក្នុងប្រយោគដោយផ្ទាល់អំពីការផ្ញើលុយទៅកាន់ឪពុកម្តាយរបស់ខ្លួន។

| ការបង្ហាញ ឬប្រយោគនៃអារម្មណ៍នៃការទទួលខុសត្រូវ | ចំនួននៃជនរួចពីរងគ្រោះ ដែលបានបង្ហាញពីប្រធានបទនេះ | ភាគរយនៃជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្មសរុប |
|---|---|---|
| មើលថែបងប្អូនបង្កើតរបស់ខ្លួន | ១៧ | ២២,១% |
| ផ្គត់ផ្គង់ ឬចិញ្ចឹមគ្រួសារ | ៣៣ | ៤២,៣% |

តារាង 2៖ អារម្មណ៍អំពីទំនួលខុសត្រូវចំពោះគ្រួសារ (ចំនួន=៧៧នាក់)

ជារឿយៗ អតិថិជនមានអារម្មណ៍ខ្វល់ខ្វាយអំពីប្អូនៗរបស់ពួកគេ ដែលជាផ្នែកមួយនៃក្តីបារម្ភដ៏ពិតអំពីជីវភាពឪពុកម្តាយរបស់ពួកគេ។ មានអតិថិជនម្នាក់លើកឡើងថា "ខ្ញុំមានអារម្មណ៍ថា ខ្ញុំមានសម្ពាធយ៉ាងខ្លាំង ហើយឥឡូវ ខ្ញុំកំពុងតែគិតចង់ស្វែងរកការងារពេលយប់។" (តើការងារអ្វីទៅ?) "ខ្ញុំមិនទាន់ដឹងច្បាស់នៅឡើយ ឥឡូវនេះ។ វាគ្រាន់តែជាគម្រោងរបស់ខ្ញុំប៉ុណ្ណោះ ដោយសារតែខ្ញុំចង់ជួយដល់គ្រួសារ និងប្អូនៗរបស់ខ្ញុំ"។ ប្រយោគមួយទៀត គឺជាការបង្ហាញអារម្មណ៍ទូទៅអំពីការចង់ផ្គត់ផ្គង់ ឬចិញ្ចឹមគ្រួសាររបស់ខ្លួន។ ជារឿយៗ ចំណុចនេះត្រូវបានបង្ហាញនៅក្នុងបំណងចិត្តចង់ដេញតាមឱកាសសិក្សា ឬឱកាសការងារដែលមានលក្ខណៈកាន់តែប្រសើរ ដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួនកាន់តែប្រសើរក្នុងពេលអនាគត ដែលអតិថិជនម្នាក់បាននិយាយថា "ខ្ញុំចង់សិក្សា និងរៀនឲ្យចប់សាកលវិទ្យាល័យ ដើម្បីឲ្យខ្ញុំអាចមានចំណេះដឹងខ្ពស់ ហើយធ្វើការចិញ្ចឹមម្តាយរបស់ខ្ញុំបាន"។

អារម្មណ៍នៃទំនួលខុសត្រូវ និងការផ្តល់ប្រាក់ឧបត្ថម្ភ ដែលបានពិភាក្សានៅខាងលើ ជារឿយៗ ផ្តោតទៅលើអារម្មណ៍នៃការព្រួយបារម្ភសម្រាប់ជីវភាពគ្រួសាររបស់ខ្លួន។ អតិថិជនមានក្តីព្រួយបារម្ភយ៉ាងខ្លាំង ជានិច្ចកាល និងជាទៀងទាត់ ក្នុងរយៈពេលជាច្រើនឆ្នាំ ហើយក្តីបារម្ភដ៏ធំបំផុតមួយរបស់ពួកគេ គឺជាការរស់នៅរបស់ក្រុមគ្រួសាររបស់ពួកគេ។ ដូចបានឃើញខាងក្រោម ៤២%នៃចំនួនអតិថិជន បានបង្ហាញក្តីបារម្ភចំពោះជីវភាពគ្រួសាររបស់ពួកគេ យ៉ាងហោចណាស់ម្តងនៅក្នុងរយៈពេលនៃការសិក្សា។

| ចំនួននៃជនរួចពីរងគ្រោះ ដែលបានបង្ហាញក្តីព្រួយបារម្ភ ឬក្តីកង្វល់ ទាក់ទងនឹងជីវភាពគ្រួសារ | ភាគរយនៃជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្មសរុប |
|---|---|
| ៣៥ | ៤២,៦% |

**តារាង 3៖ ក្តីបារម្ភអំពីជីវភាពគ្រួសារ**

ប្រយោគនៅក្នុងតារាងខាងក្រោម បង្ហាញពីអារម្មណ៍នៃទំនួលខុសត្រូវ និងក្តីបារម្ភ ដែលអតិថិជនមានចំពោះឪពុកម្តាយរបស់ពួកគេ និងបំណងចិត្តចង់ផ្គត់ផ្គង់ដល់ពួកគេ។

| *ប្រយោគទាក់ទងនឹងក្តីបារម្ភ និងទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ដល់ឪពុកម្តាយ/គ្រួសាររបស់ខ្លួន* |
|---|
| "អ្វីដែលខ្ញុំបារម្ភបំផុតនោះ គឺបញ្ហាថវិកា និងម្តាយរបស់ខ្ញុំ។" |
| "ខ្ញុំចង់ធ្វើការ និងមានប្រាក់ខែល្មមសមរម្យ ដើម្បីឲ្យខ្ញុំអាច...ជួយដល់គ្រួសាររបស់ខ្ញុំ ក្នុងពេលដែលខ្ញុំផ្គត់ផ្គង់ខ្លួនឯង។" |
| "ខ្ញុំធ្វើការ ហើយខ្ញុំចង់ត្រលប់ទៅរស់នៅជាមួយម្តាយរបស់ខ្ញុំវិញ ដោយសារតែខ្ញុំចង់មើលថែគាត់។" |
| "ខ្ញុំចង់សិក្សាឲ្យបានចប់សព្វគ្រប់ ដោយសារតែខ្ញុំគិតថា បើខ្ញុំរៀនចប់វិទ្យាល័យ នោះខ្ញុំអាចរកបានការងារមួយ ហើយអាចរកប្រាក់ជួយផ្គត់ផ្គង់ម្តាយ និងគ្រួសាររបស់ខ្ញុំ។" |
| "ខ្ញុំមិនដែលមានអារម្មណ៍ធុញថប់ក្នុងការធ្វើការ ដើម្បីជួយដល់គ្រួសាររបស់ខ្ញុំឡើយ។ ខ្ញុំរីករាយដែលខ្ញុំអាចផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្ញុំបាន។" |
| "ខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវទទួលខុសត្រូវចំពោះគ្រួសាររបស់ខ្ញុំ។ ពេលដែលខ្ញុំបារម្ភ ឬមានបញ្ហា ខ្ញុំមិនដឹងជានិយាយជាមួយនរណាឡើយ។" |
| "ខ្ញុំតែងតែគិតអំពីចំនួនលុយ ដែលខ្ញុំគួរតែផ្គត់ផ្គង់ដល់ម្តាយរបស់ខ្ញុំ ចំនួនលុយដែលខ្ញុំនឹងសងបំណុល ឬរបស់របរ ដែលខ្ញុំគួរតែទិញសម្រាប់ម្តាយរបស់ខ្ញុំ និងសម្រាប់ខ្លួនឯង?" |
| "ខ្ញុំបារម្ភយ៉ាងខ្លាំងអំពីបំណុលរបស់គាត់ ហើយខ្ញុំត្រូវតែធ្វើការ ដើម្បីសងបំណុលម្តាយរបស់ខ្ញុំ។" |

**តារាង 4៖ ប្រយោគទាក់ទងនឹងក្តីបារម្ភ និងទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ដល់ឪពុកម្តាយ និងក្រុមគ្រួសារ**

កូនច្បង ជាពិសេសបើសិនជាកូនស្រី អាចមានអារម្មណ៍ទទួលបន្ទុកយ៉ាងខ្លាំងក្នុងការផ្គត់ផ្គង់គ្រួសារ។ អតិថិជនម្នាក់ ដែលជាកូនច្បងនៃគ្រួសារដែលមានបងប្អូនចំនួនប្រាំបួននាក់ បាននិយាយអំពីការនេះ នៅពេលដែលនាងធ្វើសមាហរណកម្មចេញពីកម្មវិធីមណ្ឌលស្នាក់នៅទៅរស់នៅជាមួយគ្រួសាររបស់នាង៖ នាងព្រួយបារម្ភច្រើន ពីព្រោះគ្រួសាររបស់នាងមានបញ្ហាហិរញ្ញវត្ថុ ដោយសារមានតែឪពុកម្តាយរបស់នាងប៉ុណ្ណោះ ដែលធ្វើការ ដើម្បីចិញ្ចឹមគ្រួសារ។ នាងចង់ធ្វើការ ដើម្បីជួយដោះបំណុលរបស់ពួកគេ ប៉ុន្តែនាងក៏ចង់បន្តការសិក្សារបស់នាងផងដែរ ទោះបីជានាងមិនដឹងថា វាអាចទៅរួចតាមរបៀបណាក៏ដោយ ដោយសារតែមធ្យោបាយដែលអាចធ្វើបាននៅមានកម្រិតនៅឡើយចំពោះនាង។ នាងតែងតែមានអារម្មណ៍ពិរុទ្ធភាព និងអារម្មណ៍ចង់ឈប់រៀនភ្លាមៗ ដើម្បីចេញទៅរកលុយសម្រាប់ជួយគ្រួសារនាង។

លំដាប់លំដោយនៃកំណើតនៅក្នុងគ្រួសាររបស់អតិថិជន ត្រូវបានកត់ត្រាចំពោះករណីស្រ្តីចំនួន៣២នាក់។ មាន២០នាក់ក្នុងចំណោមស្រ្តី ៣២ករណីនោះ មាន(៦២,៥%) គឺជាកូនច្បង កូនស្រីច្បង ឬកូនស្រីច្បងតែមួយ។ ការនេះអាចបង្ហាញពីស្ថានភាពជីវភាពថា កូនស្រីច្បង ត្រូវបានរំពឹងទុក ឬមានអារម្មណ៍ពីទំនួលខុសត្រូវកាន់តែច្រើន ដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេទាំងនៅវ័យក្មេង។ ចំណុចនេះត្រូវបានបញ្ជាក់ តាមរយៈប្រយោគផ្សេងៗជាច្រើន ដែលអតិថិជនជាស្រ្តីបានលើកឡើង។ មានអតិថិជនម្នាក់ ដែលបាននិយាយពីក្តីបារម្ភអំពីគ្រួសាររបស់នាង ហើយជារឿយៗ នាងផ្ញើលុយទៅកាន់ពួកគេ ព្រោះវាជាទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ពួកគេ ក្នុងនាមជាកូនច្បងនៅក្នុងគ្រួសារ។ ជនរួចពីរងគ្រោះម្នាក់ទៀត ពេលដែលនាងត្រូវបានក្រុមស្រាវជ្រាវសួរថា "តើនាងមានអារម្មណ៍ "តូចចិត្ត" ដែរឬទេ ដែលមានភារកិច្ចដ៏ធំបែបនេះក្នុងការជួយដល់គ្រួសាររបស់នាង"។ នាងបានឆ្លើយថា "ខ្ញុំមិនតូចចិត្តឡើយ។ ខ្ញុំគិតថា វាជារឿងធម្មតាទេ ដែលកូនច្បងត្រូវតែធ្វើនៅក្នុងគ្រួសារ។"

ជនរួចពីរងគ្រោះក៏ផ្អាកផែនការអនាគត ឬផែនការសម្រាប់ខ្លួនឯង ដើម្បីជួយ និងផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេ។ ការនេះជារឿយៗ ត្រូវបានបង្ហាញនៅក្នុងការពន្យាពេលក្នុងការសិក្សា ឱកាសការងារ និងការរៀបអាពាហ៍ពិពាហ៍ជាដើម។ ប្រយោគខ្លះ ទាក់ទងនឹងប្រធានបទនេះ មាននៅក្នុងតារាងខាងក្រោម៖

| |
|---|
| *ប្រយោគទាក់ទងនឹងការពន្យាពេលផែនការអនាគត* |
| "ខ្ញុំមិនទាន់មានផែនការណាមួយនៅឡើយទេ ហើយខ្ញុំមិនដឹងជាត្រូវធ្វើអ្វីដែរ ដោយសារតែខ្ញុំគិតច្រើនអំពីគ្រួសាររបស់ខ្ញុំ ហើយខ្ញុំមានទំនួលខុសត្រូវជាច្រើនសម្រាប់គ្រួសារខ្ញុំ។" |
| [ក្រោយពេលបដិសេធសំណើសុំរៀបការ] "ខ្ញុំមិនខ្វល់អំពី [ការមានគ្រួសារផ្ទាល់ខ្លួនឡើយ] ដោយសារតែខ្ញុំនៅតែចង់រស់នៅជាមួយគ្រួសារខ្ញុំ និងជួយផ្គត់ផ្គង់ដល់ពួកគាត់។" |
| "ខ្ញុំគិតថា ក្នុងពេលអនាគត ខ្ញុំនឹងរៀបការ ហើយប្តូរទៅរស់នៅជាមួយប្តីរបស់ខ្ញុំ ប៉ុន្តែ តើនរណានឹងផ្គត់ផ្គង់ [គ្រួសាររបស់ខ្ញុំ] ទៅ? [...] បើខ្ញុំរៀបការ តើនរណានឹងផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្ញុំទៅ?" |

**តារាង 5៖ ប្រយោគទាក់ទងនឹងការផ្អាកផែនការអនាគត**

លើសពីនេះទៅទៀត ជនរួចពីរងគ្រោះជាច្រើននាក់ បាននិយាយផែនការអនាគតរបស់ពួកគេ រួមមានដូចជាការរស់នៅជុំជាមួយឪពុកម្តាយរបស់ពួកគេ ការផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេ និងបំណងចិត្តចង់មានទំនាក់ទំនងល្អជាមួយគ្រួសាររបស់ពួកគេជាដើម។

| *ប្រយោគទាក់ទងនឹងបំណងចិត្តសម្រាប់ថ្ងៃអនាគត* |
|---|
| "ខ្ញុំចង់ឲ្យឪពុកម្តាយរបស់ខ្ញុំរើមករស់នៅជាមួយខ្ញុំក្នុងទីក្រុងភ្នំពេញ... ខ្ញុំប្រាថ្នាថា គ្រួសាររបស់ខ្ញុំ នឹងស្រឡាញ់គ្នាទៅវិញទៅមកជារៀងរហូត។" |
| "ខ្ញុំចង់ទិញផ្ទះមួយ ហើយនាំគ្រួសាររបស់ខ្ញុំមករស់នៅជាមួយខ្ញុំក្នុងផ្ទះនោះ។" |
| "ជាដំបូង ខ្ញុំនឹងសន្សំប្រាក់ ហើយបើអាច បើខ្ញុំមានលុយច្រើន ខ្ញុំនឹងជួយម្តាយរបស់ខ្ញុំ... ហើយទិញផ្ទះមួយសម្រាប់ម្តាយរបស់ខ្ញុំ។ ខ្ញុំចង់រស់នៅជាមួយម្តាយរបស់ខ្ញុំ។ ខ្ញុំមិនចង់រស់នៅឆ្ងាយពីម្តាយរបស់ខ្ញុំឡើយ។" |

**តារាង 6៖ ប្រយោគទាក់ទងនឹងបំណងចិត្តសម្រាប់ថ្ងៃអនាគត**

### *៤.២.២ កិត្តិយស និងការសងគុណ*

នៅពេលដែលជនរួចពីរងគ្រោះត្រូវបានសួរដោយផ្ទាល់ស្តីអំពី "ការជំពាក់គុណរបស់ឪពុកម្តាយ" អតិថិជនមិនបានយល់ឃើញក្នុងន័យ(ការជំពាក់បំណុល) ជាអវិជ្ជមានឡើយ ប៉ុន្តែ គាត់ចង់ពន្យល់វាក្នុងន័យជាការគោរព ជាទំនួលខុសត្រូវ (វិជ្ជមាន) និងការសងគុណចំពោះឪពុកម្តាយរបស់ពួកគេវិញ។ អតិថិជនម្នាក់បានពណ៌នាពីអារម្មណ៍ប៉ះទង្គិចទាំងនេះយ៉ាងដូច្នេះថា៖ "តាមពិតទៅ ទំនួលខុសត្រូវ (អ្នក) អាចចាត់ទុកវាថាជាបន្ទុក ឬមិនមែនជាបន្ទុក។ វាមិនសំខាន់ឡើយបើយើងមិនធ្វើវា ប៉ុន្តែវាទាក់ទងជាមួយចិត្តសប្បុរស និងចិត្តកតញ្ញូរបស់យើងចំពោះឪពុកម្តាយ និងគ្រួសាររបស់យើងប៉ុណ្ណោះ។ ក្នុងនាមយើងជាសមាជិកក្នុងគ្រួសារ យើងមិនអាចឈរមើលពួកគាត់ប្រឈមមុខនឹងទុក្ខលំបាកបានឡើយ។ ដូច្នេះ បើយើងអាចជួយបាន យើងគួរតែជួយតាមតែយើងអាចធ្វើទៅបាន" (អតិថិជនចូលរួមជាស្ត្រីរបស់គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង(BLR) បាននិយាយអំពីអ្វីដែលនាងជំពាក់ឪពុកម្តាយរបស់នាង)។

ពេលខ្លះ នៅក្នុងបទសម្ភាសន៍ក្រៅផ្លូវការ អតិថិជនបាននិយាយអំពីចិត្តកតញ្ញូ នៅពេលដែលនិយាយអំពីទំនួលខុសត្រូវ ឬអារម្មណ៍របស់ពួកគេចំពោះឪពុកម្តាយរបស់ពួកគាត់។ អតិថិជនម្នាក់បានបង្ហាញពីការសងគុណជាទៀងទាត់នៅក្នុងប្រយោគរបស់នាងចំពោះកូនប្រុសរបស់នាង ដែលបានចូលរួមនៅក្នុងក្រុមជើងកាង និងបានប្រើប្រាស់គ្រឿងញៀន ដោយសួរគាត់ថា "តើនេះជាការសងគុណរបស់កូនចំពោះម៉ាក់ និងតាយាយរបស់កូនឬ?" ជនរួចពីរងគ្រោះម្នាក់ទៀត បានពន្យល់ពីអារម្មណ៍ទំនួលខុសត្រូវរបស់នាងក្នុងការសងបំណុលឪពុកម្តាយរបស់នាង ដោយនិយាយថា នាងចាត់ទុកការសងបំណុលនេះជា "ចិត្តកតញ្ញូ" របស់នាង។ ន័យម្យ៉ាងទៀតនៃ "ការសងគុណ" មាននៅក្នុងតារាងខាងក្រោម៖

| *ការសំដែង "ការសងគុណ" ដោយជនរួចពីរងគ្រោះបានលើកឡើង* |
| --- |
| "ឪពុកម្តាយរបស់ខ្ញុំមានអារម្មណ៍មោទនភាពចំពោះ [ខ្ញុំ]… ខ្ញុំមានអារម្មណ៍ថា ឪពុកម្តាយរបស់ខ្ញុំ គឺជាមនុស្សល្អ ហើយពួកគាត់តែងតែលើកទឹកចិត្តខ្ញុំ ដូច្នេះ ខ្ញុំពិតជាអរគុណដល់ពួកគាត់យ៉ាងខ្លាំងដែលបានផ្តល់កំណើតដល់ខ្ញុំ និងផ្តល់ជីវិតដល់ខ្ញុំ។" |
| "[បងប្រុសរបស់ខ្ញុំ] តែងតែធ្វើការនេះ (រកលុយ)។ ពេលដែលម៉ាក់ខ្ញុំអាចរកលុយបាន គាត់បានជួយកូនៗរបស់គាត់ ហើយឥឡូវ វាដល់ពេលដែលពួកយើងជួយគាត់វិញម្តងហើយ។" |
| "ខ្ញុំមានសង្សារម្នាក់ ប៉ុន្តែ ខ្ញុំមិនទាន់ចង់រៀបការ ឬចង់មានកូនឡើយ ដោយសារតែខ្ញុំចង់រកលុយជួយដល់គ្រួសាររបស់ខ្ញុំជាមុនសិន និងដើម្បី "សងគុណឪពុកម្តាយខ្ញុំ"។" |
| "ខ្ញុំគិតច្រើន ពេលដែលខ្ញុំមានកូន ខ្ញុំចង់ឲ្យពួកគេចេះគោរពចាស់ទុំ។ ពួកគេគួរតែចេះជួយចាស់ទុំ ពេលដែលចាស់ទុំរបស់ពួកគេជួបការលំបាក…ខ្ញុំចង់ឲ្យពួកគេក្លាយជាមនុស្សល្អ ចេះគោរពចាស់ទុំ និងនិយាយពាក្យសំដីទន់ភ្លន់។" |
| [ទាក់ទងការមានទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុច្រើនពេកនៅក្នុងគ្រួសារ] "ខ្ញុំមានអារម្មណ៍ពិបាក និងហត់នឿយ ប៉ុន្តែឥឡូវវាក្លាយជាទម្លាប់ និងភារកិច្ចរបស់ខ្ញុំ ដែលខ្ញុំត្រូវផ្តល់ជូនដល់ម្តាយរបស់ខ្ញុំ។" |

**តារាង 7៖ ការបង្ហាញអំពីការសងគុណរបស់ជនរួចពីរងគ្រោះ**

មានអតិថិជនប្រាំពីរនាក់បានបង្ហាញនូវសូចនាករមួយទាក់ទងទាំង "ទំនួលខុសត្រូវ និងកិត្តិយសគ្រួសារ"៖ ពួកគេបានបង្ហាញថា ការលះបង់ឲ្យគេបំពានផ្លូវភេទ គឺជាការមួយដែលពួកគេស្ម័គ្រចិត្តទទួលយក ដោយសារតែពួកគេត្រូវតែធ្វើដើម្បីជាប្រយោជន៍គ្រួសាររបស់ពួកគេ។ ចំណុចនេះក៏ត្រូវបានរកឃើញដែរ នៅក្នុងចំណោមអ្នករកស៊ីផ្លូវភេទជនជាតិវៀតណាមក្នុងការសិក្សា របស់ Busza's (2004)៖ "ម្តាយរបស់ខ្ញុំបានយំយ៉ាងខ្លាំង ពេលដែលគាត់បានដឹងថា [ខ្ញុំជាអ្នករកស៊ីផ្លូវភេទ]។ ខ្ញុំបានប្រាប់គាត់មិនឲ្យយំ ដោយសារតែខ្ញុំស្ម័គ្រចិត្តធ្វើវា ហើយខ្ញុំមិនមានអារម្មណ៍អាក្រក់អំពីវាឡើយ" (ទំព័រ ២៤១)។

ជនរួចពីរងគ្រោះនៅក្នុងការសិក្សានេះ ក៏បានលើកឡើងនូវប្រយោគស្រដៀងគ្នាផងដែរ ដូចជា ជនរួចពីរងគ្រោះម្នាក់បានបញ្ជាក់យ៉ាងច្បាស់ថា នាងមិនដែលសោកស្តាយឡើយសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទរបស់នាង ដ្បិតនាងបានលះបង់ខ្លួននាង ដើម្បីឲ្យគ្រួសាររបស់នាងមាន "អនាគត" ល្អ។ អតិថិជនម្នាក់ទៀត ដែលម្តាយរបស់នាងបានលក់ព្រហ្មចារីរបស់នាង យើងបានសួរនាងថា តើនាងស្តីបន្ទោសដល់ម្តាយរបស់នាងដែរ ឬអត់ តែនាងបានឆ្លើយមកវិញថា "ទេ ខ្ញុំគឺជាម្នាក់ដែលចង់ជួយដល់គ្រួសាររបស់ខ្ញុំ"។ អតិថិជនម្នាក់បានធ្វើការសម្រេចចិត្តចូលទៅក្នុងវិស័យការងាររកស៊ីផ្លូវភេទម្តងទៀត ដើម្បីសងបំណុលម្តាយរបស់នាង ហើយម្តាយរបស់នាងមិនបានដឹងពីប្រភេទនៃការងារដែលនាងធ្វើឡើយ។ ចុងបញ្ចប់ ជនរួចពីរងគ្រោះម្នាក់ ដែលត្រូវបានយាយរបស់នាងលក់ទៅផ្ទះបននៅពេលនាងមានអាយុប្រាំបួនឆ្នាំ នាងបានលើកហេតុផលថា ការនេះគឺសម្រាប់ជាផលប្រយោជន៍គ្រួសារ៖ "ខ្ញុំគិតថា ទោះបីជាយាយរបស់ខ្ញុំបានធ្វើខុសក៏ដោយ ក៏ខ្ញុំមានទំនួលខុសត្រូវសម្រាប់គ្រួសារ ទោះបីជាខ្ញុំនៅក្មេងពេកក៏ដោយ… ដូច្នេះ ទោះបីជាខ្ញុំដឹងថា វាខុសក៏ដោយ ក៏ខ្ញុំត្រូវធ្វើវាសម្រាប់គ្រួសាររបស់ខ្ញុំដែរ។"

ប្រធានបទនៃការគោរព និងការសងគុណ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសិក្សាមួយទៀត ទាក់ទងនឹងការបង្ខិតបង្ខំឲ្យចូលក្នុងវិស័យការងាររកស៊ីផ្លូវភេទនៅក្នុងប្រទេសកម្ពុជា៖

ស្ត្រីជាច្រើននាក់ដែលខ្ញុំបានធ្វើបទសម្ភាសន៍ ទទួលបានការពេញចិត្តយ៉ាងខ្លាំង នៅពេលដែលពួកគេអាចផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសាររបស់ពួកគេបាន។ ការបំពេញតាមតួនាទីវប្បធម៌ដ៏សំខាន់ ដើម្បីក្លាយជាកូនស្រី ដែលគោរពតាមកាតព្វកិច្ចជាកូនស្រី (និងកូនប្រុសក្តី) ដែលត្រូវទទួលខុសត្រូវមើលថែទាំឪពុកម្តាយ បងប្អូន និងកូនចៅរបស់ពួកគេ ហើយស្ត្រីមួយចំនួនដែលធ្វើការនៅក្នុងវិស័យការងាររកស៊ីផ្លូវភេទ មើលឃើញខ្លួនឯងថាជាបុគ្គលម្នាក់ដែលត្រូវលះបង់ខ្លួនយ៉ាងខ្លាំង (Sandy, 2006 ទំព័រ 465)។

## ៤.២.៣ ទំនាក់ទំនងអវិជ្ជមាន

ទោះបីជាទំនាក់ទំនងរវាងពួកគេ និងឪពុកម្តាយ មានភាពរកាំរកូស ឬអវិជ្ជមានយ៉ាងណាក៏ដោយ ជនរួចពីរងគ្រោះនៅតែបានផ្គត់ផ្គង់ឪពុកម្តាយរបស់ពួកគេ ហើយមានអារម្មណ៍មានទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ដល់ឪពុកម្តាយដដែល។ ជនរួចពីរងគ្រោះ ជារឿយៗ ត្រូវបានសាកសួរក្នុងពេលស្ទង់មតិ ឬបទសម្ភាសន៍ ថាតើមាននរណាម្នាក់ដែលពួកគេអាចទុកចិត្តបាននៅក្នុងជីវិតរបស់ពួកគេដែរឬទេ។ យោងតាមការឆ្លើយតបរបស់ពួកគេ វាត្រូវបានរកឃើញថាតើឪពុកម្តាយរបស់ពួកគេជាបុគ្គលដែលពួកគេទុកចិត្តបានដែរឬក៏អត់។ ពេលដែលជនរួចពីរងគ្រោះបាននិយាយអំពីការទុកចិត្តឪពុក/ម្តាយ ពួកគេភាគច្រើនបានបង្ហាញថាពួកគេទុកចិត្តម្តាយខ្លាំងជាងឪពុក ប៉ុន្តែ ករណីខ្លះទៀត គេទុកចិត្តឪពុកជាង។ សូមកត់សម្គាល់ថាមានករណីចំនួនបី ដែលអតិថិជនបានលើកឡើងថា ពួកគេទុកចិត្តឪពុកម្តាយរបស់ពួកគេ ប៉ុន្តែពួកគេមិនទុកចិត្តនរណាផ្សេងទៀតឡើយក្នុងរយៈពេលនៃការសិក្សាស្រាវជ្រាវនេះ។ លើសពីនេះទៅទៀត មានករណីមួយ អតិថិជនបានលើកឡើងថា ពួកគេមិនទុកចិត្តនរណាម្នាក់ឡើយ ទោះបីជាយ៉ាងណាក៏ដោយ ឪពុកម្តាយរបស់ពួកគេបានចែកឋាន (ស្លាប់)បាត់ទៅហើយ។ ដូច្នេះ ករណីនេះមិនត្រូវបានរាប់ចូលនៅក្នុងករណីដូចប្រភេទខាងលើនេះឡើយ។

សរុបមក មានអតិថិជន ៤២% បានលើកឡើងថា ពួកគេទុកចិត្តឪពុក ឬម្តាយ ឬទាំងឪពុកទាំងម្តាយ និងជាធម្មតាពួកគេទុកចិត្តម្តាយរបស់ពួកគេ យ៉ាងហោចណាស់ម្តង ក្នុងរយៈពេលនៃការសិក្សាស្រាវជ្រាវ។ ផ្ទុយទៅវិញ មានអតិថិជនជិត ៣០% បានលើកឡើងថា នៅពេលមួយ ពួកគេមិនទុកចិត្តឪពុកម្តាយរបស់ពួកគេឡើយ ជារឿយៗ បើមើលតាមប្រយោគភាគច្រើនបានលើកឡើងថា ពួកគេមិនមាននរណាម្នាក់ដែលពួកគេអាចទុកចិត្តបាននៅក្នុងជីវិតរបស់ពួកគេទេ។

| ប្រយោគនៃការទុកចិត្ត | ចំនួនជនរួចពីរងគ្រោះ | ភាគរយសរុបជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្ម |
|---|---|---|
| ទុកចិត្តឪពុកម្តាយរបស់ខ្លួន | ៣៣ | ៤២,៣% |
| មិនទុកចិត្តឪពុកម្តាយរបស់ខ្លួន | ២៣ | ២៩,៩% |

តារាង ៥៖ ការទុកចិត្តលើឪពុកម្តាយ (ចំនួន=៧៧នាក់)

ការបង្ហាញអារម្មណ៍ផ្សេងៗទៀតចំពោះគ្រួសាររបស់ពួកគេមានដូចជា អារម្មណ៍គ្មានការសោកស្តាយចំពោះអតីតកាលរបស់ពួកគេ (ឧទា. ការធ្វើការនៅក្នុងវិស័យរកស៊ីផ្លូវភេទ ការដែលត្រូវបានគេលក់ដោយការកេងប្រវ័ញ្ចផ្លូវភេទ) ដោយសារតែពួកគេបានចាត់ទុកវាដូចជាជាការលះបង់មួយរបស់ពួកគេសម្រាប់គ្រួសារ (ស្មើនឹង៧នាក់បានលើកឡើង) អារម្មណ៍នឹករលឹកដល់ឪពុកម្តាយរបស់ពួកគេជាខ្លាំង ដែលអារម្មណ៍នេះមិនមែនកើតឡើងតែនៅពេលដែលពួកគេកំពុងស្នាក់នៅក្នុងមណ្ឌលថែទាំជំនួសឡើយ (មាន១៤នាក់បានលើកឡើង) អារម្មណ៍ចង់ឲ្យគ្រួសាររបស់ពួកគេមើលថែ ឬមានអារម្មណ៍

"កក់ក្ដៅ" ក្នុងការរស់នៅជាមួយឪពុកម្ដាយរបស់ពួកគេ (មាន២០នាក់បានលើកឡើង) និងអារម្មណ៍ដែលឪពុកម្ដាយមិនបានមើលថៃ (មាន៧នាក់បានលើកឡើង)។ លទ្ធផលទាំងនេះ ត្រូវបានរៀបរាប់នៅក្នុងតារាងខាងក្រោម។

ជាញឹកញាប់ ភាពខុសគ្នារវាងទំនាក់ទំនងអវិជ្ជមាន និងបំណងចង់ជួយផ្គត់ផ្គង់ក្រុមគ្រួសារ គឺជាករណីដែលកើតឡើងច្រើនរវាងកូនស្រី និងម្ដាយរបស់ពួកគេ។ អតិថិជនម្នាក់ត្រូវបានម្ដាយរបស់នាងរំលោភបំពានទាំងរូបកាយ និងអារម្មណ៍ ប៉ុន្តែនាងនៅតែបង្ហាញការយល់ពីអារម្មណ៍របស់ម្ដាយនាង និងបំណងចិត្តចង់រស់នៅជាមួយគាត់ និងផ្គត់ផ្គង់ដល់គាត់។ គំនិតរបស់នាងទៅលើការរំលោភបំពាន ដែលនាងបានជួប គឺជាការសំដែងនូវភារកិច្ចសងគុណដែលកូនមានចំពោះឪពុកម្ដាយរបស់នាង៖ "ម្ដាយរបស់ខ្ញុំបានជេរ និងស្រែកដាក់ខ្ញុំនៅមុខអ្នកដទៃ។ ខ្ញុំបានព្យាយាមទប់អារម្មណ៍មិនតបចំពោះអ្វីដែលគាត់បានធ្វើចំពោះខ្ញុំ ដោយសារតែខ្ញុំយល់ថា គាត់គឺជាម្ដាយរបស់ខ្ញុំ"។

ជនរួចពីរងគ្រោះផ្សេងៗទៀតបានបង្ហាញពីអារម្មណ៍ទុក្ខព្រួយចំពោះការបាត់បង់ទំនាក់ទំនងជាមួយម្ដាយរបស់នាង ប៉ុន្តែពួកគេនៅតែបន្តធ្វើអ្វីដែលពួកគេគិតថា ជាភារកិច្ចរបស់ពួកគេ។ ពួកគេបានបង្ហាញពីបំណងចិត្តចង់នៅជិតស្និទស្នាលជាមួយម្ដាយរបស់ពួកគេ និងចង់ទទួលបានការយល់ព្រមពីម្ដាយរបស់ខ្លួនតាមរយៈការព្យាយាមធ្វើជាកូនស្រីដ៏ល្អម្នាក់ ដោយរួមទាំងការផ្ដល់លុយឲ្យកាន់តែច្រើនដល់ឪពុកម្ដាយផងដែរ។

| *ប្រយោគទាក់ទងនឹងការផ្គត់ផ្គង់ដល់ឪពុកម្ដាយ ទោះបីជាពួកគេមានទំនាក់ទំនងមិនល្អជាមួយឪពុកម្ដាយ* |
|---|
| "ខ្ញុំមិនដែលចង់បានអ្វីពីគាត់ឡើយ។ ខ្ញុំគ្រាន់តែចង់ធ្វើឲ្យគាត់សប្បាយចិត្ត ប៉ុន្តែ គាត់មិនបានយល់ពីខ្ញុំឡើយ។ គ្រប់ពេលដែលគាត់ត្រូវការលុយ ខ្ញុំតែងតែជួយគាត់ ដោយសារតែខ្ញុំមានអារម្មណ៍អាណិតគាត់។ ខ្ញុំចង់ជួយគាត់ ប៉ុន្តែ គាត់មិនដែលខ្វល់ខ្វាយពីខ្ញុំឡើយ។ គាត់បាននិយាយដើមខ្ញុំ។" |
| [ការពិភាក្សាអំពីទំនាក់ទំនងរបស់នាងជាមួយម្ដាយរបស់នាង ដែលបានជួញដូរនាង] "ខ្ញុំបារម្ភអំពីម្ដាយរបស់ខ្ញុំ ដែលស្ថិតនៅក្នុងពន្ធនាគារ។ ខ្ញុំចង់នៅជាមួយគាត់។" |
| [ការពិភាក្សាអំពីម្ដាយរបស់នាង ដែលនាងផ្គត់ផ្គង់ និងជួយសងបំណុល] "ម្ដាយរបស់ខ្ញុំរអ៊ូរដាក់ខ្ញុំជារឿយៗ ដោយសារតែខ្ញុំមិនឲ្យលុយដល់គាត់ ហើយគាត់បានខឹងខ្ញុំ។ ពេលខ្លះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំចង់ត្រលប់ទៅដូចមុនវិញ [ចង់ត្រលប់ទៅធ្វើការជាអ្នករកស៊ីផ្លូវភេទ]។" |

**តារាង 9៖** ប្រយោគទាក់ទងនឹងការផ្គត់ផ្គង់ដល់ឪពុកម្ដាយ ទោះបីជាមានទំនាក់ទំនងល្អជាមួយពួកគេ

ចុងបញ្ចប់ សំណុំនៃសូចនាករទាក់ទងនឹង "ទំនាក់ទំនងសងគុណបែបអវិជ្ជមាន" រួមមានសូចនាករចំនួនបីដែលត្រូវបានជ្រើសរើសចេញពីគ្រួសារបែកបាក់៖ ថាតើនៅក្នុងគ្រួសាររបស់ពួកគេធ្លាប់មានបងប្អូនបង្កើតត្រូវគេជួញដូរ ឬជួបការកេងប្រវ័ញ្ចផ្លូវភេទដូចគាត់ដែរឬទេ ឃ្លាប្រយោគមួយចំនួនទាក់ទងនឹងការញៀននៅក្នុងគ្រួសាររបស់ពួកគេ និងបញ្ហាអំពើហិង្សាក្នុងគ្រួសារ។ ស្ថានភាពណា ដែលពាក់ព័ន្ធជាមួយនឹងជនរួចពីរងគ្រោះខ្លួនឯង បងប្អូនបង្កើត ឬឪពុកម្ដាយ ឬអាណាព្យាបាលរបស់ពួកគេ គឺត្រូវបានរាប់បញ្ចូលនៅក្នុងសូចនាករទាំងពីរចុងក្រោយ។ ដូចបានឃើញនៅក្នុងតារាងខាងក្រោម នៅក្នុងការសិក្សានេះ មានជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្មចំនួន ២០% មានបងប្អូនបង្កើតដែលធ្លាប់ត្រូវគេជួញដូរ ឬកេងប្រវ័ញ្ចផ្លូវភេទផងដែរ ហើយ ៣០% មានបញ្ហាញៀននៅក្នុងគ្រួសាររបស់ពួកគេដូចជាការញៀនថ្នាំ ញៀនគ្រឿងស្រវឹង ឬញៀននឹងល្បែងស៊ីសងជាដើម និងមាន ៩% មានបទពិសោធន៍ ឬបានឃើញអំពើហិង្សាក្នុងគ្រួសាររបស់ពួកគេ។

| សូចនាករអំពីគ្រួសារបែកបាក់ | ចំនួនជនរួចពីរងគ្រោះ | ភាគរយសរុបនៃជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្ម |
|---|---|---|
| បងប្អូនបង្កើតដែលត្រូវគេជួញដូរ ឬកេងប្រវ័ញ្ចផ្លូវភេទផងដែរ | ១៦ | ២ ,១ |
| ការញៀននៅក្នុងគ្រួសារ៖ ថ្នាំ គ្រឿងស្រវឹង ល្បែងស៊ីសង | ២៣ | ៣ |
| អំពើហិង្សាក្នុងគ្រួសារ | ៧ | ៩,១ |

**តារាង 10៖** សូចនាករអំពីភាពបរាជ័យក្នុងគ្រួសារ ចំនួន=៧៧នាក់)

ជារួមមក គ្មានសូចនាករ ឬការបង្ហាញអារម្មណ៍ពីទំនាក់ទំនងគ្រួសារអវិជ្ជមានណាមួយ បានប៉ះពាល់ដល់បំណងចិត្ត ឬអារម្មណ៍ទទួលខុសត្រូវក្នុងការជួយផ្គង់ផ្គត់របស់ជនរួចពីរងគ្រោះដល់គ្រួសាររបស់ពួកគេនោះឡើយ។

### *៤.២.៤ បន្ទុកចំពោះការបំពេញកាតព្វកិច្ចគ្រួសារ*

សម្ពាធដ៏គួរឲ្យចាប់អារម្មណ៍នៅក្នុងចិត្តគំនិតរបស់អតិថិជនចូលរួម ចំពោះឪពុកម្តាយរបស់ពួកគេ គឺជារឿយៗត្រូវបានបង្ហាញថា ជាអារម្មណ៍ទទួលបន្ទុកដ៏ធំមួយក្នុងការផ្គត់ផ្គង់ដល់ឪពុកម្តាយរបស់ពួកគេ បើទោះបីជាពួកគេបាននិយាយថាវាជាកាតព្វកិច្ចរបស់ខ្លួន សម្រាប់ជាការសងគុណក៏ដោយ។ នៅក្នុងចម្លើយឆ្លើយតបទៅនឹងឃ្លាប្រយោគមួយចំនួន ដែលបានដាក់ឲ្យជនរួចពីរងគ្រោះជ្រើសរើសថាតើពួកគេយល់ស្រប ឬមិនយល់ស្រប ចំពោះអត្ថន័យនៃប្រយោគនោះយ៉ាងណា ហើយយល់ស្រប ឬមិនស្របនៅត្រឹមកម្រិតណា។ ជាសរុបមក ជនរួចពីរងគ្រោះបានលើកឡើងថា ឪពុកម្តាយគួរតែទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុសម្រាប់កូនៗ ដែលមានអាយុក្រោម ១៨ឆ្នាំ។ កុមារដែលមានអាយុក្រោម ១៨ឆ្នាំ មិនគួរទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ ឬសងបំណុលគ្រួសាររបស់ពួកគេឡើយ ប៉ុន្តែកូនដែលមានអាយុលើសពី ១៨ឆ្នាំ គួរតែធ្វើ។ ជាចុងបញ្ចប់ ជនរួចពីរងគ្រោះនៅក្នុងការសិក្សានេះមិនបានយល់ស្របជាមួយនឹងឃ្លាដែលថា "កូនត្រូវមានវាសនាដូចឪពុកម្តាយរបស់ពួកគេ" ឡើយ។ លើសពីនេះទៅទៀត ពួកគេមានការយល់ស្រប ឬយល់ស្របខ្លាំងថា បុរសដែលមានអាយុលើស ១៨ឆ្នាំ គួរតែមានទំនួលខុសត្រូវ ច្រើនជាងស្ត្រីដែលអាយុលើស ១៨ឆ្នាំ ក្នុងការផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេ។

ផ្ទុយពីលទ្ធផលរកឃើញទាំងនេះ មានអតិថិជនចូលរួមក្នុងការសិក្សាជាច្រើននាក់ ហើយមានចំនួនយ៉ាងច្រើនលើសលុបជាស្ត្រី បានបង្ហាញថា ពួកគេមានអារម្មណ៍ទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ដល់ឪពុកម្តាយ និងក្រុមគ្រួសាររបស់ពួកគេ ហើយពួកគេបាននិយាយថា ពួកគេត្រូវធ្វើបែបនេះ តាំងពីពួកគេនៅជាកុមារមកម្ល៉េះ។ បន្ទុកនៃកាតព្វកិច្ចសងគុណ បានជះឥទ្ធិពលប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់ជនរួចពីរងគ្រោះ រហូតដល់មានអ្នកខ្លះក្នុងចំណោមពួកគេបាននិយាយអំពីអារម្មណ៍ចង់សម្លាប់ខ្លួន បាក់ទឹកចិត្ត និងតានតឹងអារម្មណ៍ខ្លាំងអំពីការមានភារកិច្ចត្រូវផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេ។ ការពិភាក្សាក្រុមគោលដៅអំពីកាតព្វកិច្ចសងគុណ បានបញ្ជាក់អំពីការពាក់ព័ន្ធគ្នាដែលការសិក្សាស្រាវជ្រាវពីមុនៗ បានលើកឡើង រវាងភារកិច្ចសងគុណផ្នែកហិរញ្ញវត្ថុ និងលទ្ធផលសុខភាពផ្លូវចិត្តអវិជ្ជមាន។

តារាងខាងក្រោម រៀបរាប់អំពីប្រយោគមួយចំនួន ដែលជនរួចពីរងគ្រោះបានលើកឡើងអំពីបន្ទុកនៃកាតព្វកិច្ចសងគុណរបស់ពួកគេ ក៏ដូចជាអារម្មណ៍ដែលត្រូវរែកពុនបន្ទុកទាំងនោះ។

| *ប្រយោគទាក់ទងនឹងបន្ទុកនៃការសងគុណ* |
|---|
| "ឧបសគ្គដ៏ធំបំផុតក្នុងការសម្រេចគោលដៅរបស់ខ្ញុំ គឺខ្ញុំខ្វះលុយក្នុងការផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្ញុំ... ខ្ញុំចង់ក្លាយជាមេចុងភៅ ដើម្បីឲ្យខ្ញុំអាចជួយដល់គ្រួសាររបស់ខ្ញុំ។ ឪពុកម្ដាយរបស់ខ្ញុំ ត្រូវការលុយ។ វាបន្ទាន់ពេកហើយសម្រាប់ខ្ញុំ។" |
| "បងប្រុសរបស់ខ្ញុំជួយឪពុកម្ដាយរបស់ខ្ញុំ ប៉ុន្តែ មិនបានច្រើនទ្បើយ ដោយសារតែគាត់មានបំណុលជាច្រើន។ ពីមុន ខ្ញុំមានអារម្មណ៍ពីបន្ទុកដែលត្រូវមានការទទួលខុសត្រូវទាំងនេះ...ខ្ញុំមានអារម្មណ៍អន់ចិត្ត។ ខ្ញុំយំ។ ខ្ញុំឈឺចាប់ ហេតុអ្វីបានជាខ្ញុំជាម្នាក់ដែលត្រូវរ៉ាប់រងដល់គ្រួសារទាំងមូលអញ្ចឹង ?" |
| "ខ្ញុំមានអារម្មណ៍ទទួលខុសត្រូវសងបំណុល ដោយសារតែខ្ញុំបានខ្ចីលុយ ដើម្បីធ្វើពិធី ពេលដែលម្ដាយរបស់ខ្ញុំឈឺ។ ខ្ញុំបារម្ភច្រើនអំពីលុយជំពាក់គេនោះ ដ្បិតខ្ញុំជាមនុស្សតែម្នាក់គត់ ដែលទទួលខុសត្រូវសងបំណុល។ ពេលខ្លះ វាធ្វើឲ្យខ្ញុំមានអារម្មណ៍ឯកោយ៉ាងខ្លាំង។" |
| "ខ្ញុំត្រូវធ្វើការយ៉ាងនឿយហត់ ដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ហត់នឿយខ្លាំងក្នុងការធ្វើបែបនេះ។" |
| "ពេលដែលខ្ញុំបានឃើញស្ថានភាពគ្រួសាររបស់ខ្ញុំ ខ្ញុំមិនអាចឈប់យំទ្បើយ។ យើងគឺជាគ្រួសារធំមួយ។ ពេលខ្លះ ខ្ញុំចង់សម្លាប់ខ្លួន ប៉ុន្តែ ពួកគេបានលើកទឹកចិត្តខ្ញុំ។" |
| "គ្រួសាររបស់ខ្ញុំ មានបញ្ហាជាច្រើន។ យើងគ្មានប្រាក់ចំណូល ហើយមានបំណុលជាច្រើន ខណៈពេលដែលម្ដាយរបស់ខ្ញុំលេងល្បែងស៊ីសង។ ខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់អំពីការនេះ។ បញ្ហាគ្រួសាររបស់ខ្ញុំធ្វើឲ្យខ្ញុំឈឺចិត្តណាស់។" |

**តារាង 11៖** ប្រយោគទាក់ទងនឹងបន្ទុកនៃការសងគុណ

លទ្ធផលនៃការពិភាក្សាក្រុមគោលដៅ ទៅលើប្រធានបទ "ការសងគុណ" ក៏បានបង្ហាញអំពីការសំដែងអារម្មណ៍ស្រដៀងគ្នាពីបន្ទុកនេះផងដែរ។ ចំណុចខាងក្រោម បង្ហាញពីលទ្ធផលដែលឆ្លើយតបនឹងសំណួរ៖ "តើកាតព្វកិច្ចមានន័យបែបណាខ្លះចំពោះអ្នក ?"

ពេលដែលសុំឲ្យកំនត់អត្ថន័យ និងពិភាក្សាអំពីពាក្យថា "កាតព្វកិច្ច" អតិថិជនចូលរួមក្នុងការពិភាក្សាបានប្រើពាក្យមួយចំនួនដូចជា "ធ្ងន់ធ្ងរ" "បន្ទុក" "ទំនួលខុសត្រូវ" និង "ពិបាក"។ ពួកគេបាននិយាយអំពី "ចង្កោមនៃកាតព្វកិច្ចដែលពួកគេត្រូវទទួលខុសត្រូវ" ជាអ្វីៗ ដែលពួកគេត្រូវធ្វើ ដើម្បីផ្គត់ផ្គង់ដល់គ្រួសារ រួមមានទាំងអាហារ សម្លៀកបំពាក់ ផ្ទះសម្បែង និងថ្លៃថ្នាំពេទ្យជាដើម។

ពួកគេក៏បានបង្ហាញពីអារម្មណ៍ទាំងពីរយ៉ាង៖ អារម្មណ៍ទទួលបន្ទុកច្រើនហួសហេតុពេកដោយប្រើពាក្យថា *"វាពិតជាពិបាកណាស់!"* និង *"វាមានកិច្ចការជាច្រើនដែលយើងត្រូវគិត"* និងអារម្មណ៍ដែលពួកគេត្រូវតែស៊ូទ្រាំនៅក្នុងកាតព្វកិច្ចរបស់ពួកគេ *"យើងគួរតែធ្វើនូវអ្វីដែលយើងត្រូវធ្វើ ហើយមិនត្រូវបោះបង់ចោលទ្បើយ។"*

និយមន័យនៃពាក្យ "កាតព្វកិច្ច" ត្រូវបានជនរួចពីរងគ្រោះសង្ខេបមកក្នុងប្រយោគមួយដូចខាងក្រោម៖
*"កាតព្វកិច្ច គឺជាភារកិច្ចរបស់យើង ដែលយើងត្រូវតែទទួលខុសត្រូវចំពោះក្រុមគ្រួសាររបស់យើង។"*

**តារាង 12៖** ទស្សនៈយល់ឃើញអំពីកាតព្វកិច្ច

អតិថិជនក៏បានបង្ហាញពីអារម្មណ៍មិនល្អ និងពិរុទ្ធភាព នៅពេលដែលពួកគេមានអារម្មណ៍ថា ពួកគេមិនអាចផ្គត់ផ្គង់បានគ្រប់គ្រាន់ដល់ឪពុកម្ដាយរបស់ពួកគេ។ មានអតិថិជនម្នាក់បានបង្ហាញពីអារម្មណ៍ពិរុទ្ធភាពថា ដោយសារនាងបានរៀបការរួចហើយ នាងមិនអាចផ្គត់ផ្គង់បានពេញលេញដល់គ្រួសារឪពុកម្ដាយរបស់នាងទេ៖ "ខ្ញុំព្រួយបារម្ភអំពីពួកគាត់ ពេលដែលខ្ញុំឃើញពួកគាត់ជួបការលំបាក...យ៉ាងណាក្តី ខ្ញុំមិនអាចជួយពួកគាត់បានទ្បើយ ដោយសារតែខ្ញុំបានរៀបការរួចហើយ។ អ្វី

ដែលខ្ញុំរកបាន គឺសម្រាប់តែផ្គត់ផ្គង់ដល់គ្រួសារផ្ទាល់របស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំមិនអាចជួយបាន ដូច្នេះ ខ្ញុំមានអារម្មណ៍មិនល្អឡើយ។" មានអតិថិជនម្នាក់ទៀត បានពណ៌នាអំពីសម្ពាធក្នុងការផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួន ទោះបីជាគេបានដឹងពីអត្ថប្រយោជន៍នៃការអប់រំដែលនឹងជួយគេបានកាន់តែច្រើននៅក្នុងពេលអនាគតក៏ដោយៈ "ខ្ញុំចង់បញ្ចប់ការសិក្សារបស់ខ្ញុំ។ ខ្ញុំចង់មានការងារមួយ ដើម្បីឲ្យខ្ញុំអាចផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្ញុំបានប្រសើរជាងពេលនេះ... ខ្ញុំអាចបន្តរឹងមាំបាន ប៉ុន្តែពេលដែលខ្ញុំឃើញទឹកមុខរបស់ពួកគាត់ ខ្ញុំមិនអាចទ្រាំទ្របានឡើយ ខ្ញុំមានអារម្មណ៍ឈឺចិត្ត...មានអ្នកខ្លះស្តីបន្ទោសខ្ញុំថា ខ្ញុំល្ងង់ដែលខ្ញុំមិនស្តាប់តាមឪពុកម្តាយរបស់ខ្ញុំ [ឈប់រៀន ហើយរកការងារធ្វើ] ប៉ុន្តែ ពួកគេមិនដឹងថា ខ្ញុំឈឺចិត្តខ្លាំងប៉ុណ្ណាឡើយ។" បន្ទុកក្នុងការផ្គត់ផ្គង់ដល់គ្រួសារមិនមែនកើតឡើងចំពោះតែទំនួលខុសត្រូវលើឪពុកម្តាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏កើតឡើងដោយសារតែមានបន្ទុកទទួលខុសត្រូវផ្គត់ផ្គង់ដល់បងប្អូនសាច់ញាតិដទៃទៀត ក៏ដូចគ្នានឹងសហគមន៍ទាំងមូលផងដែរ។ អតិថិជនខ្លះបានបង្ហាញអារម្មណ៍ ទទួលរងនូវការមើលងាយពីសំណាក់អ្នកជិតខាង ដោយសារតែពួកគេមិនបានផ្តល់លុយគ្រប់គ្រាន់ឲ្យឪពុកម្តាយរបស់ពួកគេ ពេលដែលពួកគេមកលេងផ្ទះ។

ការសម្រេចចិត្តបែបអវិជ្ជមាន ក៏ត្រូវបានជាប់ទាក់ទងជាមួយនឹង "បន្ទុកនៃការសងគុណ" នេះផងដែរ។ ជាញឹកញាប់អតិថិជនដែលបានត្រលប់ទៅប្រកបរបររកស៊ីផ្លូវភេទ ឬពិចារណាគិតចង់ត្រលប់ទៅធ្វើការបែបនេះវិញ ដោយសារតែគ្រួសាររបស់ពួកគេត្រូវការលុយ ឬកំពុងតែទទួលរងនូវសម្ពាធ ដែលជំរុញឲ្យពួកគេរកលុយឲ្យបានកាន់តែច្រើនថែមទៀត។ មានជនរួចពីរងគ្រោះម្នាក់បានសម្រេចចិត្តចាប់ផ្តើមផ្តល់សេវាផ្លូវភេទដល់អតិថិជននៅក្នុងហាងខារ៉ាអូខេវិញ ក្រោយពេលនាងបានធ្វើសមាហរណកម្ម បន្ទាប់ពីម្តាយរបស់នាងមានជម្ងឺ ហើយតម្រូវឲ្យធ្វើការព្យាបាលបន្ទាន់ និងត្រូវស្នាក់នៅមន្ទីរពេទ្យក្នុងរយៈពេលជាច្រើនថ្ងៃ ហើយថ្លៃសម្រាប់ការព្យាបាលត្រូវការលុយច្រើនណាស់ ដែលធ្វើឲ្យគ្រួសារនាងមិនអាចមានលទ្ធផលបង់ប្រាក់ឡើយ។ អតិថិជនម្នាក់ទៀត កំពុងតែពិចារណាចង់ត្រលប់ទៅរក "ការងារពេលយប់" (ការរកស៊ីផ្លូវភេទ) ដោយសារតែសម្ពាធដែលឪពុកម្តាយរបស់នាងដាក់មកលើនាងៈ "ខ្ញុំបានប្រាប់ [ឪពុកម្តាយរបស់ខ្ញុំ] ថា ខ្ញុំចង់ធ្វើការ [ការងារជាមួយកម្មវិធីអង្គការ] តែពួកគេបាននិយាយថា ពេលដែលខ្ញុំធ្វើការនៅទីនេះ ខ្ញុំមិនមានលុយសល់ ហើយមិនដែលជួយពួកគាត់ឡើយ។ ខ្ញុំជួយពួកគាត់ច្រើនរួចមកហើយ ហើយខ្ញុំមិនដឹងថា ពួកគាត់ចង់ឲ្យខ្ញុំជួយច្រើនប៉ុណ្ណាទៀតទេ។ នេះជាហេតុផលដែលខ្ញុំសម្រេចចិត្តធ្វើការនៅពេលយប់ ប៉ុន្តែ ការធ្វើការពេលយប់ ខ្ញុំមានអារម្មណ៍មិនល្អឡើយ។"

## ៤.៣ ការទទួលរងនូវការឈឺចាប់ពីក្តីបារម្ភផ្នែកហិរញ្ញវត្ថុរបស់ជនរួចពីរងគ្រោះ

ជនរួចពីរងគ្រោះជួបបទពិសោធន៍ថប់បារម្ភ (ខ្វល់ខ្វាយ)ទាំងស្ថានភាពហិរញ្ញវត្ថុក្នុងពេលបច្ចុប្បន្ន និងអំពីបញ្ហាផែនការអនាគតរបស់ពួកគេ។ ផ្នែកនេះ រៀបរាប់អំពីការបង្ហាញអារម្មណ៍ និងរោគសញ្ញានៃក្តីបារម្ភផ្នែកហិរញ្ញវត្ថុមួយចំនួនក្នុងចំណោមជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្ម ក៏ដូចជាការបង្ហាញចេញពីក្តីបារម្ភរបស់ពួកគេ តាមរយៈការរំពឹងទុក និង ផែនការអនាគតដែលមិនសូវប្រាកដប្រជា។

ដូចជាបានឃើញនៅក្នុងតារាងខាងក្រោម ជនរួចពីរងគ្រោះ ត្រូវបានបែងចែកទៅតាមប្រភេទថាតើពួកគេរកលុយបានគ្រប់គ្រាន់ពីការងារចម្បងរបស់ពួកគេដែរទេ ទោះបីជាពួកគេទាំងអស់គ្នាសុទ្ធតែបានដឹងពីបញ្ហានេះក៏ដោយ។ ដើម្បីឆ្លើយតបចំពោះប្រយោគដែលថ្លែងថាៈ "ខ្ញុំអាចរកលុយបានគ្រប់គ្រាន់ តាមរយៈការងារចម្បងរបស់ខ្ញុំ" មានអតិថិជនចំនួន ២២ នាក់ បានឆ្លើយថាយល់ស្រប ឬយល់ស្របខ្លាំង និងមានអតិថិជន ២២នាក់ទៀត បានមិនយល់ស្រប ឬមិនយល់ស្របខ្លាំងចំពោះឃ្លាដែលបានលើកឡើងខាងលើ។




**តារាង 13៖** ចម្លើយ "ខ្ញុំរកលុយបានគ្រប់គ្រាន់ ដោយធ្វើការនៅក្នុងការងារតែមួយ" (ចំនួន=៤៤នាក់)

ប្រព័ន្ធចងកូដសម្រាប់ទិន្នន័យសាច់រឿងសង្ខេបបែបគុណវិស័យ ក៏ត្រូវត្រួតពិនិត្យតាមដានថាតើជនរួចពីរងគ្រោះមានអារម្មណ៍ថា ពួកគេមានលុយគ្រប់គ្រាន់ ដើម្បីទូទាត់លើការចំណាយរបស់ពួកគេដែរឬទេ។ តាមរយៈបទសម្ភាសន៍ក្នុងអំឡុងពេលនៃការសិក្សាស្រាវជ្រាវ (ចាប់ពីក្នុងឆ្នាំ២០១១ និងរហូតដល់ពាក់កណ្តាលឆ្នាំ ២០១៥ សម្រាប់អតិថិជនមួយចំនួន និងបទសម្ភាសន៍ក្នុងចុងឆ្នាំ ២០១៤សម្រាប់អតិថិជនដទៃទៀត) មានអតិថិជន ២៨,៦% បាននិយាយថា ពួកគេមានអារម្មណ៍ថា ពួកគេមានលុយគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំថ្ងៃរបស់ពួកគេ ខណៈពេលដែល អតិថិជនចំនួន ៤១,៦% បាននិយាយថា ពួកគេមានអារម្មណ៍ថា ពួកគេមិនមានលុយគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំថ្ងៃរបស់ពួកគេឡើយ (នៅសល់អតិថិជនចំនួន៣០%ផ្សេងទៀត ដែលមិនបានលើកឡើងថាតើពួកគេមានលុយគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំថ្ងៃរបស់ពួកគេឡើយ)។

សូចនាករដទៃទៀតទាក់ទងនឹងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ រួមមានដូចជាការបង្ហាញពីក្តីបារម្ភ ឬភាពភ័យខ្លាចអំពីបញ្ហាថវិកា (ចំណុចនេះខុសគ្នាពីក្តីបារម្ភអំពីបញ្ហាបំណុល) ការសំដែងបង្ហាញពីភាពមិនច្បាស់លាស់ ឬក្តីបារម្ភអំពីបញ្ហាអនាគត និងការបង្ហាញអំពីការរៀបចំផែនការអនាគត។ លទ្ធផលនៃសូចនាករនេះ មានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| បទពិសោធន៍ ឬការបង្ហាញពីក្តីបារម្ភផ្នែកហិរញ្ញវត្ថុ | ចំនួនជនរួចពីរងគ្រោះ ដែលបានបង្ហាញពីប្រធានបទនេះ | ភាគរយសរុបនៃជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្ម |
|---|---|---|
| ក្តីបារម្ភ ឬភាពភ័យខ្លាចទាក់ទងនឹងបញ្ហាថវិកា (ខុសពីក្តីបារម្ភអំពីបញ្ហាបំណុល) | ៣៨ | ៤៩,៤% |
| ភាពមិនច្បាស់លាស់ ឬក្តីបារម្ភអំពីអនាគត | ៤៥ | ៥៨,៤% |
| ការរៀបចំផែនការអនាគត | ៦៦ | ៨៥,៧% |

**តារាង 14៖** ការបង្ហាញ និងបទពិសោធន៍អំពីក្តីបារម្ភផ្នែកហិរញ្ញវត្ថុ (ចំនួន=៧៧នាក់)

ក្នុងចំណោមអតិថិជនចំនួន ៣៨នាក់ ដែលបានសំដែងពីក្តីបារម្ភ ឬភាពភ័យខ្លាច ទាក់ទងនឹងបញ្ហាថវិកា មានអតិថិជន៣៧នាក់បាននិយាយអំពីប្រធានបទនេះ ក្រោយពេលពួកគេបានធ្វើសមាហរណកម្ម។ ហើយមាន៥នាក់ក្នុងចំណោម៣៧នាក់នោះក៏បានសំដែងពីក្តីបារម្ភអំពីបញ្ហាថវិកា មុនពេលការធ្វើសមាហរណកម្មរបស់ពួកគេ (ឧទា. ពេលដែលពួកគេកំពុង

តែរស់នៅក្នុងមណ្ឌល) និងមានអតិថិជនម្នាក់ទៀតបានសំដែងពីក្តីបារម្ភអំពីបញ្ហាថវិកានេះ មុនពេលធ្វើសមាហរណកម្ម តែមិនមាននិយាយទៀតឡើយបន្ទាប់ពីគេបានធ្វើសមាហរណកម្ម។

មួយវិញទៀត មានអតិថិជនចំនួន ៤៥នាក់ បានសំដែងពីភាពមិនច្បាស់លាស់ ឬក្តីបារម្ភរបស់ពួកគេចំពោះបញ្ហាអនាគត ដូចជាការចង់បន្តការសិក្សាឲ្យបានចប់ ការស្វែងរកការងារ ការរកលុយបានគ្រប់គ្រាន់ ឬបញ្ហាផ្គត់ផ្គង់ជីវភាព និងបញ្ហាសុខុមាលភាពផ្សេងៗទៀត។ ក្នុងនោះ មានអតិថិជន៣៨នាក់ បានសំដែងពីប្រធានបទនេះ ក្រោយពេលធ្វើសមាហរណកម្ម មាន៦នាក់ បានប្រាប់ពីរឿងនេះ មុនពេលធ្វើសមាហរណកម្ម ហើយមានម្នាក់បានបង្ហាញពីក្តីបារម្ភនេះ ទាំងមុនពេល និង ក្រោយពេលធ្វើសមាហរណកម្មរួច។

ជាចុងបញ្ចប់ មានអតិថិជនចំនួន ៦៦នាក់ បានបង្ហាញពីទម្រង់មួយចំនួននៃការរៀបចំផែនការអនាគត។ តួលេខនេះហាក់ដូចជាខ្ពស់ជាងសូចនាករដទៃទៀត ហើយវាអាចដោយសារតែការសួរសំណួរដោយផ្ទាល់ចំៗពីផែនការអនាគត ដែលជាញឹកញាប់ត្រូវបានសួរក្នុងកំឡុងពេលធ្វើបទសម្ភាសន៍។ ក្នុងចំណោមអតិថិជនចំនួន ៦៦នាក់ មានអតិថិជនចំនួន៣៣នាក់ បានបង្ហាញពីផែនការសម្រាប់អនាគត ក្រោយពេលធ្វើសមាហរណកម្ម និងមាន១២នាក់បង្ហាញពីការរៀបចំផែនការមុនពេលធ្វើសមាហរណកម្ម ហើយ ២១នាក់ទៀត បានបង្ហាញពីការរៀបចំផែនការអនាគត ទាំងមុន និងក្រោយពេលធ្វើសមាហរណកម្ម។

សូចនាករមួយទៀត គឺជាចំនួនដងដែលជនរួចពីរងគ្រោះបានផ្លាស់ប្តូរទីលំនៅ ក្រោយពេលធ្វើសមាហរណកម្មរួច។ ក្នុងចំណោម ៦៨នាក់ ដែលសូចនាករនេះបានធ្វើការតាមដាន ចំនួនផ្លាស់ប្តូរទីលំនៅជាមធ្យមដែលពួកគេបានធ្វើក្រោយពេលធ្វើសមាហរណកម្ម គឺមានចំនួន ២,៧ដង។ អតិថិជនចំនួន១៦នាក់ បានផ្លាស់ប្តូរទីលំនៅលើសពី៤ដង ក្រោយពេលធ្វើសមាហរណកម្ម ជាទូទៅក្នុងរយៈពេលប្រហែលជាពីរឆ្នាំ។ ជាចុងក្រោយ មាន ១៦,៩%នៃអតិថិជនទាំងនោះ នៅពេលខ្លះបានពិភាក្សាថា ពួកគេមិនមានឯកសារកំណត់អត្តសញ្ញាណត្រឹមត្រូវ ដូចជាសំបុត្រកំណើត ឬសៀវភៅគ្រួសារឡើយ ដែលកត្តានេះអាចជាសូចនាករនៃភាពងាយរងគ្រោះសេដ្ឋកិច្ចមួយទៀតផងដែរ។

### *៤.៣.១ បញ្ហាថវិកា និងសុខភាពផ្លូវចិត្ត*

ដូចបានបង្ហាញខាងលើ ជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្ម ជួបបទពិសោធន៍ទាក់ទងនឹងក្តីបារម្ភផ្នែកហិរញ្ញវត្ថុដែលកើតឡើងម្តងហើយម្តងទៀត និងជាទៀងទាត់។ រោគសញ្ញានៃក្តីបារម្ភផ្នែកហិរញ្ញវត្ថុ ត្រូវបានតភ្ជាប់ជាមួយនឹងបន្ទុកនៃការសងគុណឪពុកម្តាយ ដូចជាបានលើកឡើងដោយអតិថិជនម្នាក់ ដែលនិយាយអំពីការជះឥទ្ធិពលអវិជ្ជមាននៃការត្រូវទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះគ្រួសាររបស់នាង៖ "ខ្ញុំមានទំនួលខុសត្រូវច្រើនណាស់ បើខ្ញុំមានលទ្ធភាព (ស្ថានភាពសេដ្ឋកិច្ចខ្ពស់ជាងនេះ) ខ្ញុំនឹងមិនមានអារម្មណ៍តានតឹងបែបនេះឡើយ។ បើខ្ញុំគ្មានសមត្ថភាពនឹងដោះស្រាយបញ្ហានេះ ខ្ញុំមានអារម្មណ៍មួម៉ៅ ហើយពេលខ្លះ ពេលដែលខ្ញុំមិនអាចគ្រប់គ្រងអារម្មណ៍បាន ខ្ញុំចោលកំហឹងទាំងនោះទៅលើកូនៗរបស់ខ្ញុំ។"

អតិថិជនទាំងអស់ដែលបានចូលរួមក្នុងការពិភាក្សាក្រុមគោលដៅ សុទ្ធតែយល់ស្របលើការជះឥទ្ធិពលជាអវិជ្ជមាននៃការមានកាតព្វកិច្ចច្រើនពេកចំពោះក្រុមគ្រួសាររបស់ពួកគេ ដូចជាបានរៀបរាប់នៅក្នុងប្រអប់ខាងក្រោម៖

**សំណួរ៖ នៅពេលអ្នកមានទំនួលខុសត្រូវច្រើនចំពោះឪពុកម្តាយ និងក្រុមគ្រួសាររបស់អ្នក តើវាអាចជះឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះដល់អ្នក?**

មានអតិថិជនតិចតួចប៉ុណ្ណោះដែលអាចបង្ហាញពីចំណុចវិជ្ជមានចំពោះការមានកាតព្វកិច្ចគ្រួសារច្រើន។ មានអតិថិជនពីរនាក់បានយល់ស្របថា ពួកគេគួរតែមានមោទនភាពចំពោះខ្លួនឯង ដែលអាចឆ្លងកាត់ទុក្ខលំបាក ហើយអាចក្រោកឈរវិញបាន ពេលដែលពួកគេដួលចុះ៖ *"យើងត្រូវតែរឹងមាំឡើង និងក្រោកឈរវិញ!"*

ទោះជាយ៉ាងណាក៏ដោយ អតិថិជនទាំងអស់ មានចំណុចដែលត្រូវនិយាយទាក់ទងនឹងការជះឥទ្ធិពលអវិជ្ជមានចំពោះការមានទំនួលខុសត្រូវជាច្រើនបែបនេះចំពោះគ្រួសារ។ រោគសញ្ញា និងការបង្ហាញអារម្មណ៍ទំនួលខុសត្រូវ ដែលគេបានរៀបរាប់ មានដូចជា អារម្មណ៍ស្ត្រេស ការផ្ទុះកំហឹង ការមានជម្លោះជាមួយអ្នកដទៃ ការមានអារម្មណ៍អស់សង្ឃឹម ការពិបាកផ្តោតអារម្មណ៍ ការឈឺក្បាល ការស្រែកយំ ការគេងមិនលក់ ការមានគំនិតចង់សម្លាប់ខ្លួន ការមានជម្ងឺលើរាងកាយ ការបាក់ទឹកចិត្ត និង ការខ្វះការជំរុញចិត្ត។ ជនរួចពីរងគ្រោះបាននិយាយលើកឡើងពីអារម្មណ៍ "ធ្ងន់" "ស្មុគស្មាញ" និង "ពិបាកចិត្ត"។

លើសពីនេះទៅទៀត អតិថិជនទាំងអស់បានយល់ស្របលើហេតុផលដំបូងបំផុត ដែលជំរុញពួកគេឲ្យធ្វើការនៅក្នុងវិស័យកម្សាន្ត(វិស័យការងាររកស៊ីផ្លូវភេទ) គឺដោយសារតែពួកគេមានអារម្មណ៍ថា ពួកគេមានទំនួលខុសត្រូវច្រើនពេកចំពោះគ្រួសាររបស់ពួកគេ។

**តារាង 15៖** ការជះឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានដោយសារទំនួលខុសត្រូវសងគុណឪពុកម្តាយ

អារម្មណ៍បារម្ភរបស់ជនរួចពីរងគ្រោះ មិនមែនគ្រាន់តែទាក់ទងនឹងទំនួលខុសត្រូវ និងបន្ទុកនៃការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុសម្រាប់គ្រួសាររបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែវាក៏ទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ ជាញឹកញាប់ជនរួចពីរងគ្រោះមានការព្រួយបារម្ភអំពីបញ្ហាលុយដែលពួកគេរកបាន បារម្ភពីការធ្វើយ៉ាងណាឲ្យពួកគេអាចនឹងបង់ថ្លៃការចំណាយទាំងអស់របស់ពួកគេបាន ការមើលថែដល់កូនរបស់ពួកគេ របៀបដែលពួកគេនឹង (ឬមិនអាច) រៀបចំសម្រាប់ស្ថានភាពអាសន្ន ដូចជា ការមានជំងឺ ឬការស្លាប់របស់សមាជិកគ្រួសារ និងរបៀបដែលពួកគេនឹងសងបំណុលរបស់ខ្លួនឯង និងបំណុលគ្រួសាររបស់ពួកគេជាដើម។ មានជនរួចពីរងគ្រោះប្រហែលជាពាក់កណ្តាល បានលើកឡើងថា ពេលខ្លះ ពួកគេមានអារម្មណ៍ព្រួយបារម្ភ ឬភ័យខ្លាច ទាក់ទងនឹងលុយ ហើយជិតពាក់កណ្តាល បាននិយាយថា ពួកគេមិនបានរកលុយគ្រប់គ្រាន់សម្រាប់ការចំណាយរបស់ពួកគេឡើយ។ ការនេះមិនបានប្រសើរឡើងក្នុងពេលមួយរយៈឡើយ ប៉ុន្តែវាតែងតែបារម្ភជានិច្ចនៅក្នុងកំឡុងពេលនៃការសិក្សាវាយតម្លៃ។

ជារឿយៗ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចាត់ទុកការមានលុយច្រើនស្មើជាមួយនឹងការមានលទ្ធផលសុខភាពផ្លូវចិត្តវិជ្ជមាន ដូចជាបានឃើញនៅក្នុងប្រយោគក្នុងតារាងខាងលើ ("ខ្ញុំមិនមានអារម្មណ៍តានតឹងឡើយ")។ ការភ្ជាប់ជាមួយការនេះ គឺជាបំណងចិត្តដែលបង្ហាញចេញពេលខ្លះថា ខ្លួនចង់រៀបការជាមួយបុរសអ្នកមាន ដែលអាចមើលថែពួកគេ និងក្រុមគ្រួសាររបស់ពួកគេបាន។ គំនិតរបស់ជនជនរួចពីរងគ្រោះភាគច្រើន មានពាក់ព័ន្ធនឹងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ។ ឧទាហរណ៍ ជនរួចពីរងគ្រោះម្នាក់បាននិយាយសរុបមកថា៖ "ខ្ញុំគិតថា លុយគឺជាវត្ថុមួយដ៏សំខាន់។ ខ្ញុំគិតថា លុយគឺជាអ្វីៗទាំងអស់ លុយ ផ្ទះ និង របស់របរផ្សេងទៀត។" ផ្ទុយទៅវិញ ជារឿយៗ ជនរួចពីរងគ្រោះបាននិយាយអំពីអារម្មណ៍អវិជ្ជមាន ពេលដែលពិភាក្សាអំពីប្រាក់ចំនូល ឬក្តីបារម្ភផ្នែកហិរញ្ញវត្ថុរបស់ពួកគេ៖ "ខ្ញុំមានអារម្មណ៍តានតឹងភាគច្រើន ពេលដែលខ្ញុំមិនមានលុយ។ ពេលដែលខ្ញុំមិនមានលុយ វាធ្វើឲ្យខ្ញុំមានអារម្មណ៍ខឹង និងបាក់ទឹកចិត្ត។"

ក្តីបារម្ភផ្នែកហិរញ្ញវត្ថុ ក៏ត្រូវបានបង្ហាញចេញតាមរយៈអារម្មណ៍គ្របដណ្តប់ខ្លាំង ហើយជនរួចពីរងគ្រោះមួយចំនួនបាននិយាយអំពីការចង់ធ្វើអ្វីមួយសម្រាប់ពួកគេ (ដោយឪពុកម្តាយរបស់ពួកគេ ឬបុគ្គលិកកម្មវិធីជំនួយអង្គការ) ដោយសារតែពួកគេមិនអាចដោះស្រាយបញ្ហាទាំងនោះដោយខ្លួនឯងបាន។ ជនរួចពីរងគ្រោះម្នាក់បានជួបបញ្ហា ដោយពេលធ្វើសមាហរណកម្ម ប៉ុន្តែក៏បានបង្ហាញពីដំណើរនៃភាពធន់ទ្រាំរបស់នាងថា៖ "ខ្ញុំមានអារម្មណ៍ថា ការធ្វើសមាហរណកម្មរបស់ខ្ញុំ មិនសូវជាល្អទេឡើយ ដោយសារតែខ្ញុំមានអារម្មណ៍ទទួលខុសត្រូវធ្វើការយ៉ាងខ្លាំង ដើម្បីរកប្រាក់។ ខ្ញុំត្រូវមើលថែខ្លួនឯងនៅផ្ទះ ខុសពីនៅក្នុងមណ្ឌល ដែលខ្ញុំមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ហើយមានអ្នកម្តាយនៅមណ្ឌលជាអ្នកចម្អិនម្ហូប។ ប៉ុន្តែខ្ញុំគិតថា ខ្ញុំគួរតែរៀនចេះរស់នៅដោយខ្លួនឯង។"

ភេទហាក់ដូចជាដើរតួយ៉ាងសំខាន់នៅក្នុងអារម្មណ៍ទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ។ ក្តីបារម្ភផ្នែកហិរញ្ញវត្ថុ មិនមែនគ្រាន់តែជាកត្តាជំរុញពីខាងក្រៅតែប៉ុណ្ណោះទេ ប៉ុន្តែជនរួចពីរងគ្រោះជាស្ត្រី បានដាក់សម្ពាធយ៉ាងច្រើនទៅលើខ្លួនឯងក្នុងការក្លាយជា "កូនស្រីល្អ" និង "ស្ត្រីល្អ"។ ជាទូទៅ កូនប្រុសមិនមានអារម្មណ៍ទទួលខុសត្រូវសងបំណុលឪពុកម្តាយរបស់ពួកគេឡើយ មានតែខ្លួនឯងប៉ុណ្ណោះ។ ជនរួចពីរងគ្រោះជាស្ត្រីម្នាក់បាននិយាយថា "យើងជាស្ត្រី យើងមានទំនួលខុសត្រូវជាច្រើនក្រោយពេលមានកូន...យើងជាស្ត្រី ត្រូវតែគិតគ្រប់ទាំងអស់ ទាំងការគិត និងការសន្សំប្រាក់...ថ្ងៃនេះ មិនទាន់គ្រប់គ្រាន់ឡើយ។ ដូច្នេះ ថ្ងៃស្អែក យើងត្រូវតែគិត... យើងត្រូវតែគិត ហើយធ្វើ... យើងត្រូវតែគិតឲ្យបានជិតដល់ គ្រប់ជ្រុងជ្រោយ និងឆែកមើលខ្លួនឯង បើយើងចង់ឲ្យគ្រួសាររបស់យើងល្អ យើងគួរតែចាប់ផ្តើមឲ្យល្អចេញពីយើងទៅ។" ការនេះហាក់ដូចជាផ្ទុយពីលទ្ធផលស្ទង់មតិ ដែលបានបង្ហាញថា អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបានជឿថា បុរសពេញវ័យ មានទំនួលខុសត្រូវច្រើនជាងស្ត្រីពេញវ័យក្នុងការផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេ។

### *៤.៣.២ ការរំពឹងទុកមិនច្បាស់លាស់ និងក្តីបារម្ភសម្រាប់ថ្ងៃអនាគត*

ផែនការអនាគត ទទួលរងឥទ្ធិពលយ៉ាងខ្លាំង ហើយជារឿយៗត្រូវផ្លាស់ប្តូរពីកំឡុងពេលការចុះប្រមូលពត៌មានមួយទៅការចុះប្រមូលពត៌មានមួយនៅក្នុងកំឡុងពេលនៃការសិក្សាស្រាវជ្រាវ ហើយអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវជាច្រើននាក់មិនមានភាពច្បាស់លាស់ឡើយអំពីមហិច្ឆតារបស់ពួកគេ។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវមួយចំនួនបាននិយាយនូវមហិច្ឆតាការងារខុសៗគ្នានៅក្នុងគ្រប់ការចុះប្រមូលពត៌មានរបស់អ្នកស្រាវជ្រាវ ប៉ុន្តែមិនដែលស្វែងរងការបណ្តុះបណ្តាលវិជ្ជាជីវៈការងារ ឬការងារនៅក្នុងវិស័យដែលខ្លួនបានទទួលការបណ្តុះបណ្តាលទាំងនោះឡើយ។ ជនរួចពីរងគ្រោះជាច្រើនហាក់ដូចជាមិនអាចទាញនូវភាពទាក់ទងគ្នារវាង "ក្តីស្រមៃ" និង "មហិច្ឆតាការងារពិត"។

ប្រធានបទនេះ ត្រូវបានបញ្ជាក់នៅក្នុងការសិក្សារបស់                    ស្តីពីការផ្តល់អំណាចសេដ្ឋកិច្ច ដល់ជនរួចពីរងគ្រោះពីការជួញដូរ៖

> បុគ្គលដែលត្រូវគេជួញដូរមួយចំនួន មានការរំពឹងទុកមិនពិតប្រាកដអំពីជម្រើសនៃការងាររបស់ពួកគេ។ ពួកគេអាចចង់បានការងារ ដែលមិនត្រូវទៅនឹងជំនាញ/ការអប់រំរបស់ពួកគេ ឬរំពឹងចង់បានប្រាក់ខែខ្ពស់ដែលមិនពិតប្រាកដ។ អ្នកខ្លះទៀតក៏មានការយល់ឃើញមិនពិតប្រាកដអំពីការងារ ដែលពួកគេរំពឹងចង់ធ្វើ និងមានការជំរុញចិត្តដែលភាន់ច្រលំ... ការនេះអាចនាំទៅរកការមួម៉ៅ និងការខកចិត្ត ដែលជះឥទ្ធិពលអវិជ្ជមានទៅលើសមត្ថភាពរបស់ពួកគេ ហើយទទួលយកការងារដែលសក្តិសម (ទំព័រ ៣១)។

ហេតុផលអំពីការអេសមត្ថភាពក្នុងការរៀបចំផែនការដែលពិតប្រាកដសម្រាប់ថ្ងៃអនាគត អាចជាការដែលជនរួចពីរងគ្រោះកំពុងតែធ្វើការសម្រាប់តែរស់។ បើបុគ្គលម្នាក់ផ្តោតអារម្មណ៍លើការបានតែមួយគ្រប់សម្រាប់មួយថ្ងៃ ឬពីមួយសប្តាហ៍ទៅមួយសប្តាហ៍ នោះគាត់អាចមិនមានសមត្ថភាពពេញលេញ ឬមានផែនការច្បាស់លាស់សម្រាប់ការងារ ឬឱកាសបន្ទាប់ឡើយ។ ពិតណាស់ ពេកសញ្ញានៃក្តីបារម្ភផ្នែកហិរញ្ញវត្ថុ ដែលបង្ហាញចេញនៅក្នុងការពិភាក្សាជាក្រុមមួយក្នុងចំណោមក្រុមដទៃទៀត រួមមានការខ្វះការជំរុញចិត្ត និងការអស់សង្ឃឹម។

ជារឿយៗ ពួកគេឆ្លើយសំណួរអំពីក្តីស្រមៃរយៈពេល៥ឆ្នាំ ដោយមានគំនិតអំពីការងារ ឬវគ្គបណ្តុះបណ្តាលមួយ ប៉ុន្តែមានមនុស្សតិចតួចណាស់ ដែលគិតបានវែងឆ្ងាយដេញតាមឱកាស ដែលនាំពួកគេទៅសម្រេចក្តីស្រមៃរបស់ពួកគេ។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវជាច្រើននាក់ចង់បើកហាងតូចមួយ៖ "ដោយសារតែការងារនេះ យើងអាចនៅផ្ទះបាន"។ (អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវមេអំបៅរយៈពេលវែង ( ) អំពីហេតុផលដែលនាងចង់បើកហាងលក់ចាប់ហួយ ជាជាងធ្វើការនៅក្នុងកម្មវិធីជំនួយ )។ ម្នាក់ទៀតបាននិយាយថា ការបើកតូបលក់ចាប់ហួយនៅផ្ទះរបស់នាង នឹងអនុញ្ញាតឲ្យនាងអាចរកលុយបានខ្លះ ខណៈពេលដែលនាងនៅផ្ទះមើលថែកូនរបស់នាង។

## ៤.៤ ភាពមិនមានលំនឹងផ្នែកហិរញ្ញវត្ថុរបស់ជនរួចពីរងគ្រោះ និងបំណុល

ការកំណត់អារម្មណ៍ភ័យព្រួយជុំវិញផ្នែកហិរញ្ញវត្ថុ គឺជាបទពិសោធន៍អស្ថេរភាពហិរញ្ញវត្ថុដ៏ពិតរបស់ជនរួចពីរងគ្រោះ។ ផ្នែកនេះបង្ហាញពីការរកប្រាក់ និងបំណងចិត្តរបស់ជនរួចពីរងគ្រោះសម្រាប់ការរកប្រាក់ចំណូលសម្រាប់ថ្ងៃអនាគត ក៏ដូចជាបទពិសោធន៍នៃបំណុលរបស់ជនរួចពីរងគ្រោះ។

### *៤.៤.១ អស្ថេរភាពហិរញ្ញវត្ថុក្នុងពេលបច្ចុប្បន្ន និងពេលអនាគត*

នៅក្នុងការស្ទង់មតិ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវត្រូវបានសួរអំពីចំនួនម៉ោងនៃការងារដែលពួកគេធ្វើ និងចំនួនលុយដែលពួកគេរកបានក្នុងមួយខែនៅក្នុងការងារបច្ចុប្បន្នរបស់ពួកគេ។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ៥៩នាក់បានឆ្លើយហើយប្រាក់ខែជាមធ្យម គឺ ៦០ ហើយពួកគេបានធ្វើការជាមធ្យមចំនួន ៦០ម៉ោងក្នុងមួយខែ (មនុស្សជាច្រើនធ្វើការជាមួយកម្មវិធីជំនួយរបស់គេជាប្រភេទការងារក្រៅម៉ោង មិនទៀងទាត់ ឬមួយរយៈពេល ខណៈពេលដែលទៅរៀនផង និងស្នាក់នៅក្នុងមណ្ឌលផង)។

ទិន្នន័យបែបគុណភាពក៏កត់ត្រាចំនួនប្រាក់ដែលជនរួចពីរងគ្រោះរកបានក្នុងរយៈពេលនៃការសិក្សា ក្រៅពីនៅក្នុងការស្ទង់មតិខាងលើ។ ប្រាក់ខែប្រចាំខែ ត្រូវបានកត់ត្រាសម្រាប់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចំនួន៣៤នាក់។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទាំង៣៤នាក់នេះ បានបង្ហាញពីប្រាក់ខែប្រចាំខែរបស់ពួកគេ យ៉ាងហោចណាស់នៅក្នុងឆ្នាំសិក្សារយៈពេលពីរឆ្នាំ។ ប្រាក់ខែជាមធ្យមសម្រាប់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទាំង ៣៤នាក់ ត្រូវបានរៀបរាប់នៅក្នុងតារាងខាងក្រោម៖

| ឆ្នាំ | ចំនួននៃជនរួចពីរងគ្រោះ ដែលបានបង្ហាញប្រាក់ខែ | ប្រាក់ខែជាមធ្យម |
|---|---|---|
| ២០១១ | ៥ | ៥៧ដុល្លារ |
| ២០១២ | ១៨ | ៩៧ដុល្លារ |
| ២០១៣ | ២៧ | ១២០ដុល្លារ |
| ២០១៤ | ២៥ | ១២២ដុល្លារ |
| ២០១៥ | ១២ | ១៤២ដុល្លារ |

**តារាង 16៖** ប្រាក់ខែប្រចាំខែជាមធ្យម

តួលេខទាំងនេះ បង្ហាញថា ជនរួចពីរងគ្រោះដែលបន្តមានការងារធ្វើក្រោយពេលធ្វើសមាហរណកម្ម កំពុងតែមានប្រាក់ខែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ជនរួចពីរងគ្រោះពាក់កណ្ដាល បាននិយាយនៅពេលមួយថា ពួកគេមិនបានរកលុយគ្រប់គ្រាន់ ដើម្បីទូទាត់ការចំណាយរស់នៅរបស់ពួកគេឡើយ ហើយហេតុផលក្នុងការឈប់ពីការងារ ជារឿយៗ ពាក់ព័ន្ធជាមួយនឹងប្រាក់ខែទាប ឬប្រាក់ខែមិនគ្រប់គ្រាន់។ ជនរួចពីរងគ្រោះតិចតួចបំផុត ចុងបញ្ចប់លែងមានការងារធ្វើ (ឬបើពួកគេមាន ពួកគេមិននៅធ្វើឡើយ) ប៉ុន្តែការងារដែលពួកគេធ្វើ មិនបានបំពេញតម្រូវការហិរញ្ញវត្ថុរបស់ពួកគេឡើយ។ ការនេះត្រូវបានបញ្ជាក់នៅក្នុងផ្នែករំលឹកអក្សរសាស្ត្រជុំវិញតម្រូវការផ្នែកសង្គមសេដ្ឋកិច្ចរបស់ជនរួចពីរងគ្រោះពីការជួញដូរ៖ "ទោះបីជាពេលដែលអ្នកឆ្លើយ រកបានការងារក៏ដោយ ក៏ប្រាក់ខែមិនតែងតែគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការសម្រាប់ការរស់នៅរបស់ពួកគេដែរ។" (
ទំព័រ ២៦

ភ្ជាប់ទៅនឹងការនេះ គឺជាភាពអសមត្ថភាពរបស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវក្នុងការរៀបចំផែនការអនាគត រួមទាំងការខ្វះជំនាញរៀបចំគម្រោងថវិកា និងជំនាញរៀបចំហិរញ្ញវត្ថុ។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវមួយចំនួនបាននិយាយអំពីការចង់បានប្រាក់ចំនូលតិចៗប្រចាំថ្ងៃ (ដូចជា ប្រាក់ធីប ( ) ពីការធ្វើការនៅក្នុងខារ៉ាអូខេ ឬបដិសណ្ឋារកិច្ច) ដើម្បីទទួលបានប្រាក់ចំណូលប្រចាំខែច្រើន។ លើសពីនេះទៅទៀត ទោះបីជាជនរួចពីរងគ្រោះភាគច្រើន បានបង្ហាញពីទម្រង់ខ្លះនៃការរៀបចំផែនការ ឬក្ដីស្រមៃអនាគតក៏ដោយ ក៏មនុស្សតិចតួចបំផុតបោះជំហានធ្វើដំណើរ ដើម្បីសម្រេច ឬធ្វើការឆ្ពោះទៅសម្រេចមហិច្ឆតារបស់ពួកគេ។ ជនរួចពីរងគ្រោះជាច្រើនបានលើកឡើងថា ការងារដ៏ប្រពៃរបស់ពួកគេ គឺជាការបើកតូបលក់ចាប់ហួយនៅក្នុងផ្ទះរបស់ពួកគេ ដែលអាចផ្ដល់ប្រយោជន៍ពីរ មួយគឺគាត់អាចនៅផ្ទះ និងមួយទៀតអាចរកបានប្រាក់ចំណូលប្រចាំថ្ងៃ។

ការអសមត្ថភាពរៀបចំផែនការអនាគត ផ្សារភ្ជាប់ទៅនឹងប្រាក់ចំណូលមិនគ្រប់គ្រាន់ និងអសមត្ថភាពក្នុងការរៀបចំគម្រោងថវិកា មានន័យថា ជនរួចពីរងគ្រោះងាយរងគ្រោះនឹងគ្រោះអាសន្នពីខាងក្រៅ ហើយមិនអាចកសាងមូលធន ដើម្បីធ្វើឲ្យជីវភាពគ្រួសាររបស់ពួកគេមានភាពប្រសើរឡើងបានឡើយ។ ដូច ពន្យល់ថា៖ "ការសម្រេចបានស្ថេរភាពហិរញ្ញវត្ថុ តម្រូវឲ្យមាន មិនគ្រាន់តែប្រាក់ចំណូលដើម្បីទូទាត់ថ្លៃចំណាយសម្រាប់ការរស់នៅប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានទ្រព្យធនបម្រុងទុកសម្រាប់ពេលដែលមានគ្រោះអាសន្នកើតឡើង សម្រេចគោលដៅហិរញ្ញវត្ថុ និងកសាងសន្តិសុខរយៈពេលវែងផងដែរ" (ទំព័រទី៣)។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបាននិយាយម្ដងទៀតអំពីទំនួលខុសត្រូវគ្រួសារថា៖ "ថ្ងៃនេះ យើងមានគ្រប់គ្រាន់ ប៉ុន្តែក្នុងពេលដដែល យើងត្រូវគិតអំពីអ្វីដែលត្រូវធ្វើនៅថ្ងៃស្អែក និងពេលដែល

ថ្ងៃស្អែកមកដល់ យើងនឹងគិតអំពីវាម្តងទៀតសម្រាប់ថ្ងៃខានស្អែក និងថ្ងៃខានស្អែកទៀត។ យើងត្រូវតែត្រៀមខ្លួនឲ្យបានល្អ!" ជាអកុសល មនុស្សតិចតួចណាស់បានបង្ហាញថា ពួកគេអាច "ត្រៀមខ្លួនបានល្អ" ដែលជាហេតុនាំឲ្យពួកគេលិចលង់ក្នុងបំណុលជាបន្តបន្ទាប់។

### ៤.៤.២ អារម្មណ៍ចំពោះបញ្ហាបំណុល

ការស្ទង់មតិពីឆ្នាំ ២០១១ និង ២០១២ សួរសំណួរជាច្រើន ទាក់ទងនឹងការទទួលបាន និងការសងបំណុល ទាំងបំណុលផ្ទាល់ខ្លួន និងបំណុលគ្រួសាររបស់ខ្លួន។ សំណួរមួយទាក់ទងនឹងអារម្មណ៍របស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវអំពីស្ថានភាពបំណុលមិនច្បាស់លាស់។ សំណួរនៃការស្ទង់មតិ និងចម្លើយ មានដូចខាងក្រោម៖

សំណួរ៖ សូមស្រមៃថា បើគ្រួសាររបស់អ្នកជំពាក់បំណុលគេ៖ តើអ្នកគិតថា អ្នកនឹងមានអារម្មណ៍ដូចម្តេចចំពោះការជំពាក់បំណុលគេនោះ?

ចម្លើយផ្សេងៗ៖ បារម្ភថាតើខ្ញុំនឹងសងបំណុលគេដោយរបៀបណា
ខ្វល់ខ្វាយ ប៉ុន្តែ មិនព្រួយបារម្ភពីរបៀបដែលខ្ញុំនឹងសងបំណុលគេឡើយ
មិនដឹង
មិនខ្វល់ (មិនបារម្ភ)

ដូចជាបានឃើញនៅក្នុងតារាងខាងក្រោម អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវភាគច្រើនបាននិយាយថា ពួកគេនឹងបារម្ភអំពីការសងបំណុលគេ បើគ្រួសាររបស់ខ្លួន (មិនចាំបាច់ជាពួកគេផ្ទាល់ឡើយ) ជំពាក់បំណុលគេ។ លទ្ធផលនេះ មានភាពដូចគ្នា ដោយមិនប្រកាន់ពីភេទឡើយ។




តារាង 17៖ អារម្មណ៍ផ្ទាល់ខ្លួនអំពីបំណុលគ្រួសារ

សំណួរទាក់ទងនឹងបំណុលផ្សេងទៀត ដែលមាននៅក្នុងការស្ទង់មតិ គឺជាទំនួលខុសត្រូវ និងជម្រើសទាក់ទងនឹងបំណុលគ្រួសារ និងបំណុលផ្ទាល់ខ្លួន។ តារាងខាងក្រោម រៀបរាប់នូវចម្លើយចំពោះសំណួរទាំងនេះ។

| សំណួរ | ភាគរយដែលឆ្លើយថា "មែន" | ភាគរយ ដែលឆ្លើយថា "ទេ" |
|---|---|---|
| តើអ្នកមានអារម្មណ៍ថា អ្នកមានជម្រើសក្នុងការជំពាក់បំណុលគេ ឬមិនជំពាក់ដែរឬទេ? *ចំនួន ៣៣* | ៦៩,៧ | ៣០,៣ |
| តើអ្នកធ្លាប់ទទួលខុសត្រូវក្នុងការសងបំណុលកាលពីឆ្នាំមុនដែរ ឬទេ? *ចំនួន ៣៣* | ៤៨,៥ | ៥១,៥ |
| តើមាននរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នក ទទួលខុសត្រូវសងបំណុលគេកាលពីឆ្នាំមុនៗដែរឬទេ? *ចំនួន ៧៧* | ៤៩,៣ | ៥០,៧ |

**តារាង 18៖** ទំនួលខុសត្រូវ និងអ្នកទទួលខុសត្រូវនៅក្នុងបំណុលគ្រួសារ

ដូចបានឃើញខាងលើ ភាគច្រើននៃអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបាននិយាយថា ពួកគេមានអារម្មណ៍ថា ពួកគេបានម្ចាស់ការលើថាតើពួកគេត្រូវជំពាក់បំណុលគេ ឬទេ។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវត្រូវបានបែងចែកជាពាក់កណ្តាលថាតើពួកគេ ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់ពួកគេ ត្រូវទទួលខុសត្រូវសងបំណុលគេនៅឆ្នាំមុនៗ ឬទេ។ សូមកត់សំគាល់ថា ការស្ទង់មតិទាំងនេះ ទទួលបាននៅជិតដើមឆ្នាំនៃកំឡុងពេលសិក្សា ពេលដែលអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវភាគច្រើន កំពុងតែរស់នៅក្នុងមណ្ឌលថែទាំ។ តារាងខាងក្រោម រៀបរាប់នូវចម្លើយមួយចំនួន ទាក់ទងនឹងអារម្មណ៍របស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវជុំវិញការមាន និងការសងបំណុល។

| អារម្មណ៍អំពីបំណុល | ចំនួននៃជនរងគ្រោះដែលបានបង្ហាញពីប្រធានបទនេះ | ភាគរយនៃជនរងគ្រោះដែលបានធ្វើសមាហរណកម្មសរុប |
|---|---|---|
| អារម្មណ៍អំពីទំនួលខុសត្រូវក្នុងការសងបំណុល | ៤៨ | ៦២,៣ |
| ក្តីបារម្ភ ទាក់ទងនឹងបំណុល | ២៧ | ៣៥,១ |
| ការរុកគួនរបស់ម្ចាស់បំណុល | ៨ | ១០,៤ |

**តារាង 19៖** ក្តីបារម្ភទាក់ទងនឹងបំណុល ចំនួន ៧៧នាក់)

ជាងពាក់កណ្តាលនៃជនរងគ្រោះ បានបង្ហាញអារម្មណ៍ទទួលខុសត្រូវសងបំណុល ទោះបីវាជាបំណុលរបស់គេ ឬបំណុលគ្រួសាររបស់ពួកគេក៏ដោយ។ លើសពីនេះទៅទៀត ជាងមួយភាគបីនៃជនរងគ្រោះ បានបង្ហាញពីក្តីបារម្ភទាក់ទងនឹងការមានបំណុល និងការសងបំណុលគេ។ ជិត ១០% បាននិយាយអំពីក្តីបារម្ភ និងការភ័យខ្លាចជុំវិញនឹងម្ចាស់បំណុលដែលតាមទារបំណុលរបស់ពួកគេ។ ទាក់ទងនឹងសូចនាករខាងលើ គឺជាប្រយោគដោយផ្ទាល់អំពីការមិនមានទទួលខុសត្រូវសងបំណុល៖ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ១២នាក់ (១៥.៦%) បាននិយាយថា ពួកគេមិនទទួលខុសត្រូវសងបំណុលឡើយ។ លើសពីនេះទៅទៀត ក្នុងចំណោមអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ២៧នាក់ ដែលបានបង្ហាញពីក្តីបារម្ភអំពីបំណុល អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបួននាក់ (១៤.៨%) ក៏បានបង្ហាញពីភាពភ័យខ្លាចអំពីបំណុលផងដែរ ហើយអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវម្នាក់ បានបង្ហាញតែពីភាពភ័យខ្លាច (មិនមែនក្តីបារម្ភ) អំពីបំណុលតែប៉ុណ្ណោះ។

## ៤.៤.៣ វដ្តនៃបំណុល

ការមានបទពិសោធន៍នៃបំណុល ជនរួចពីរងគ្រោះភាគច្រើន បាននិយាយអំពីការលំបាក។ បំណុល គឺជាក្តីបារម្ភផ្នែកហិរញ្ញវត្ថុមួយ ដែលត្រូវដោះស្រាយជាបន្ទាន់សម្រាប់ជនរួចពីរងគ្រោះភាគច្រើន។ ៦២% បានបង្ហាញអារម្មណ៍ទំនួលខុសត្រូវសងបំណុល ៥៥%មានបំណុល ហើយ ៦៥% បាននិយាយថា ឪពុកម្តាយរបស់ពួកគេ ជំពាក់បំណុល។ បំណុលនៅក្នុងចំណោមជនរួចពីរងគ្រោះ និងគ្រួសាររបស់ពួកគេ មិនមែនជាព្រឹត្តិការណ៍តែមួយនោះទេ។ បំណុលនៅក្នុងគ្រួសារទាំងនេះ គឺជាវដ្តដែលមិនចេះអស់ ដែលពួកគេហាក់ដូចជាពិបាកនឹងដកខ្លួនចេញផុតពីបំណុល។ តារាងខាងក្រោម រៀបរាប់ពីបទពិសោធន៍បច្ចុប្បន្ននៃបំណុលនៅទូទាំងកំឡុងពេលនៃការសិក្សា។

| បទពិសោធន៍នៃបំណុល | ចំនួននៃជនរួចពីរងគ្រោះ ដែលបានបង្ហាញប្រធានបទនេះ | ភាគរយនៃជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្មសរុប |
|---|---|---|
| ជនរួចពីរងគ្រោះដែលកំពុងតែសងបំណុលរបស់ខ្លួន | ៤២ | ៥៤ ៥ |
| ឪពុកម្តាយរបស់ជនរងគ្រោះ ដែលកំពុងតែជំពាក់បំណុល | ៥០ | ៦៤ ៩ |

**តារាង 20៖** បទពិសោធន៍នៃបំណុល (ចំនួន=៧៧នាក់)

ពេលខ្លះ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបានបង្ហាញពីចំនួននៃបំណុលដែលពួកគេកំពុងតែសង។ មានតែករណីចំនួន ៤១នៅក្នុងទិន្នន័យបែបគុណភាព ដែលអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបានបង្ហាញពីចំនួននៃបំណុលផ្ទាល់ខ្លួនដែលពួកគេកំពុងតែជំពាក់សព្វថ្ងៃ។ ចំនួនជាមធ្យម ប្រហែល៣៦០ដុល្លារ។ មាន២៥ករណី ដែលអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបានបង្ហាញពីចំនួននៃបំណុលឪពុកម្តាយរបស់ពួកគេ ដែលពួកគេកំពុងតែសងជារឿយៗ។ ចំនួនជាមធ្យមមានប្រហែលជា៩៦៥ដុល្លារ។ លើសពីនេះទៅទៀត អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវភាគច្រើន ដែលបាននិយាយអំពីការមានបំណុល ឬកំពុងតែសងបំណុលឪពុកម្តាយរបស់ពួកគេ បាននិយាយអំពីវានៅក្នុងបទសម្ភាសន៍ជាច្រើន និងជាច្រើនឆ្នាំ ដោយបង្ហាញថា បំណុល បានកំពុងតែកើនឡើង និងសងម្តងហើយម្តងទៀត។

លទ្ធផលបង្ហាញថា ភាគច្រើន អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវសុំឲ្យគ្រួសាររបស់ពួកគេទៅខ្ចីលុយ ពេលដែលពួកគេត្រូវការលុយជាបន្ទាន់ ហើយវានាំទៅរកជំនឿខុសឆ្គង ដែលជឿថា ជនរួចពីរងគ្រោះទាំងនេះ មាននូវបណ្តាញគាំទ្រ ដែលពួកគេអាចពឹងពាក់បាន ប៉ុន្តែចុងបញ្ចប់ គ្រួសារទាំងមូល មិនមែនគ្រាន់តែអ្នករួចពីរងគ្រោះប៉ុណ្ណោះទេ កំពុងតែធ្វើដំណើរឆ្លងកាត់វដ្តនៃបំណុលនេះ។ ជារឿយៗនៅក្នុងបទសម្ភាសន៍ ជនរួចពីរងគ្រោះមិនបានបញ្ជាក់ច្បាស់ថានរណាដែលពួកគេកំពុងតែខ្ចីលុយនោះទេ ប៉ុន្តែសេចក្តីសន្និដ្ឋាននោះគឺថា ភាគច្រើន ពួកគេកំពុងតែខ្ចីលុយពីអ្នកចងការប្រាក់តាមភូមិ។

លើសពីនេះទៅទៀត ប្រភេទធំៗទាំងបួននៃបំណុល ដែលបានបង្ហាញដោយរួចពីរងគ្រោះ មានដូចជា ការចំណាយសម្រាប់ការរស់នៅ ការចំណាយសម្រាប់ការព្យាបាលជម្ងឺ គ្រួសារ និងការជួសជុលផ្ទះ ឬទ្រព្យសម្បត្តិ។ ការនេះបង្ហាញថា ជារឿយៗ បំណុលត្រូវបានបង្កឡើង ដោយសារតែគ្រួសារមិនមានប្រាក់សន្សំ ឬបណ្តាញសុវត្ថិភាពសម្រាប់ការចំណាយជាទៀងទាត់ និងហេតុការណ៍មិនបានរំពឹងទុក។ ប្រភេទនៃបំណុលនៃ "គ្រួសារ" រួមមាន ពេលដែលជនរួចពីរងគ្រោះបានខ្ចីលុយផ្ញើទៅកាន់ឪពុកម្តាយរបស់ពួកគេ ដើម្បីឲ្យឪពុកម្តាយរបស់ពួកគេអាចបង់ថ្លៃសម្រាប់ការចំណាយរស់នៅ ឬបំណុលផ្ទាល់ខ្លួនរបស់ពួកគេ។ ការនេះក៏បង្ហាញពីភាពតភ្ជាប់រវាងការសងគុណ និងបំណុលនៅក្នុងជនរួចពីរងគ្រោះ ដែលនឹងនាំ

ឲ្យពួកគេចូលក្នុងបំណុល ដើម្បីលើកកិត្តិយសឪពុកម្តាយរបស់ពួកគេ ដោយសងបំណុលនៅពេលក្រោយ។ ការសងបំណុលឪពុកម្តាយ ក៏ជាការរំពឹងទុកនៃការសងគុណឪពុកម្តាយផងដែរ ដូចអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវម្នាក់បានលើកឡើងពីការរងទុក្ខពីអារម្មណ៍ពិរុទ្ធភាព ហើយជារឿយៗពិចារណាចង់ឈប់រៀន ដើម្បីផ្គត់ផ្គង់លុយច្រើនថែមទៀតដល់ឪពុកម្តាយរបស់ពួកគេ៖ "គ្រប់ពេល [ឪពុកម្តាយ] ខ្ចីលុយពីអ្នកដទៃ មនុស្សវិនិច្ឆ័យខ្ញុំថា ខ្ញុំមានការងារមួយ ប៉ុន្តែមិនផ្គត់ផ្គង់ដល់គ្រួសារ។"

និង បានរកឃើញបំណុលក្លាយជាវដ្តដ៏ជាប់ក្នុងផ្នត់គំនិតនៃគ្រួសាររបស់ជនរួចពីរងគ្រោះពីការជួញដូរ ជាពិសេសនៅក្នុងសហគមន៍វៀតណាមក្នុងប្រទេសកម្ពុជា។ ក៏បានរកឃើញថា បំណុលអាចក្លាយជាសំណល់មួយពីបទពិសោធន៍នៃការជួញដូរ៖ "ជារឿយៗ ជនរួចពីរងគ្រោះមាននូវបំណុលជាប់លាប់ពីបទពិសោធន៍នៃការជួញដូររបស់ពួកគេ ជាបំណុលដែលកើតចេញពីការចំណាយទាក់ទងនឹងការចំណាកស្រុក ឬ "ការចំណាយ" ដែលជំពាក់ដល់អ្នកជួញដូរ ក្នុងពេលនៃការកេងប្រវ័ញ្ច" (ទំព័រ ២៤)។

មើលទៅកាន់ស្ត្រី ដែលពាក់ព័ន្ធនៅក្នុងការរកស៊ីផ្លូវភេទ ជាកត្តានៅក្នុងទំនាក់ទំនងសេដ្ឋកិច្ចជាច្រើន ហើយបង្កើតគំនិត "អ្នករកស៊ីផ្លូវភេទ ជាប់នៅក្នុងទំនាក់ទំនងជាមួយម្ចាស់បំណុលមិនផ្លូវការ ឈ្មួញចំណាកស្រុកផ្លូវភេទ និយោជិតនៅក្នុងឧស្សាហកម្មផ្លូវភេទ គ្រួសាររបស់ពួកគេ និងអតិថិជនរបស់ពួកគេ" (ទំព័រ ៤)។ ទោះបីជាស្ត្រីម្នាក់បានពាក់ព័ន្ធនៅក្នុងឧស្សាហកម្មផ្លូវភេទ ដោយការជ្រើសរើស ការបង្ខំ ឬដោយគិតគូរពីការប្រថុយប្រថានក៏ដោយ ក៏ទំនាក់ទំនងទាំងនេះ ជារឿយៗសំខាន់នៅក្នុងជីវិតរបស់នាង។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវម្នាក់នៅក្នុងការសិក្សាបច្ចុប្បន្ន បានត្រលប់មកវិញវាវង ការងារក្នុងកម្មវិធីជំនួយរបស់នាង និងការធ្វើការនៅក្នុងខារ៉ាអូខេ អាស្រ័យលើពេលវេលា និងចំនួនលុយដែលឪពុកម្តាយរបស់នាង ឬគាត់ជំពាក់បំណុលគេ។ នាងចង់ធ្វើការនៅក្នុងការងារ របស់កម្មវិធីជំនួយ ប៉ុន្តែភាពទាក់ទាញនៃ "ការរកលុយបានស្រួល" នៅក្នុងខារ៉ាអូខេ ( ) បានចូលរួមនៅក្នុងវដ្តនៃបំណុល និងការសងបំណុលដែលបន្តមាន។

ការលេងល្បែងស៊ីសង ក៏ត្រូវបានលើកឡើងដោយជនរួចពីរងគ្រោះជាច្រើននាក់ថា ជាឫសគល់នៃបំណុលផងដែរ។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវមួយចំនួនបាននិយាយអំពីការញៀនរបស់ឪពុកម្តាយជាមួយល្បែងស៊ីសង។ ម្នាក់ទៀតបានប្រាប់ពីបញ្ហានៃការលេងល្បែងស៊ីសងរបស់នាងផ្ទាល់៖ "ការលេងល្បែងស៊ីសង គឺជាកត្តាដ៏មានឥទ្ធិពលបំផុតដែលនាំឲ្យគ្រប់គ្នាជំពាក់បំណុលគេ។ ដើម្បីជួសជុលផ្ទះ ខ្ញុំអាចសន្សំប្រាក់បាន...ប៉ុន្តែ ខ្ញុំមិនអាចសន្សំប្រាក់មកលេងល្បែងបានឡើយ។ អ្នកដឹងទេ ខ្ញុំធ្លាប់ជាអ្នកមានម្នាក់កាលពីអតីតកាល។ ប៉ុន្តែឥឡូវ ខ្ញុំធ្លាក់ខ្លួនក្រ ដោយសារតែខ្ញុំញៀននឹងល្បែង។ ល្បែងស៊ីសង អាចបំផ្លាញទំនាក់ទំនងរបស់អ្នក រំខានដល់គ្រួសារ និងការងារ ហើយនាំទៅរកភាពអន្តរាយផ្នែកហិរញ្ញវត្ថុ។" ទម្រង់មួយទៀតនៃល្បែងស៊ីសង អាចជាតុងទីន ជាទម្រង់មិនផ្លូវការមួយនៃការសន្សំប្រាក់ និងក្រុមសន្សំប្រាក់ដែលមាននៅទូទាំងប្រទេសកម្ពុជា។ វាមិនមែនជាស្ថាប័នស្របច្បាប់ឡើយ ហើយវាអាចមានប្រយោជន៍ដល់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវមួយចំនួន ដែលប្រើវា ដើម្បីសន្សំប្រាក់។ ទោះបីយ៉ាងណាក៏ដោយ ជារឿយៗ មនុស្សហៅក្រុមនោះថាជា "ការលេងតុងទីន" ដែលចង់សំដៅថា វាអាចក្លាយជាទម្រង់មួយនៃការលេងល្បែងស៊ីសង ហើយជារឿយៗ ជនរួចពីរងគ្រោះនិយាយអំពីការជំពាក់បំណុលកាន់តែច្រើន ពេលដែលពួកគេចូលរួមលេងក្នុងក្រុមទាំងនេះ ជាងការចំណេញពីវា។

## ៤.៥ ជនរួចពីរងគ្រោះភាគច្រើនមិនបានត្រៀមខ្លួនសម្រាប់ការងារ

វាមាននូវទិន្នន័យដ៏ច្រើនអំពីការត្រៀមខ្លួនរបស់ជនរួចពីរងគ្រោះនៅក្នុងការអប់រំក្រោយពេលថែទាំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងទីផ្សារការងារ។ យ៉ាងណាក៏ដោយ សម្រាប់គោលបំណងនៃការសិក្សាវាយតម្លៃនេះ មានតែប្រធានបទពីរប៉ុណ្ណោះដែលត្រូវបានសិក្សា ដែលទាក់ទងនឹងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ។ ប្រធានបទទីមួយ គឺថាតើការបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំខ្លួនជនរួចពីរងគ្រោះសម្រាប់ទីផ្សារការងារធម្មតា ហើយប្រធានបទទីពីរ គឺជាអត្ថប្រយោជន៍ និងឧបសគ្គនៃការធ្វើការសម្រាប់កម្មវិធីក្រោយការមើលថែ ឬអាជីវកម្មបែបសង្គមនៃកម្មវិធីមណ្ឌលថែទាំ ក្រោយពេលការធ្វើសមាហរណកម្ម។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចំនួន ៣៦នាក់ បាននិយាយថា ពួកគេបានធ្វើការនៅក្នុងអាជីវកម្មបែបសង្គមនៃកម្មវិធីមណ្ឌលថែទាំ ក្នុងកំឡុងពេលធ្វើសមាហរណកម្ម ហើយក្នុងចំណោមនោះ មានអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ១៣នាក់ (៣៦%) បាននិយាយថា មានការងារតែមួយ កំឡុងពេលនៃការសិក្សា (ឧទា. ពួកគេបានស្នាក់នៅក្នុងការងារអាជីវកម្មបែបសង្គមនៃកម្មវិធីមណ្ឌលថែទាំ បន្ទាប់ពីធ្វើសមាហរណកម្មរួច រហូតដល់ពេលបច្ចុប្បន្ន)។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ២៣នាក់ផ្សេងទៀត មានការងារជាមធ្យមចំនួនបីក្នុងមួយនាក់ នៅកំឡុងពេលនៃការសិក្សាវាយតម្លៃទាំងមូល។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចំនួន ៣១នាក់ នៅក្នុងការសិក្សាប៉ាន់ប្រមាណ បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមួយចំនួនមុនពេល ឬក្រោយពេលនៃការធ្វើសមាហរណកម្ម។ ការសិក្សាប៉ាន់ប្រមាណក៏តាមដានថាតើអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបានប្រើប្រាស់ជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ពួកគេ នៅក្នុងការងាររបស់ពួកគេ ក្រោយពេលធ្វើសមាហរណកម្មដែរឬអត់។ ឧទាហរណ៍ បើការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ពួកគេ ផ្តោតលើការដេរ ដូច្នេះសូចនាករធ្វើការតាមដានថាតើការងាររបស់ពួកគេទាក់ទងនឹងការដេរដែរឬអត់ ដូចជា ការធ្វើការនៅក្នុង រោងចក្រកាត់ដេរ ឬអាជីវកម្មកាត់ដេរតាមផ្ទះ។ សូចនាករនេះ ត្រូវបានសិក្សាសម្រាប់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចំនួន ២៧នាក់។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ១៨នាក់ បានប្រើប្រាស់ជំនាញវិជ្ជាជីវៈដែលគេបានរៀនតាមរបៀបណាមួយក្នុងការងាររបស់ពួកគេ ក្នុងកំឡុងពេលនៃការធ្វើសមាហរណកម្ម ហើយ ១៧នាក់ផ្សេងទៀត មិនបានប្រើប្រាស់ជំនាញទាំងនោះឡើយ។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចំនួន ៧នាក់ បានទាំងប្រើប្រាស់ និងមិនបានប្រើប្រាស់ក្នុងពេលមួយ។ ឧទាហរណ៍ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវមួយចំនួនបានព្យាយាមចាប់ផ្តើមការរកស៊ីតាមផ្ទះ ប៉ុន្តែក្រោយមក បានបោះបង់ចោល ដោយសារតែឧបករណ៍ខូចខាត ឬប្រាក់ចំនូលមិនគ្រប់គ្រាន់។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចំនួន ១១នាក់ មានការងារជាអប្បបរមាចំនួនបួន ក្នុងកំឡុងពេល/ក្រោយពេលធ្វើសមាហរណកម្ម។ ក្នុងចំណោមនោះ មាន ៨នាក់ បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងមណ្ឌលថែទាំ ប៉ុន្តែមិនបានប្រើប្រាស់វាឡើយ ក្រោយពេលធ្វើសមាហរណកម្ម (យ៉ាងហោចណាស់ មាន ៣នាក់បានប្រើប្រាស់បានខ្លះក្នុងកំឡុងពេលនៃរយៈពេលសិក្សាប៉ាន់ប្រមាណ)។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទាំងនេះ ម្នាក់ៗមានការងារជាមធ្យមចំនួនប្រាំក្រោយពេលធ្វើសមាហរណកម្ម។ តារាងខាងក្រោម រៀបរាប់ពីប្រភេទនៃការងារ ដែលមានចំនួនការងារជាច្រើនដែលជនរួចពីរងគ្រោះធ្វើ។




**តារាង 21៖** ប្រភេទនៃការងារ ដែលមានអត្រានៃការលាឈប់ខ្ពស់ (ចំនួន=១១នាក់)

កម្មកររោងចក្រ (ជានិច្ចកាលរោងចក្រកាត់ដេរ) និងបដិសណ្ឋារកិច្ចភ្ញៀវ (ឧទា. ភោជនីយដ្ឋាន សណ្ឋាគារ) ស្ថិតក្នុងចំណោមប្រភេទនៃការងារដែលពេញនិយមបំផុត ដែលជនរួចពីរងគ្រោះទំនងជាមាន បើពួកគេមានកម្រិតនៃការឈប់ពីការងារខ្ពស់។ ការធ្វើការនៅក្នុងតូបតូច ការស៊ីឈ្នួល ឬការត្រលប់ទៅឧស្សាហកម្មផ្លូវភេទ ក៏ទំនងជាកើនឡើងចំនួននៃការងារ ដែលជនរួចពីរងគ្រោះមានក្រោយពេលនៃការធ្វើសមាហរណកម្មផងដែរ។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវសរុបចំនួន ៣៤នាក់ បាននិយាយអំពីហេតុផលដែលពួកគេបានសម្រេចចិត្តឈប់ពីការងាររបស់ពួកគេ ឈប់រៀន ឬចាកចេញពីកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមុនពេលកំណត់។ ហេតុផលពីរចម្បងបំផុត គឺបទពិសោធន៍ការងារអវិជ្ជមាន និងតម្រូវការហិរញ្ញវត្ថុគ្រួសារបន្ទាន់។ ហេតុផលដទៃទៀតដែលនាំឲ្យឈប់ រួមមានប្រាក់ខែមិនគ្រប់គ្រាន់ ជម្ងឺ ឬភាពអាសន្នខាងការព្យាបាលជម្ងឺ សម្ពាធគ្រួសារដោយផ្ទាល់ និងការខ្វះអ្នកមើលថែកូន។ តារាងខាងក្រោម រៀបរាប់ពីគ្រប់ប្រយោគទាំងអស់ ដែលអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបានលើកឡើងពេលដែលពិភាក្សាអំពីហេតុផលក្នុងការឈប់ពីការងាររបស់ពួកគេ។

| ហេតុផលនាំឲ្យឈប់ពីការងារ ឬសាលារៀន ឬការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ | ចំនួននៃជនរួចពីរងគ្រោះដែលបានធ្វើសមាហរណកម្ម បង្ហាញពីប្រធានបទនេះ |
|---|---|
| រៀនមិនចេះ ឬពិបាកពេក | ៤ |
| គ្រួសារត្រូវការជំនួយបន្ទាន់ | ១១ |
| សម្ពាធពីគ្រួសារ | ៥ |
| ប្រាក់ខែទាបពេក។ ត្រូវការរកលុយថែមទៀត/កាន់តែឆាប់។ | ៩ |
| ខ្វះមធ្យោបាយធ្វើដំណើរ | ២ |
| អត់មានអ្នកមើលកូន | ៥ |
| ជម្ងឺ ភាពអាសន្នខាងការព្យាបាលជម្ងឺ | ៣ |
| បទពិសោធន៍អវិជ្ជមាននៅកន្លែងការងារ | ១៨ |

**តារាង 22៖** ហេតុផលក្នុងការចាកចេញពីការងារ( ចំនួន=៣៤នាក់)

ជារឿយៗ វាមាននូវភាពបន្ទាន់ណាមួយនៅក្នុងហេតុផលនៃការឈប់ពីការងារ ហើយជារឿយៗ អ្នកចូលរួមក្នុងការ សិក្សាស្រាវជ្រាវមានអារម្មណ៍បន្ទុកមួយសម្រាប់ការផ្គត់ផ្គង់កាន់តែច្រើនសម្រាប់គ្រួសាររបស់ពួកគេ។ ប្រភេទនៃ "បទពិសោធន៍អវិជ្ជមាននៅកន្លែងការងារ" រួមមានការមិនចូលចិត្ត ឬការមិនចាប់អារម្មណ៍លើការងារ និង/ឬមិត្តរួមការងារ និយោជកមិនឲ្យតម្លៃ ការគ្រប់គ្រងអន់ និងការរុកគួននៅក្នុងកន្លែងការងារ។

### ៤.៥.១ ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ទីផ្សារការងារ

ការកំណត់ពីប្រភេទនៃការបណ្តុះបណ្តាលការងារ ដែលរៀបចំជនរួចពីរងគ្រោះសម្រាប់ទីផ្សារការងារ បានក្លាយជាក្តីកង្វល់មួយនៅក្នុងអក្សរសាស្ត្រក្នុងឆ្នាំថ្មីៗនេះ។ បានរកឃើញនូវឧបសគ្គមួយចំនួនដែលរារាំងដល់ការទទួលបានការងារដែលជោគជ័យសម្រាប់ជនរួចពីរងគ្រោះពីការជួញដូរ រួមមាន ឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈមិនគ្រប់គ្រាន់ ឬមិនមាន កង្វះធនធានក្នុងការចូលរួមក្នុងការបណ្តុះបណ្តាលរយៈពេលវែង និងការផ្តោតអារម្មណ៍លើទម្រង់នៃការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនាំទៅរកការផ្គត់ផ្គង់ច្រើនជាងតម្រូវការ និងការបង្អាក់ដល់ភាពត្រៀមខ្លួននៃការងារ (ទំព័រ ៣១ ៣២)។ បានបញ្ជាក់ការនេះ ដោយបន្ថែមថា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជារឿយៗ ត្រូវបានចាត់ទុកជាគោលដៅផ្ទាល់ខ្លួន និងការព្យាបាលការងារសម្រាប់ជនរួចពីរងគ្រោះ ជាជាងចាត់ទុកជាសកម្មភាពផ្តោតលើទីផ្សារវិជ្ជាជីវៈ ដែលនឹងនាំទៅរកការងារកំប៉ិកកំប៉ុក (ទំព័រ ៥)។

លទ្ធផលនៃការសិក្សាវាយតម្លៃបច្ចុប្បន្ន បង្ហាញពីទស្សនៈដ៏សំខាន់ពីរបៀប និងថាតើការបណ្តុះបណ្តាលវិជ្ជាជីវៈរៀបចំជនរួចពីរងគ្រោះសម្រាប់ការងារបន្ទាប់ពីការធ្វើសមាហរណកម្ម។ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវចំនួនពាក់កណ្តាល ដែលបានចូលរៀនការបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រើប្រាស់វានៅពេលណាមួយ ក្នុងកំឡុងពេលនៃការធ្វើសមាហរណកម្មរបស់ពួកគេ។ ពួកគេជាច្រើននាក់ ចុងបញ្ចប់ធ្វើការនៅអាជីវកម្មរបស់កម្មវិធីជំនួយ ឬអាជីវកម្មបែបសង្គមនៃកម្មវិធីមណ្ឌលថែទាំ និងមិនមែននៅក្នុងការងារ ខាងក្រៅវិស័យប្រឆាំងការជួញដូរឡើយ។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវក៏បានបង្ហាញពីការស្ទាក់ស្ទើរក្នុងការចុះឈ្មោះ ឬបញ្ចប់កម្មវិធីការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ពួកគេ ដោយសារតែភាពកម្រិតផ្នែកហិរញ្ញវត្ថុដែលមិនរកបានលុយអ្វីសោះ ឬមិនបានលុយគ្រប់គ្រាន់ ក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យ៉ាងហោចណាស់ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវដប់នាក់បាននិយាយដោយផ្ទាល់អំពីហេតុផលរបស់ពួកគេក្នុងការឈប់ពីការងាររបស់ពួកគេ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសារតែគ្រួសាររបស់ពួកគេត្រូវការជំនួយហិរញ្ញវត្ថុពីពួកគេជាបន្ទាន់។

នៅពេលខ្លះ ជនរួចពីរងគ្រោះក៏បង្ហាញពីឆន្ទៈចង់ស្វែងរកការងារថ្មី ដែលមានប្រាក់ខែច្រើនជាងការធ្វើការជាមួយកម្មវិធីជំនួយ។ យ៉ាងណាក៏ដោយ ពួកគេមានការលំបាកក្នុងការទទួលបានការងារដែលមានប្រាក់ខែខ្ពស់ ដោយសារតែពួកគេមានធនធាន និងជំនាញមានកម្រិត។ ពេលខ្លះ ជំនាញដែលពួកគេបានរៀន ខណៈពេលដែលពួកគេស្ថិតនៅក្នុងកម្មវិធីបណ្តុះបណ្តាល គឺមិនត្រូវ ឬមិនអាចធ្វើបាននៅក្នុងសហគមន៍របស់ពួកគេឡើយ។ ចំនួននៃជនរួចពីរងគ្រោះ កំពុងតែធ្វើបានយ៉ាងល្អជាមួយវគ្គបណ្តុះបណ្តាលជំនាញរបស់ពួកគេ (ឧទា. ការធ្វើម្ហូប ការដេរ ការធ្វើសក់)។ យ៉ាងណាក៏ដោយ ជំនាញទាំងនេះ មិនអាចប្រើប្រាស់បានឡើយ ពេលដែលពួកគេធ្វើសមាហរណកម្មទៅកាន់តំបន់ និងខេត្តដាច់ស្រយាល។ ដូច្នេះ ពួកគេត្រូវតែធ្វើចំណាកស្រុកទៅធ្វើការនៅកន្លែងផ្សេង ដូច្នេះហើយបានជាហានិភ័យ និងភាពងាយរងគ្រោះរបស់ពួកគេបានកើនឡើង។

### *៤.៥.២ អាជីវកម្មសង្គមនៃកម្មវិធីមណ្ឌលថែទាំ*

ការតាមដានប្រាក់ខែ បានបង្ហាញពីការកើនឡើងនៅក្នុងប្រាក់ខែរបស់ជនរួចពីរងគ្រោះក្នុងកំឡុងពេលនៃការសិក្សា។ សូមកត់សំគាល់ថា ប្រាក់ខែ ត្រូវបានតាមដានរយៈពេលជាច្រើនឆ្នាំសម្រាប់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ២៥នាក់ប៉ុណ្ណោះ ហើយអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទាំងនោះ អាចទំនងជាចង់មានការងារក្នុងអាជីវកម្មសង្គមដែលនឹងនរ ហើយមិនមែនការងារក្រៅផ្លូវការ ឬការងារក្រៅពីផ្នែកការប្រឆាំងនឹងការជួញដូរ។

សូចនាករនៃស្ថេរភាពការងារមួយទៀត គឺជាការពិតដែលថាជនរួចពីរងគ្រោះភាគច្រើន ដែលមានការងារមួយ ក្នុងកំឡុងពេលនៃការជ្រើសមាហរណកម្ម បានធ្វើការនៅក្នុងអាជីវកម្មសង្គមនៃកម្មវិធីមណ្ឌលថែទាំ ឬការងារក្នុងកម្មវិធីជំនួយ។ ជាទូទៅ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទំនងជាមានអារម្មណ៍មានសន្តិសុខខ្លាំងជាងនៅក្នុងការងារទាំងនោះ ទាំងខាងហិរញ្ញវត្ថុ ឬផ្លូវចិត្ត។

ជនរួចពីរងគ្រោះបានបង្ហាញទាំងអារម្មណ៍ពេញចិត្ត និងមិនពេញចិត្តចំពោះបទពិសោធន៍ការងាររបស់ពួកគេជាមួយអាជីវកម្មដែលប្រឆាំងនឹងការជួញដូរ។ តារាងខាងក្រោមរៀបរាប់នូវប្រយោគមួយចំនួន ដែលជនរួចពីរងគ្រោះបាននិយាយអំពីបទពិសោធន៍របស់ពួកគេជាមួយការងារក្នុងកម្មវិធីជំនួយ និងការបណ្តុះបណ្តាល។

| *ការបង្ហាញពីអារម្មណ៍ពេញចិត្ត ឬមិនពេញចិត្តជាមួយការងាររបស់កម្មវិធីជំនួយ* |
| --- |
| "ពេលខ្លះ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តជាមួយប្រាក់ខែទាប ដែលអង្គការផ្តល់ឲ្យខ្ញុំ ហើយខ្ញុំមិនអាចទទួលបានប្រភេទនៃការបណ្តុះបណ្តាល ដែលខ្ញុំចង់បានដូចជាមិត្តភក្តិរបស់ខ្ញុំឡើយ ពួកគេអាចទទួលការបណ្តុះបណ្តាលទាក់ទងនឹងការតុបតែងខ្លួននៅតាមហាងខាងក្រៅ។" |
| "ខ្ញុំមិនមានចំណាប់អារម្មណ៍ចង់រៀន ឬចូលរួមក្នុងជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈឡើយ។ ខ្ញុំចង់បើកហាងលក់កាហ្វេ និងអាហារ បើអាច។ ខ្ញុំគិតថា វានឹងរកលុយបានច្រើនជាង។" |
| "ខ្ញុំនៅតែធ្វើការក្នុងកម្មវិធីជំនួយរបស់អង្គការ ដោយសារតែខ្ញុំគ្មានជម្រើសណាផ្សេងទៀតឡើយ។ វាពិបាកក្នុងការធ្វើការនៅទីនេះ ប៉ុន្តែ ខ្ញុំនៅតែធ្វើ ដោយសារតែវាពិបាកក្នុងការរកបានការងារថ្មី។" |
| "ពេលដែលខ្ញុំបានធ្វើការនៅក្នុងកម្មវិធីជំនួយរបស់អង្គការ ខ្ញុំមានអារម្មណ៍ខុសប្លែកពីមុន។ ជីវិតរបស់ខ្ញុំមិនមានគ្រោះថ្នាក់ដូចនៅក្នុងបនស្រីឡើយ។ ខ្ញុំមានជីវិតមួយទៀតហើយឥឡូវ។" |

**តារាង 23៖** ការបង្ហាញពីការពេញចិត្ត ឬមិនពេញចិត្តចំពោះការងារជាមួយកម្មវិធីជំនួយ

## ៥.១ សេចក្តីសន្និដ្ឋាន និងដែនកំណត់

ប្រធានបទសំខាន់ ដែលកើតចេញពីការសិក្សាវាយតម្លៃនេះ គឺជាការសងគុណឪពុកម្តាយ នៅក្នុងទស្សនៈរបស់ជនរួចពីរងគ្រោះ ជាការបង្ហាញការសងគុណ ទោះបីជាការអនុវត្តន៍ ជាបន្ទុកដ៏ពិបាក ដែលធ្លាក់ទៅលើមនុស្សដែលមានភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងសង្គមរួចហើយក៏ដោយ។ ពេលខ្លះ ជនរួចពីរងគ្រោះ រងគ្រោះពីក្តីបារម្ភជ្រុលផ្នែកហិរញ្ញវត្ថុ ការបង្ហាញរោគសញ្ញា ដូចជា អារម្មណ៍តានតឹង ការបារម្ភជានិច្ច និងភាពភ័យខ្លាចទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេ។ ស្ថានភាពហិរញ្ញវត្ថុនៃជនរួចពីរងគ្រោះទាំងនេះ មិនមានស្ថេរភាព និងហិនហោចដោយបំណុល ដែលជារឿយៗមិនចេះចប់មិនចេះហើយឡើយ។ ជនរួចពីរងគ្រោះបង្ហាញភាពមិនច្បាស់លាស់អំពីទីផ្សារការងារ និងអនាគតសេដ្ឋកិច្ចរបស់ពួកគេ ហើយជារឿយៗ ពួកគេមានអារម្មណ៍មិនបានត្រៀមខ្លួនសម្រាប់កម្លាំងការងារឡើយ។

សូមកត់សំគាល់ថា អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវជាច្រើននាក់ដែលបានបង្ហាញពីប្រធានខាងលើ បានធ្វើជាច្រើនដង នៅក្នុងរយៈពេលនៃការចូលរួមរបស់ពួកគេជាមួយការសិក្សា។ ជារឿយៗ នៅក្នុងបទសម្ភាសន៍ដែលដាច់ចេញពីគ្នារាប់ខែ និងឆ្នាំ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនឹងបង្ហាញអារម្មណ៍ និងបទពិសោធន៍ដដែលម្តងហើយម្តងទៀត។ លទ្ធផលទាំងនេះ បានផ្លាស់ប្តូរបន្តិចបន្តួចក្នុងវគ្គនៃការសិក្សា។ ឧបសគ្គ អារម្មណ៍ទទួលខុសត្រូវ និងភាពមិនស្ថិតស្ថេរ កំពុងតែកើតមានឡើងសម្រាប់ជនរួចពីរងគ្រោះភាគច្រើន ដែលបានបង្ហាញប្រធានបទទាំងនេះ។

លើសពីនេះទៅទៀត ប្រធានបទភាគច្រើនបំផុតអំពីការសងគុណឪពុកម្តាយ និងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ ត្រូវបានបង្ហាញចេញ ក្រោយពេលការធ្វើសមាហរណកម្មពេលដែលជនរួចពីរងគ្រោះម្នាក់បានត្រលប់ទៅរស់នៅក្នុងសហគមន៍វិញ។ ដូចជាបានឃើញនៅក្នុងតារាងខាងក្រោម ៦៣%នៃអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ (៤៨/៧៧) បានបង្ហាញពីប្រធានបទអំពីការសងគុណ និងក្តីបារម្ភផ្នែកហិរញ្ញវត្ថុ ក្រោយពេលពួកគេបានធ្វើសមាហរណកម្ម។ មានតែ ៥% (៤/៧៧) ប៉ុណ្ណោះដែលមិនបានបង្ហាញពីប្រធានបទនេះ ហើយ៥%ទៀត បានបង្ហាញប្រធានបទទាំងនេះ មុនពេលធ្វើសមាហរណកម្ម និងមិនមែនក្រោយពេលធ្វើសមាហរណកម្មឡើយ។ ចុងបញ្ចប់ ២៧% (២១/៧៧) បានបង្ហាញពីប្រធានបទនៃការសងគុណ និងក្តីបារម្ភខាងហិរញ្ញវត្ថុទាំងមុនពេល និងក្រោយពេលធ្វើសមាហរណកម្ម។




**តារាង 24៖** ការបង្ហាញពីការសងគុណ និងក្តីបារម្ភផ្នែកហិរញ្ញវត្ថុរបស់ជនរួចពីរងគ្រោះ

អារម្មណ៍តានតឹងដ៏សំខាន់បំផុតនៅក្នុងលទ្ធផលរកឃើញអំពីការសងគុណ និងក្តីបារម្ភផ្នែកហិរញ្ញវត្ថុនៅក្នុងចំណោមជនរួចពីការរងគ្រោះពីការជួញដូរដែលបានធ្វើសមាហរណកម្ម គឺជាគម្លាតរវាងប្រយោគដោយផ្ទាល់ ទាក់ទងនឹងប្រធានបទទាំងនេះ និងការសំដែងចេញពីប្រធានបទទាំងនេះដោយប្រយោល។ ឧទាហរណ៍ពីរនៃភាពតានតឹងនេះ គឺនៅក្នុងប្រធានបទអំពីទំនួលខុសត្រូវរបស់កូនចំពោះឪពុកម្តាយរបស់ខ្លួន និងការមើលឃើញគំនិតសងគុណជាការគោរព ឬជាបន្ទុក។

នៅក្នុងការស្ទង់មតិដំបូង អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវមិនយល់ស្របភាគច្រើន (៧៦%) ថា កូនក្រោមអាយុ១៨ឆ្នាំ គួរតែទទួលខុសត្រូវក្នុងការផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ យ៉ាងណាក៏ដោយ ការបង្ហាញពីក្ដីបារម្ភ ទំនួលខុសត្រូវ និង ពិរុទ្ធភាពអំពីការផ្គត់ផ្គង់គ្រួសាររបស់ខ្លួន ត្រូវបានជ្រួតជ្រាប ទោះបីក្នុងចំណោមអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ដែល មានអាយុត្រឹម ឬក្រោម១៨ឆ្នាំ។ ទីពីរ ទោះបីជាអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបាននិយាយថា ភារកិច្ចសងគុណរបស់ ពួកគេ ទាក់ទងនឹងការគោរព និងការសងគុណក៏ដោយ ក៏ការបង្ហាញពីបន្ទុក និងការលំបាក គឺមានកម្រិតខ្ពស់ខ្លាំងក្នុង ចំណោមមនុស្សដែលបានបង្ហាញប្រធានបទនៃការសងគុណ។

ជាមួយគ្នាផងដែរ ការពិតដែលជនរួចពីការរងគ្រោះភាគច្រើនបានបង្ហាញពីប្រធានបទនៃការសងគុណ និងក្ដីបារម្ភផ្នែក ហិរញ្ញវត្ថុ ក្រោយពេលពួកគេបានធ្វើសមាហរណកម្ម វាធ្វើឲ្យពួកគេមានកម្រិតនៃភាពតានតឹងខ្ពស់ ក្នុងកំឡុងពេលនៃការ ធ្វើសមាហរណកម្មដំបូង បន្ថែមនូវបញ្ហាខាងផ្លូវចិត្ត និងផ្លូវអារម្មណ៍ជាច្រើន នៅពេលដែលពួកគេចាកចេញពីមណ្ឌល និង ត្រលប់ទៅកាន់ផ្ទះ ឬចូលទៅក្នុងសហគមន៍របស់ពួកគេម្ដងទៀត។

លទ្ធផលនៃការរកឃើញចេញពីការសិក្សាវាយតម្លៃនេះ អាចចូលរួមចំណែកនាំឲ្យលទ្ធផលនេះកាន់តែប្រសើរ និងផ្ដល់នូវ ស្ថានភាពកាន់តែគ្រប់ជ្រុងជ្រោយសម្រាប់ការធ្វើសមាហរណកម្មជនរួចពីរងការគ្រោះ ក៏ដូចជាការអនុវត្តន៍ការស្រាវជ្រាវក្នុង ពេលខាងមុខ។

ទំហំសំណាកនៅក្នុងការសិក្សាប៉ាន់ប្រមាណនេះ មិនមានចំនួនស្មើគ្នានឹងការចុះប្រមូលពត៌មានក្នុងកំឡុងឆ្នាំដែលផ្ដល់ជូន នៅក្នុងគម្រោងស្រាវជ្រាវទេ ដោយសារតែអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវទាំងអស់ មិនមែនសុទ្ធតែមានពេលទំនេរ សម្រាប់រយៈពេលបីដងក្នុងមួយឆ្នាំឡើយ។ ការស្ទង់មតិ និងបទសម្ភាសន៍ ត្រូវបានធ្វើឡើងជាភាសាខ្មែរ ហើយបកប្រែជា ភាសាអង់គ្លេស។ អត្ថបទសម្ភាសន៍ និងទិន្នន័យសង្ខេបជាសាច់រឿង ត្រូវបានត្រួតពិនិត្យទៅវិញទៅមក ដើម្បីធានានូវ សុក្រឹតភាពនៃការបកប្រែ។ ការស្ទង់មតិ និងលទ្ធផលនៃការវិភាគដំបូង ត្រូវបានត្រួតពិនិត្យមើលជាក្រុមការងារ ដើម្បី ចៀសវាងនូវភាពលំអៀងដោយកត្តាវប្បធម៌នៅក្នុងការវិភាគបកស្រាយ និងធានាថា ទស្សនៈខាងវប្បធម៌ ត្រូវបានរក្សាទុក នៅក្នុងការវិភាគទិន្នន័យ។

ការវិភាគនៃលទ្ធផលរកឃើញនេះ ក៏ត្រូវយកមកពិភាក្សា និងបញ្ជាក់ជាមួយក្រុមអ្នកស្រាវជ្រាវ ដើម្បីកាត់បន្ថយការយល់ ច្រលំខាងវប្បធម៌ និងខាងបរិបទដទៃទៀត ដែលអាចកើតមានឡើង។ បន្ថែមពីលើនេះ ប្រព័ន្ធលេខកូដបែបគុណភាព អាចមាននូវភាពអសុក្រឹតបន្តិចបន្តួច ដ្បិតពេលខ្លះអ្នកស្រាវជ្រាវធ្វើការវិនិច្ឆ័យថាតើប្រយោគមួយណាដែលអ្នកចូលរួមក្នុង ការសិក្សាស្រាវជ្រាវបាននិយាយ ស្ថិតនៅក្នុងប្រភេទនៃប្រធានបទណាមួយ។

## ៥.២ អនុសាសន៍

### *៥.២.១ ភាពសំខាន់នៃគ្រួសារ*

ការសិក្សាប៉ាន់ប្រមាណនេះធ្វើការសន្និដ្ឋានថា គ្រួសារ គឺជាកត្តាដ៏សំខាន់ និងដ៏មានឥទ្ធិពលទៅលើដំណើរការនៃការធ្វើ សមាហរណកម្មសេដ្ឋកិច្ចរបស់ជនរួចពីរងគ្រោះ។ ដូច្នេះ វាជាការសំខាន់បំផុតដែលសេវាសមាហរណកម្មរបស់ជនរួចពី រងគ្រោះត្រូវរាប់បញ្ចូលចំណុចមួយចំនួនដូចជាការសិក្សាប៉ាន់ប្រមាណគ្រួសារ ការងារសង្គមកិច្ច ជាមួយគ្រួសារ និងការផ្ដល់អំណាចគ្រួសារជាដើម។ ស្ថានភាពគ្រួសារ ការរំពឹងទុក ទ្រព្យធន និងឧបសគ្គរាំងនានា គួរតែ

ត្រូវបានយកមកគិតពិចារណាមើល និងដាក់បញ្ចូលទៅក្នុងផែនការ សម្រាប់ការសមាហរណកម្មជនរួចពីរងគ្រោះនីមួយៗ។

ក្រុមអ្នកស្រាវជ្រាវយល់ឃើញថា ពេលដែលជនរួចពីរងគ្រោះណាម្នាក់មិនមានក្រុមគ្រួសារជាបង្គោល ពួកគេមើលទៅហាក់ដូចជាកំពុងតែ "រសាត់អណ្តែតឥតកោះត្រើយ"។ បើសិនជានាងមិនមានគ្រួសារត្រលប់ទៅនៅជាមួយទេ នោះនាងមានទំនោរច្រើនក្នុងការត្រលប់ចូលទៅក្នុងវិស័យការងារកេងប្រវ័ញ្ចផ្លូវភេទជាថ្មីម្តងទៀត (ដូចជា ការងារក្នុងវិស័យរកស៊ីផ្លូវភេទ)។ គ្រួសារ គឺជាមូលដ្ឋានគ្រឹះរបស់បុគ្គលម្នាក់ៗ ហើយពួកគេមិនអាចមើលឃើញខ្លួនឯងដាច់ចេញដោយឡែកពីគ្រួសារបាននោះឡើយ។ ដូច្នេះ នៅពេលដែលកម្មវិធីជំនួយកំពុងតែព្យាយាមជួយជនរួចពីរងគ្រោះក្នុងការធ្វើសមាហរណកម្ម សេវាកម្មមួយចំនួននៅក្នុងគម្រោងកម្មវិធីនោះត្រូវតែគិតពិចារណាពីគ្រួសារ និងបញ្ចូលគ្រួសារនៅក្នុងសេវាកម្មនោះដែរតាមដែលអាចធ្វើទៅបាន។ ចំណុចមួយចំនួនដែលត្រូវតែដាក់បញ្ចូលមានដូចជា ការធ្វើជាអ្នកប្រឹក្សាផ្នែកហិរញ្ញវត្ថុ ការរៀបចំផែនការអនាគត ការកំណត់គោលដៅឬផែនការឲ្យបានជាក់លាក់ ឬការបង្កើតឲ្យចេះគិតពិចារណាឲ្យបានម៉ត់ចត់ និងការបង្ហាញពីតួនាទីនៃគ្រួសារដែលជាកត្តាដ៏រឹងមាំនៅក្នុងជីវិតរបស់ជនរួចពីរងគ្រោះជាដើម។

ជាចុងបញ្ចប់ ក្រុមអ្នកស្រាវជ្រាវផ្តល់អនុសាសន៍ឲ្យកម្មវិធីថែទាំ ធ្វើការពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រផែនការសម្រាប់សេវាសមាហរណកម្មរបស់ពួកគេ និងចំនួនដង ឬរយៈពេលនៃចុះតាមដានពេលវេលាអតិថិជនរបស់ពួកគេនៅពេលធ្វើសមាហរណកម្មពួកគេត្រលប់ទៅសហគមន៍វិញ។ ស្ថានភាពសមាហរណកម្មសេដ្ឋកិច្ច គួរតែត្រូវបានវាយតម្លៃជាលក្ខណៈប្រព័ន្ធ និងគួរតែបង្កើនកម្លាំងបន្ថែមទៀតក្នុងការការស្វែងយល់នូវជម្រើសសេដ្ឋកិច្ចឲ្យបានច្រើន និងទាំងអស់សម្រាប់ជនរួចពីរងគ្រោះ ក្រៅពីជម្រើសការងារបែបបុរាណដដែលៗ ហើយគួរតែគិតពិចារណាអំពីស្ថានភាពសមត្ថភាពរបស់ក្រុមគ្រួសាររបស់ពួកគេផងដែរ។ មានការសិក្សាស្រាវជ្រាវជាច្រើន រួមទាំងការសិក្សាប៉ាន់ប្រមាណមួយនេះ បានបង្ហាញបញ្ជាក់នូវបរិមាណនៃរយៈពេលដែលជនរួចពីរងគ្រោះត្រូវការជំនួយ ទាំងផ្នែកហិរញ្ញវត្ថុ និងសង្គមសេដ្ឋកិច្ច ក្រោយពេលពួកគេត្រូវបានធ្វើសមាហរណកម្មរួច ហើយរយៈពេលដែលត្រូវការនេះ គឺប្រហែលជាត្រូវការពេលយូរជាងអ្វីដែលកម្មវិធីថែទាំជំនួសភាគច្រើនបានកំពុងផ្តល់ឲ្យពួកគេ។

### *៥.២.២ គំរូនៃសមត្ថភាពផ្នែកហិរញ្ញវត្ថុក្នុងចំណោមជនរួចពីរងគ្រោះ*

ដោយផ្អែកលើលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណ ផែនការគ្រោងនៃការងារអភិវឌ្ឍសមត្ថភាពហិរញ្ញវត្ថុ ត្រូវបានផ្តល់ជាអនុសាសន៍ដល់កម្មវិធីឲ្យកែលម្អជំនួយសមាហរណកម្មសេដ្ឋកិច្ចរបស់ពួកគេទៅកាន់ជនរួចពីរងគ្រោះ។ សមាជិក និងសមត្ថភាពគ្រួសារ ក៏គួរតែដើរតួយ៉ាងសំខាន់នៅក្នុងផែនការសមត្ថភាពហិរញ្ញវត្ថុសម្រាប់ជនរួចពីរងគ្រោះម្នាក់ៗផងដែរ។

គំរូនៃសមត្ថភាពហិរញ្ញវត្ថុក្នុងចំណោមជនរួចពីរងគ្រោះពីការជួញដូរនេះ ត្រូវបានធ្វើឡើងដោយផ្អែកទៅតាមផែនការគ្រោងនៃការងារមានស្រាប់ ដែលវាត្រូវបានបង្កើតឡើងរួចទៅហើយសម្រាប់ជនរួចពីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនៅក្នុងសហរដ្ឋអាមេរិក។ ដើម្បីឲ្យគំរូនេះអាចកែសម្រួលសម្រាប់យកមកប្រើប្រាស់នៅក្នុងវិស័យប្រឆាំងនឹងការជួញដូរមនុស្សបាន វាទាមទារឲ្យមានការសិក្សាវាយតម្លៃ និងការធ្វើតេស្តសាកល្បងមើលជាច្រើនដងច្រើនសារថែមទៀតទៅលើគំរូនេះ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ គំរូនៃផែនការគ្រោងបែបទ្រឹស្តីនេះ គឺវាជាចំណុចចាប់ផ្តើមដ៏ល្អមួយដែលយើងគួរតែគិតពិចារណា។

២០១៣ បានអនុវត្តគំរូនៃសមត្ថភាពហិរញ្ញវត្ថុជាមួយនឹងជនរួចពីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ហើយលោកក៏បាននិយាយអំពីការរៀបចំបង្កើតនូវផែនការសមត្ថភាពហិរញ្ញវត្ថុជាលក្ខណៈបុគ្គល ដើម្បីជួយដល់ស្ត្រីអាចយកការអប់រំផ្នែកហិរញ្ញវត្ថុ និងជំនួយនានាដែលពួកគេបានទទួលទៅអនុវត្តផ្ទាល់ (ទំព័រ ៩០)។ លទ្ធផលនៃគំរូសមត្ថភាពហិរញ្ញវត្ថុគ្រប់ជ្រុងជ្រោយនេះ បានបង្ហាញពីការជះឥទ្ធិពលលើអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ តាមរបៀបបីយ៉ាង៖ វាបានផ្លាស់ប្តូររបៀបដែលពួកគេគិតអំពីបញ្ហាហិរញ្ញវត្ថុ វាបានផ្លាស់ប្តូររបៀបដែលពួកគេប្រព្រឹត្តចំពោះបញ្ហាផ្នែកហិរញ្ញវត្ថុ (អ្នកប្រើប្រាស់ គម្រោងថវិកា និង ឥរិយាបថក្នុងការសងបំណុល) ហើយវាបានបញ្ជាក់ឲ្យឃើញទៀតថា ការរៀនសូត្រដ៏ពិតប្រាកដត្រូវបានកើតឡើង (ទំព័រ ៩១ ៩៤)។

សមត្ថភាពហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការបញ្ចូលសមាសភាពមួយចំនួនដូចជា កត្តាអក្ខរកម្មហិរញ្ញវត្ថុ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការត្រៀមខ្លួនសម្រាប់ការងារ ទីផ្សារការងារ និងមធ្យោបាយក្នុងការទទួលបាននូវប្រព័ន្ធ និងធនធានផ្សេងៗជាដើម។ ជារួមមក ការសិក្សាពីមុនៗក៏បានយល់ស្របដែរថា "សមត្ថភាពខាងហិរញ្ញវត្ថុ គឺជាការចូលរួមនៅក្នុងជីវិតសេដ្ឋកិច្ច ដែលធ្វើឲ្យ ជីវិតមានឱកាសកាន់តែច្រើនតាមដែលអាចធ្វើទៅបាន នឹងជួយជំរុញឲ្យមនុស្សឈានទៅកាន់ភាពពេញលេញនៃជីវិតរបស់ពួកគេ។ ដើម្បីឲ្យការនេះកើតឡើងបាន វាតម្រូវឲ្យមានចំណេះដឹង និងសមត្ថភាព ព្រមទាំងត្រូវការនូវសមត្ថភាព និងឱកាស ដើម្បីប្រើប្រាស់នូវចំណេះដឹងនោះ។ ចំណុចនេះពាក់ព័ន្ធទៅនឹងការផ្សារភ្ជាប់តួនាទីរបស់បុគ្គលទៅនឹងស្ថាប័ននានា។ ហើយវាក៏ពាក់ព័ន្ធនឹងការប្រើប្រាស់នូវវិធីសាស្ត្រគរុកោសល្យ ដែលជួយឲ្យមនុស្សអាចអនុវត្ត និងបង្កើនសមត្ថភាពរបស់ពួកគេថែមនៅក្នុងមុខងារដែលពួកគេកំពុងបំពេញ" ( ទំព័រ២៣)

បង្ហាញគំរូនេះ ទាក់ទងនឹងការពង្រឹងអំណាច ដោយនិយាយថា "ការពង្រឹងអំណាច វាមិនមែនជាលទ្ធផលនៃសេវាកម្មឡើយ ប៉ុន្តែ វាជាដំណើរការដែលស្ត្រីៗបានចូលរួមនៅក្នុងដំណើរការនោះ"។ ពួកគេបន្ថែមថា ការដែលអាចចូលទៅកាន់ប្រភពធនធាននានាបាន វាជំរុញឲ្យមានដំណើរការនៃការពង្រឹងអំណាចនេះ (ទំព័រ ២៨១)។ ផ្នែកមួយនៃដំណើរការនៃការពង្រឹងអំណាច គឺជាការអប់រំជនរួចពីរងគ្រោះអំពីការបំពានផ្នែកសេដ្ឋកិច្ច និងសកម្មភាពកេងប្រវ័ញ្ច ព្រមទាំង "ការតស៊ូមតិ ក៏គួរតែត្រូវបានរៀបចំ ដើម្បីផ្តល់នូវឧបករណ៍ និងយុទ្ធសាស្ត្រហិរញ្ញវត្ថុ ក្នុងគោលបំណងដើម្បីបង្កើនសមត្ថភាពក្នុងការផ្គត់ផ្គង់សេដ្ឋកិច្ចដោយខ្លួនឯងរបស់ជនរួចពីរងគ្រោះ" ( ទំព័រ១៥)។ ស្រដៀងនឹងបញ្ហានេះ ការនិយាយដោយបើកចំហអំពីបញ្ហានៃការសងគុណ និងក្តីបារម្ភផ្នែកហិរញ្ញវត្ថុជាមួយជនរួចពីរងគ្រោះដោយការជួញដូរ អាចនឹងជួយពង្រឹងអំណាចដល់ពួកគេក្នុងការប្រឈមមុខ និងដោះស្រាយជាមួយបញ្ហាទាំងនេះនៅក្នុងបរិបទក្រុមគ្រួសាររបស់ពួកគេ។

ទិដ្ឋភាពគំរូរួមមួយសម្រាប់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរ គឺជាតម្រូវការចង់បានសុវត្ថិភាពនៅក្នុងការអនុវត្តកម្មវិធី។ បានសង្កត់ធ្ងន់អំពីតម្រូវការពិសេសៗដែលជនរួចពីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារត្រូវការដូចជា ការលើកទឹកចិត្តឲ្យមានកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុ សម្រាប់ "បញ្ចូលព័ត៌មាន ដែលត្រូវបានកំណត់គោលដៅជាក់លាក់ចំពោះក្តីកង្វល់សុវត្ថិភាពពិសេស និងស្នូគស្មាញរបស់ជនរួចពីរងគ្រោះ" (ទំព័រ១៣)។ ក៏សង្កត់បញ្ជាក់ពីភាពសំខាន់នៃសុវត្ថិភាពនៅក្នុងការពង្រឹងអំណាចសេដ្ឋកិច្ច និងកម្មវិធីផ្តល់សន្តិសុខសម្រាប់ស្ត្រីដែលងាយរងគ្រោះផងដែរ។

គំរូសមត្ថភាពហិរញ្ញវត្ថុមានផ្នែកបីសំខាន់ៗ ដែលចំណុចទាំងបីនោះត្រូវតែយកទៅព្រមអនុវត្តជាមួយគ្នាតែម្តង ហើយអនុវត្តនៅក្នុងបរិបទដ៏ធំទូលាយនៅក្នុងដំណើរការនៃការអនុវត្តន៍ការងារមួយចំនួនដូចជាការងារសង្គមកិច្ច ការផ្តល់ឱវាទ និងការបង្វឹក និងការផ្តល់ប្រឹក្សាយោបល់ជាដើម។ ផ្នែកទីមួយ គឺពាក់ព័ន្ធនឹងផ្នែកអក្ខរកម្មហិរញ្ញវត្ថុ និងការអប់រំ។ ចំណុចនេះរួមបញ្ចូលទាំងការកើនឡើងនូវចំណេះដឹង និងជំនាញដល់ជនរួចពីរងគ្រោះ ទាក់ទងនឹងការរៀបចំគម្រោងថវិកា ការគ្រប់គ្រងថវិកា ការរៀបចំផែនការហិរញ្ញវត្ថុ និងការសន្សំប្រាក់។ ផ្នែកទីមួយនេះដែរ ក៏រួមបញ្ចូលនូវចំណុចមួយចំនួនទៀតដូចជា ការ បណ្តុះសមត្ថភាពការងារ ដើម្បីជួយឲ្យជនរួចពីរងគ្រោះបានត្រៀមខ្លួនជាស្រេចសម្រាប់ការបំពេញការងារផងដែរ។ ផ្នែកនេះ មិនមែនសំដៅទៅលើសកម្មភាពមួយដងចប់សព្វគ្រប់នោះឡើយ ប៉ុន្តែ វាជាដំណើរការនៃការរៀនសូត្រ និងការអនុវត្តន៍ជាបន្តបន្ទាប់នូវអ្វីដែលពួកគេបានរៀនរហូតឈានទៅដល់ផ្នែកទីពីរនៃគំរូសមត្ថភាពហិរញ្ញវត្ថុ។

ផ្នែកទីពីរនៃសមត្ថភាពហិរញ្ញវត្ថុ គឺជាការអនុវត្តន៍ចំណេះដឹង ដែលពួកគេបានរៀនឲ្យក្លាយទៅជាបទពិសោធន៍។ ជានិច្ចកាលចំណុចនេះគឺជាសកម្មភាពនៅក្នុងកន្លែងបំពេញការងារ និងបទពិសោធន៍ក្នុងការបំពេញការងារ។ ហើយដោយសារតែការអប់រំហិរញ្ញវត្ថុ គឺជាដំណើរការដែលមានជាបន្តបន្ទាប់នៅក្នុងកំឡុងពេលកំពុងធ្វើការងារ ដូច្នេះ វានឹងជំរុញឲ្យមានការអប់រំហិរញ្ញវត្ថុ ឆ្លងតាមរយៈការរៀនពីបទពិសោធន៍ក្នុងការបំពេញការងារ។ ការផ្តល់ឲ្យជនរួចពីរងគ្រោះនូវការបង្វឹក និងការប្រឹក្សាខាងហិរញ្ញវត្ថុ បន្ទាប់ពីពួកគេធ្វើសមាហរណកម្ម និងតាមរយៈបទពិសោធន៍ការងារដំបូង ក្រោយពេលពួកគេត្រូវបានសង្គ្រោះពីការជួញដូរ វាក៏នឹងនាំជំរុញឲ្យពួកគេឈានទៅរកដំណើរការនៃការពង្រឹងអំណាច និងការរៀនសូត្រពីបទពិសោធន៍របស់ពួកគេផងដែរ។

ផ្នែកទីបី គឺជាការគាំទ្រជនរួចពីរងគ្រោះឲ្យអាចចូលទៅកាន់ប្រព័ន្ធ និងធនធានផ្សេងៗ ដែលនឹងជួយពួកគេឲ្យរៀបចំផែនការសម្រាប់អនាគត និងសម្រេចនូវលទ្ធផលនៃសង្គមសេដ្ឋកិច្ចដែលពួកគេប្រាថ្នាចង់បាន។ Shapiro & Burchell (2012) បាននិយាយថា៖ "វាជាការសំខាន់ដែលត្រូវធ្វើឲ្យចំណេះដឹងហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួលក្នុងការទទួលបាន ហើយផលិតផលហិរញ្ញវត្ថុកាន់តែងាយស្រួលប្រើប្រាស់ ដែលវាអាចនឹងជួយកាត់បន្ថយក្តីបារម្ភផ្នែកហិរញ្ញវត្ថុរបស់បុគ្គលម្នាក់ៗ" (ទំព័រ ១០១)។ ដូច្នេះ ផ្នែកនេះ រួមបញ្ចូលមានទាំងឧបសគ្គក្នុងការតស៊ូមតិ និងការចាប់ដៃគូជាមួយស្ថាប័ននានា ដើម្បីលើកកម្ពស់ផលិតផល ធនធាន និងគោលនយោបាយផ្សេងៗ សម្រាប់មនុស្សដែលងាយរងគ្រោះឲ្យមានកាន់តែច្រើនថែមទៀត។ ការជួយជនរួចពីរងគ្រោះឲ្យអាចចូលទៅកាន់ប្រព័ន្ធ និងធនធាន គឺវារួមទាំងជួយឲ្យពួកគេជានាថា ពួកគេមាននូវឯកសារអត្តសញ្ញាណសំគាល់ខ្លួនត្រឹមត្រូវ ឱកាសក្នុងការបើក និងដំណើរការលេខគណនីធនាគារ (ដែលវាអាចរួមបញ្ចូលទាំងធនធានសម្រាប់ធនាគារចល័តនៅតាមតំបន់ដាច់ស្រយាលផង) និងការផ្សារភ្ជាប់ពួកគេជាមួយក្រុមសន្សំប្រាក់ដែលមានសុវត្ថិភាពនៅក្នុងសហគមន៍របស់ពួកគេ។

Sanders (2007) និង Sherraden (2010) បានសង្ខេបគំរូសមត្ថភាពហិរញ្ញវត្ថុសម្រាប់ជនរួចពីរងគ្រោះតាមរបៀបបែបនេះ "ការផ្តល់នូវការអប់រំហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព នឹងជួយឲ្យស្ត្រីៗកាន់តែមានភាពឯករាជ្យខាងផ្នែកហិរញ្ញវត្ថុ។ យ៉ាងណាមិញ ខណៈពេលដែលការអប់រំហិរញ្ញវត្ថុមានភាពសំខាន់ ប៉ុន្តែ វាក៏មិនទាន់គ្រប់គ្រាន់ឡើយ។ ធនធានហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានសេវា និងជំនួយផ្នែកហិរញ្ញវត្ថុ វានឹងជួយធ្វើឲ្យស្ត្រីៗអាចប្រើប្រាស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំនាញរបស់ពួកគេ ព្រមទាំងអាចក្លាយជាស្ត្រីដែលមានសមត្ថភាពផ្នែកហិរញ្ញវត្ថុ" (បានលើកឡើងនៅក្នុង Sanders, 2013, p. 101)។

បរិបទទូលំទូលាយនៃការងារសង្គមកិច្ច និងការប្រឹក្សាយោបល់ អាចដាក់បញ្ចូលឪពុកម្តាយ និងគ្រួសាររបស់ជនរួចពីរងគ្រោះនៅក្នុងដំណើរការនៃការរៀន និងការបង្វឹកបង្ហាត់។ វាក៏អាចដាក់បញ្ចូល ផ្នែកនៃការជួយឲ្យជនរួចពីរងគ្រោះចេះគិតយ៉ាងម៉ត់ចត់ និងមានលក្ខណៈប្រាកដប្រជាអំពីការងារដែលមាន និងពួកគេអាចធ្វើបាន។ ដូចជា Surtees (2012) លើកឡើងថា "ជាញឹកញាប់ ការធ្វើការជាមួយអ្នកទទួលផលពីគម្រោង ដើម្បីកំណត់នូវជម្រើសការងារដែលពិតប្រាកដ និងមានស្រាប់ វាទាមទារការចំណាយពេលវេលា និងការងារយ៉ាងច្រើន រួមទាំងការផ្តល់ប្រឹក្សាយោបល់រយៈពេលវែងដល់ពួកគេផងដែរ។" (ទំព័រទី ៣១)

រូបភាពខាងក្រោមរៀបរាប់ពីគំរូសមត្ថភាពហិរញ្ញវត្ថុដែលបានពណ៌នាខាងលើ។




**តារាង 25៖** គំរូសមត្ថភាពហិរញ្ញវត្ថុសម្រាប់ជនរួចពីរងគ្រោះ

### *៥.២.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវនៅពេលអនាគត*

គម្រោងសិក្សាស្រាវជ្រាវមេអំបៅរយៈពេលវែង គឺជាការសិក្សាដំបូងនៅក្នុងពិភពលោក។ ដំបូងឡើយ ការសិក្សាមានគោលបំណងផ្តោតទៅលើការជួយកម្មវិធីថែទាំជំនួស ចំនួន១៥អង្គការ ដែលធ្វើការជាមួយការអតិថិជនដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ ក្នុងគោលបំណងជួយកែលម្អសេវាកម្ម និងការគាំទ្រផ្សេងៗរបស់កម្មវិធីអង្គការដល់ជនជនរួចពីរងគ្រោះឲ្យបានកាន់តែប្រសើរឡើង។ នៅពេលដែលគម្រោងចាប់ផ្តើមដំណើរការពីមួយឆ្នាំទៅមួយឆ្នាំ អនុសាសន៍ដែលបានពីលទ្ធផលរកឃើញនៃការសិក្សា និងប្រភេទនៃការសិក្សាស្រាវជ្រាវបានកើតមានឡើងជាបន្តបន្ទាប់។ យើងសង្ឃឹមថា ការងារស្រាវជ្រាវរបស់គម្រោងមេអំបៅរយៈពេលវែង (BLR) នឹងចូលរួមចំណែកយ៉ាងច្រើន ក្នុងការយល់ដឹងអំពីការធ្វើសមាហរណកម្មជនរួចពីរងគ្រោះ ទាំងនៅក្នុងប្រទេសកម្ពុជា និងសកលលោក។ លក្ខណធម្មជាតិនៃគម្រោងសិក្សាស្រាវជ្រាវរយៈពេលវែងនេះ បានដោះស្រាយនូវបញ្ហាខ្លះៗរួចទៅហើយដូចជា "ការទុកចិត្តរបស់អតិថិជននឹងក្រុម

ស្រាវជ្រាវ" និងបានប្រមូលទិន្នន័យជា "សំឡេង" របស់ជនរួចពីការរងគ្រោះមួយចំនួនរួចទៅហើយ (
។

ការសិក្សាប៉ាន់ប្រមាណនេះ អាចចូលរួមចំណែកដល់កម្មវិធី និងសេវាសមាហរណកម្ម ដោយផ្តល់នូវការយល់ដឹងពីបទពិសោធន៍អស្ថេរភាព និងភាពព្រួយបារម្ភ ដែលជនរួចពីរងគ្រោះជួបប្រទះនៅក្នុងជីវិតផ្នែកហិរញ្ញវត្ថុរបស់ពួកគេ និងពីសារៈសំខាន់នៃគ្រួសារចំពោះសុខមាលភាពផ្លូវចិត្ត និងសេដ្ឋកិច្ចសង្គមរបស់ជនរួចពីរងគ្រោះ។ ទិន្នន័យសិក្សាប៉ាន់ប្រមាណនាពេលអនាគតអាចសិក្សាផ្តោតឲ្យជាក់លាក់បន្ថែមទៀតទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ជនរួចពីរងគ្រោះ និងសេវាសមាហរណកម្មសេដ្ឋកិច្ចនានាដូចជា៖

- របៀបដែលជនរួចពីរងគ្រោះ និងគ្រួសាររបស់ពួកគេរៀបចំខ្លួនសម្រាប់ ឬដោះស្រាយជាមួយភាពអាសន្នផ្នែកសេដ្ឋកិច្ច ដូចជា ភាពបន្ទាន់នៃការព្យាបាលជម្ងឺ ឬការស្លាប់បាត់បង់សមាជិកគ្រួសារណាម្នាក់ជាដើម។ ។ ព្រមទាំងបញ្ហានៃ ភាពអាសន្នផ្នែកសេដ្ឋកិច្ចមានលក្ខណៈយ៉ាងដូចម្តេចនៅក្នុងបទពិសោធន៍នៃការជួញដូររបស់ជនរួចពីរងគ្រោះ។
- ការសិក្សាពីស្ថានភាពសេដ្ឋកិច្ច និងបរិយាកាសការងាររបស់ជនរួចពីរងគ្រោះជាលក្ខណៈទូលំទូលាយ ថាតើប្រភេទការងារដែលងាយរងគ្រោះ ដើរតួយ៉ាងណានៅក្នុងបទពិសោធន៍របស់ជនរួចពីរងគ្រោះទាំងស្ថានភាពមុនពេល និង/ឬ ក្រោយពេលត្រូវបានគេការជួញដូរ។
- ការសិក្សាវិភាគលើទ្រព្យសម្បត្តិរបស់ជនរួចពីរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងលក្ខណៈដែលពួកគេទទួលបាន និងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ ជាវត្ថុបញ្ចាំ ឬធ្វើឲ្យមានជីវភាពរីកចម្រើនដូចជាការប្រើប្រាស់ទ្រព្យធន ជាប្រាក់សន្សំ ការបាត់បង់ទ្រព្យធននៅពេលមានបញ្ហាអាសន្នផ្នែកសេដ្ឋកិច្ចកើតឡើងជាដើម។

នៅចុងបញ្ចប់នៃរយៈពេល ១០ឆ្នាំនៃគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង ក្រុមអ្នកការងារស្រាវជ្រាវ គួរតែមានគោលបំណងប្រមូលទិន្នន័យឲ្យបានគ្រប់គ្រាន់ ដើម្បីអាចទាញយករូបភាពពេញលេញសមរម្យផ្នែកសេដ្ឋកិច្ច និងបទពិសោធន៍នៃការសងគុណរបស់ជនរួចពីរងគ្រោះទាំងមុនពេល កំឡុងពេល និងក្រោយពេលជួបប្រទះបទពិសោធន៍នៃជួញដូររបស់ពួកគេ។ ចំណុចនេះនឹងចូលរួមចំណែកយ៉ាងខ្លាំងក្នុងការយល់ពីរូបភាពធំពីរបៀប និងហេតុផលដែលបណ្តាលឲ្យពួកគេត្រូវបានគេជួញដូរ និងយល់ពីអ្វីដែលជាកត្តាជាក់លាក់នាំឲ្យមានភាពងាយរងគ្រោះរបស់ជនរងគ្រោះព្រមទាំងការយល់ដឹងពីរបៀបដែលភាពងាយរងគ្រោះមុនពេលជួញដូរ និងហានិភ័យទាំងនោះអាចនឹងត្រូវបានកាត់បន្ថយដោយការទប់ស្កាត់/ការពារការជួញដូរ និងជំរុញឲ្យមានការគាំទ្រកាន់តែប្រសើរឡើងដល់ជនរួចពីរងគ្រោះដោយការជួញដូរនៅពេលដែលពួកគេបានធ្វើសមាហរណកម្ម។

## ៦. គន្ថនិទ្ទេស


Adams, A. E. (2011). Measuring the Effects of Domestic Violence on Women's Financial Well-Being. Research Brief. University of Wisconsin-Madison Center for Financial Security.

Alexander, P. (2001, June). Contextual risk versus risk behaviour: The impact of the legal, social and economic context of sex work on individual risk taking. *Research for Sex Work: 4*, 2-4.

Andrews, B. & Wilding, J. M. (2004). The Relation of Depression and Anxiety to Life-Stress and Achievement in Students. *British Journal of Psychology*, *95*, 509–521.

Archuleta, K.L., Britt, S.L., Tonn, T.J., & Grable, J.E. (2011). Financial satisfaction and financial stressors in marital satisfaction. *Psychological Reports, 108*(2), 563-576.

Archuleta, K. L., Dale, A., & Spann, S. M. (2013). College Students and Financial Distress: Exploring Debt, Financial Satisfaction, and Financial Anxiety. *Journal of Financial Counseling and Planning, 24*(2), 50-62.

Brickell, K. (2011). "We don't forget the old rice pot when we get the new one": Discourses on Ideals and Practices of Women in Contemporary Cambodia. *Signs: 36*(2), 437-462.

Brown, E. (2007). The Ties that Bind: Migration and Trafficking of Women and Girls for Sexual Exploitation in Cambodia. Phnom Penh: IOM & U.S. State Department.

Brown University. (n.d.). Economic Stress. Brown University Health Services: http://brown.edu/Student_Services/Health_Services/Health_Education/common_college_health_issues/economic_stress.php.

Brunovskis, A. & Surtees, R. (2012). A Fuller Picture: Addressing Trafficking-Related Assistance Needs and Socio-Economic Vulnerabilities. The Fafo/NEXUS Institute Project.

Bryman, A. (2012). *Social Research Methods,* 4th Edition. Oxford: Oxford University Press.

Busza, J. (2004). Sex Work and Migration: The Dangers of Oversimplification – A Case Study of Vietnamese Women in Cambodia. *Health and Human Rights, 7*(2), 231-249.

Cavalieri, S. (2011). Between Victim and Agent: A Third-Way Feminist Account of Trafficking for Sex Work. *Indiana Law Journal: 86*(4), 1409-1458.

Chao, R. & Tseng, V. (2002). Parenting of Asians. In M. H. Bornstein (Ed.), *Handbook of Parenting: Volume 4. Social Conditions and Applied Parenting* (59-93). Mahwah: Lawrence Erlbaum Associates, Inc.

Chung, R. C.-Y. (2006). Human Trafficking for Sexual Exploitation: Psychological & Cultural Impacts. Global Studies Review. Retrieved from: http://www.globalitygmu.net.

Collins, J. M. and O'Rourke, C. (2012, February). Financial Capability and Domestic Violence. The University of Wisconsin-Extension Cooperative Extension

GADC. (2010). A Preliminary Analysis Report on Deoum Troung Pram Hath in Modern Cambodia: A Qualitative Exploration of Gender Norms, Masculinity and Domestic Violence. Phnom Penh: Gender and Development for Cambodia.

Gresenz, C. R., Sturm, R, & Tang, L. (2001). Income and Mental Health: Unraveling Community and Individual Level Relationships. *The Journal of Mental Health Policy and Economics, 4*, 197-203.

Johnson, E., & Sherraden, M. S. (2007). From Financial Literacy to Financial Capability Among Youth. *Journal of Sociology and Social Welfare 34*(3), 119-145.

Kasturirangan, A. (2009). Empowerment and Programs Designed to Address Domestic Violence. *Violence Against Women, 14*(12), 1465-1475.

Kourilsky, G. (2008, January). Note sur la piété filiale en Asie du Sud-Est theravādin : La notion de « guṇ ». [Note on filial piety in Southeast Asian Theravadin: The idea of “kun”]. *Aséanie 20*, 1-30.

Lainez, N. (2011). Transacted Children and Virginity: Ethnography of Ethnic Vietnamese in Phnom Penh. Ho Chi Minh City: Alliance Anti-Trafic Vietnam.

Lainez, N. (2012). Commodified Sexuality and Mother-Daughter Power Dynamics in the Mekong Delta. *Journal of Vietnamese Studies, 7*(1), 149-180.

Lainez, N. (2013). L’exploitation de la sexualité des femmes par leur famille au Vietnam: financer les chocs exogènes et le crédit informel (The Exploitation of Women’s Sexuality by their Family in Vietnam: Financing External Shocks and Informal Credit). *Autrepart, 66*(3), 133-152.

Lainez, N. (2015). Par-delà la traite des femmes vietnamiennes en Asie du Sud-Est. Anthropologie économique des carrières intimes (Beyond the Trafficking of Vietnamese Women in Southeast Asia: The Economic Anthropology of Careers of Intimacy). Doctoral Dissertation. Social Anthropology and Ethnology. École des hautes études en sciences sociales.

Law, L. (2000). *Sex Work in Southeast Asia: The Place of Desire in a Time of AIDS*. London & New York: Routledge.

Lewis, D. C. (2005). The Intersection of Filial Piety and Cultural Dissonance: Intergenerational Exchanges Among Khmer Families in the United States. University of Kentucky Doctoral Dissertations. Paper 372.

Lim, H., Heckman, S. J., Letkiewicz, J. C., & Montalto, C. P. (2014). Financial Stress, Self-Efficacy, and Financial Help-Seeking Behavior of College Students. *Journal of Financial Counseling and Planning, 25*(2), 148-160.

Lim, V. (2015). An Analysis on Economic (Re)-Integration of Sexual Exploitation Victims in Cambodia. Masters Thesis. Phnom Penh: Royal University of Phnom Penh.

Micollier, E. (ed.). (2004). *Sexual Cultures in East Asia: The Social Construction of Sexuality and Sexual Risk in a Time of AIDS*. London & New York: Routledge Curzon.

Miles, G. & Miles, S. (2010). The Butterfly Longitudinal Research Project: The Chab Dai study on (Re-) integration. Researching the lifecycle of sexual exploitation & trafficking in Cambodia. End of Year Progress Report 2010. Phnom Penh: Chab Dai Coalition.

Miles, G. & Miles, S. (2011). The Butterfly Longitudinal Research Project: The Chab Dai study on (Re-) integration. Researching the lifecycle of sexual exploitation & trafficking in Cambodia. End of Year Progress Report 2011. Phnom Penh: Chab Dai Coalition.

Miles, S., Heang, S., Lim, V., Orng, L. H., Smith-Brake, J., & Dane, S. (2012). The Butterfly Longitudinal Research Project: The Chab Dai study on (Re-) integration. Researching the lifecycle of sexual exploitation & trafficking in Cambodia. End of Year Progress Report 2012. Phnom Penh: Chab Dai Coalition.

Miles, S., Heang, S., Lim, V., Sreang, P, & Dane, S. (2013). The Butterfly Longitudinal Research Project: The Chab Dai study on (Re-) integration. Researching the lifecycle of sexual exploitation & trafficking in Cambodia. End of Year Progress Report 2013. Phnom Penh: Chab Dai Coalition.

Morrison, T., Miles, S., Schafer, P., Heang, S., Lim, V., Sreang, P., & Nhanh, C. (2014). Resilience: Survivor Experiences and Expressions. Thematic Paper of the Butterfly Longitudinal Research Project: A Chab Dai study on (Re-)integration: Researching the lifecycle of sexual exploitation & trafficking in Cambodia (Phnom Penh: Chab Dai).

Morrison, T., Miles, S., Lim, V. Nhanh, C., Sreang, P., & Bun, D. (2015). Stigma: Survivor Experiences and Perceptions. Thematic Paper of the Butterfly Longitudinal Research Project: A Chab Dai study on (Re-)integration: Researching the lifecycle of sexual exploitation & trafficking in Cambodia. (Phnom Penh: Chab Dai).

Nussbaum, M. C. (2005). Women's Bodies: Violence, Security, Capabilities. *Journal of Human Development, 6*(2), 167-183.

Nichols, R. (2013). The Origins and Effects of Filial Piety (Xiao 孝): How Culture Solves an Evolutionary Problem for Parents. *Journal of Cognition and Culture, 13*: 201–230.

Postmus, J. L. (2010, October). Economic Empowerment of Domestic Violence Survivors. Harrisburg, PA: VAWnet, a project of the National Resource Center on Domestic Violence.

Postmus, J. L., Plummer, S.-B., McMahon, S., Murshid, N. S., & Kim, M. S. (2011). Understanding Economic Abuse in the Lives of Survivors. *Journal of Interpersonal Violence*, *20*(10), 1–20.

Postmus, J. L., Plummer, S.-B., McMahon, S., & Zurlo, K. A. (2012). Financial Literacy: Building Economic Empowerment with Survivors of Violence. *Journal of Family and Economic Issues, 34*, 275–284

Reimer, J. K., Gourley, S., & Langeler, E. (2006). "At what price, honour?" Research into domestic trafficking of Vietnamese (girl) children for sexual exploitation, from urban slums in Phnom Penh, Cambodia. Phnom Penh: Chab Dai Coalition.

Sanders, C. K. (2007). Domestic Violence, Economic Abuse and Implications of a Program for Building Economic Resources for Low-Income Women: Findings from Interviews with Participants in a Women's Economic Action Program (CSD Research Report 07-12). St. Louis: Washington University, Center for Social Development.

Sanders, C. K. (2013). Financial Capability Among Survivors of Domestic Violence. In J. Birkenmaier, M. S. Sherraden, & J. Curley (Eds.), *Financial Capability and Asset Development: Research, Education, Policy, and Practice* (85-107). New York : Oxford University Press.

Sanders, C. K. (2014). Savings for Survivors: An Individual Development Account Program for Survivors of Intimate-Partner Violence. *Journal of Social Service Research*, *40*(3), 297-312.

Sandy, L. (2006). Sex Work in Cambodia: Beyond the Voluntary/Forced Dichotomy. *Asian and Pacific Migration Journal*, *15*(4), 449-469.

Sareen, J., Afifi, T. O., McMillan, K. A., & Asmundson, G. J. G. (2011). Relationship Between Household Income and Mental Disorders: Findings From a Population-Based Longitudinal Study. *Archives of General Psychiatry, 68*(4), 419-427.

Schunter, B. (2001, June). Filial piety and Vietnamese sex workers in Svay Pak, Cambodia. *Research for Sex Work: 4*, 9-10.

Shapiro, G. K. and Burchell, B. J. (2012). Measuring Financial Anxiety. *Journal of Neuroscience, Psychology, and Economics*, *5*(2), 95-103.

Sherraden, M. S. (2010). Financial Capability: What is it, and How Can it be Created? (CSD Working Paper. 10-17). St. Louis: Washington University, Center for Social Development.

SIREN. (2009). Re-thinking Reintegration: What do Returning Victims Really Want & Need? Evidence from Thailand and the Philippines. Bangkok: United Nations Inter-Agency Project on Human Trafficking.

Smith-Brake, J. (2011). Enhancing Financial Capability Among Youth in Hochelaga-Maisonneuve. Masters Thesis. Manchester: Southern New Hampshire University.

Surtees, R. (2010). Monitoring Anti-Trafficking Re/integration Programmes. A Manual. Washington & Brussels: NEXUS Institute & King Baudouin Foundation.

Surtees, R. (2012). Re/integration of trafficked persons: supporting economic empowerment. Brussels: King Baudouin Foundation.

Morrison, T., Miles, S., Lim, V., Nhanh, C., Sreang, P. & Bun, D. (2015). Survivor Experiences and Perceptions of Stigma: Reintegrating into the Community. The Butterfly Longitudinal Research Project: A Chab Dai study on (Re-)integration: Researching the lifecycle of sexual exploitation & trafficking in Cambodia. (Phnom Penh: Chab Dai).

Ty, M., Walsh, J. & Anurit, P. (2010). An Empirical Assessment of the Relationship between National Culture and Learning Capability in Organisations in Cambodia. *International Business Research, 3*(4), 81-90.

Walters, I. (2004). Dutiful Daughters and Temporary Wives: Economic Dependency on Commercial Sex in Vietnam. In E. Micollier (Ed.), *Sexual Cultures in East Asia: The Social Construction of Sexuality and Sexual Risk in a Time of AIDS*. London & New York: Routledge Curzon.

Weaver, T. L., Sanders, C. K., Campbell, C. L., & Schnabel, M. (2009). Development and Preliminary Psychometric Evaluation of the Domestic Violence—Related Financial Issues Scale (DV-FI). *Journal of Interpersonal Violence, 24*(4), 569-585.